# សៀវភៅ

# ស្តីពី

# នីតិវិធីនៃការរឹបអូស
# ជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

( បោះពុម្ពលើកទី ១ )

បោះពុម្ព នៅខែមិនា ឆ្នាំ ២០០៩

# **អារម្ភកថា**

សៀវភៅ ស្តីពី " **នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ** " នេះរួមមាន បី ផ្នែក

**ផ្នែកទី ១** ស្តីពី " សេនារីយូជាមូលដ្ឋានដែលជាសាច់រឿងនៃរឿងក្តីជាឧទាហរណ៍ "

**ផ្នែកទី ២** ស្តីពី " សំណុំឯកសារគំរូ ※ ដែលជាឧទាហរណ៍នៃសំណុំរឿងនៃរឿងក្តីសេនារីយូជាមូលដ្ឋាន"

**ផ្នែកទី ៣** ស្តីពី " មេរៀនដែលពន្យល់អំពីនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ "

សៀវភៅនេះត្រូវបានបង្កើតឡើងដោយសមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម (RSJP) ដោយមានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន (JICA) និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌ប្រទេសជប៉ុន (ICD) ។

សមាជិកនៃក្រុមការងាររួមមានដូចខាងក្រោម:

លោក អ៊ិន វ៉ាន់វិបុល លោកស្រី ចាំង ស៊ីណាត លោកស្រី សែម សក្តិកូឡា លោក សេង នាង លោក ប្លង់ សំណាង លោក តាំង ស៊ុនឡាយ លោក យូ ប៊ុនណា លោក ងួន រតនា លោក គង់ តារាឆាត លោក ម៉ុង មុន្នីសោភា លោក គីម ម៉េង លោក ហ៊ួត ហ៊ាង លោក ជា សុខហៀង លោក ហេង សុខណា លោក ជីវ ចាន់តារា និងលោក យូ ទិតវឌ្ឍនៈ

សៀវភៅនេះបោះពុម្ពលើកទី ១ នៅខែ មិនា ឆ្នាំ ២០០៩

---

※ រូបមន្តដែលមាននៅក្នុងសំណុំឯកសារនេះត្រូវបានបង្កើតឡើងដោយសមាជិកក្រុមការងារ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន JICA និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ICD ដោយផ្អែកលើរូបមន្តរបស់ប្រទេសជប៉ុន ហើយក្រសួងយុត្តធម៌របស់ព្រះរាជាណាចក្រកម្ពុជាមិនទាន់អនុញ្ញាតឱ្យជាផ្លូវការនៅឡើយទេ។

[សេណារីយូ (Scenario) មូលដ្ឋាន នៃការការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ]

## ១. រឿងក្តីគម្រូ

ខៀវ អាត (K) បានឱ្យសុក បូរា (S) ខ្ចីប្រាក់ចំនួន ៨.០០០ដុល្លារ ដោយមានការព្រមព្រៀងសង នៅ ថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៦។ ប៉ុន្តែ S មិនបានសងប្រាក់ទៅឱ្យ K ទេ ទោះបីកាលបរិច្ឆេទនៃការកំណត់សងបាន កន្លងហួសហើយក៏ដោយ។ ប្រមាណប្រហែលជានៅក្នុងខែ កក្កដា ឆ្នាំ ២០០៦ K បានដាស់តឿនជាញឹកញាប់ឱ្យ S សងប្រាក់ ប៉ុន្តែ S មិនបានសងប្រាក់ឡើយដោយលើកមូលហេតុថា ខ្លួនបានសងប្រាក់ចំនួន ៦.០០០ដុល្លារ មុនកាលកំណត់សង ហើយបំណុលដែលនៅសល់ត្រូវបានគេលើកលែង។

ក្នុងករណី S គ្មានការស្ម័គ្រចិត្តក្នុងការសងប្រាក់ទេ K ត្រូវឆ្លងកាត់នីតិវិធីអនុវត្តដោយបង្ខំ K ដាក់ពាក្យបណ្តឹងទាមទារប្រាក់កំចី K បានឈ្នះក្តី ហើយអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិរបស់ S ដោយផ្អែកលើសាលក្រមចុងក្រោយ។

## ២. ការរក្សាការពារ (ការរឹបអូសជាបណ្តោះអាសន្ន)

S បានជំពាក់ប្រាក់ញាតិសណ្តានរបស់គាត់ច្រើនណាស់ ដោយគាត់យកប្រាក់នោះទៅចំណាយលើថ្លៃព្យាបាលឪពុករបស់គាត់ ហើយគាត់ស្ថិតនៅក្រោមសំពាធត្រូវសងប្រាក់កំចីទៀត។ បន្ថែមពីលើនេះទៀត ការរកស៊ីរបស់ S មើលទៅមិនដំណើរការល្អសោះ។ S ជាម្ចាស់នៃអាគារ និង ដីមួយកន្លែង ប៉ុន្តែគ្មានទ្រព្យសម្បត្តិពិសេសផ្សេងក្រៅពីនេះទេ។

ក្នុងករណីដែល S លក់ដី ឬ អាគារទៅឱ្យតតិយជន ហើយចាយវាយមុនពេល K ដាក់ពាក្យសុំសម្រាប់ការអនុវត្តដោយបង្ខំតាមរយៈនីតិវិធីដែលបានរៀបរាប់ខាងលើ នោះ S នឹងគ្មានទ្រព្យសម្បត្តិសម្រាប់ K ធ្វើការអនុវត្តដោយបង្ខំឡើយ ហើយនឹងមានការលំបាកជាខ្លាំងសម្រាប់ K ក្នុងការប្រើសិទ្ធិរបស់គាត់ ប្រសិនបើគាត់ឈ្នះក្តី។ ដូច្នេះ មុនពេលដាក់បណ្តឹង K ត្រូវការនូវវិធានការដើម្បីអាចមានលទ្ធភាពក្នុងការអនុវត្ត ដោយបង្ខំនាពេលអនាគត ទោះបីជា S លក់ដី ឬ អាគាររបស់គាត់ទៅឱ្យតតិយជនក៏ដោយ។

ដូច្នេះ នៅថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០០៧ (តទៅនេះគ្រប់កាលបរិច្ឆេទទាំងអស់សំដៅលើកាលបរិច្ឆេទក្នុងឆ្នាំ ២០០៧) មាស ពេជ្រ (M) ជាមេធាវីរបស់ K បានដាក់ពាក្យសុំទៅសាលាដំបូងក្រុងភ្នំពេញ ដើម្បីឱ្យរឹបអូសជាបណ្តោះអាសន្ន ចំពោះដី និង អាគាររបស់ S។

បន្ទាប់ពីបានពិនិត្យលើពាក្យសុំខាងលើរួចហើយ ចៅក្រមសាលាដំបូងក្រុងភ្នំពេញបានពិនិត្យលើឯកសារសេចក្តីបញ្ជាក់ដំបូងដែលភ្ជាប់ជាមួយនឹងពាក្យសុំ ហើយបានកោះហៅម្ចាស់បំណុល K និង មេធាវី M

របស់គាត់ដើម្បីធ្វើការបំភ្លឺ ។ ជាលទ្ធផល អត្ថិភាពនៃការទាមទាររបស់ K លើប្រាក់កំចីដែលជាសិទ្ធិទទួលការការពារ និង ភាពចាំបាច់សម្រាប់រក្សាការពារសិទ្ធិត្រូវបានបញ្ជាក់យ៉ាងច្បាស់ ។

បន្ទាប់មក នៅថ្ងៃទី ០៥ ខែ មករា ចៅក្រមបានសម្រេចឱ្យម្ចាស់បំណុល K ត្រូវដាក់ប្រាតិភោគចំនួន ២.000ដុល្លារសម្រាប់ កិច្ចការរក្សាការពារ ហើយបានជូនដំណឹងអំពីការសម្រេចនេះទៅ K ។

នៅថ្ងៃទី ៩ មករា មេធាវី M បានបញ្ចូលទឹកប្រាក់នេះទៅក្នុងនាយកដ្ឋានសម្រាប់តំកល់ប្រាក់ធានានៅក្នុងតុលាការ ហើយបានដាក់នូវរបាយការណ៍អំពីការដាក់ប្រាក់តំកល់ទៅនាយកដ្ឋានកិច្ចការរក្សាការពាររបស់តុលាការ ។

នៅថ្ងៃដដែល បន្ទាប់ពីពិនិត្យរបាយការណ៍ស្តីពីប្រាក់តំកល់ដែល M បានដាក់ តុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះដី និង អាគាររបស់ S ហើយប្រគល់ឯកសារចំលងយថាភូតដោយផ្ទាល់ដៃទៅមេធាវី M ។

មេធាវី M បានដាក់ពាក្យសុំភ្លាមទៅសាលាដំបូងក្រុងភ្នំពេញដើម្បីអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។ ដោយទទួលបាននូវពាក្យសុំនេះ ក្រឡាបញ្ជីបានផ្ទុកផ្តាក់ឱ្យទៅចុះបញ្ជីរឹបអូសជាបណ្តោះអាសន្នចំពោះទ្រព្យសម្បត្តិរបស់ S និង បន្តបន្ទាប់មកទៀត ការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្នបានបំពេញចប់សព្វគ្រប់ ។

## ៣. បណ្តឹងអង្គសេចក្តី

នៅថ្ងៃទី ១២ ខែមករា មេធាវីរបស់ K គឺ M បានដាក់ពាក្យបណ្តឹងទាមទារប្រាក់កំចីពី S ទៅសាលាដំបូងក្រុងភ្នំពេញ ។

នៅថ្ងៃទី ៤ មេសា ចៅក្រមបានចេញសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទ K ។ នៅថ្ងៃទី ៦ មេសា អនុសារសាលក្រមត្រូវបានបញ្ជូនទៅចុងចម្លើយ S ហើយសាលក្រមបានចូលជាស្ថាពរ និង មានអានុភាពអាជ្ញាអស់ជំនុំបន្ទាប់ពីថ្ងៃទី ៦ ឧសភា ដោយសារ S មិនបានធ្វើបណ្តឹងឧទ្ធរណ៍ ។

## ៤. ការលុបចោលប្រាតិភោគសម្រាប់កិច្ចការរក្សាការពារ

នៅថ្ងៃទី ១០ ឧសភា មេធាវីរបស់ K គឺ M បានដាក់ពាក្យសុំទៅសាលាដំបូងក្រុងភ្នំពេញដើម្បីសុំលុបចោលប្រាតិភោគដែល K បានដាក់សម្រាប់ការចាត់ចែងរក្សាការពារ ហើយបានទទួលប្រាក់តំកល់នោះយោងតាម ដីកាសម្រេចលុបចោលប្រាតិភោគរបស់តុលាការ ។

# មាតិកា

## បញ្ជីឈ្មោះឯកសារ (សំណុំឯកសារគម្រូ)

**ទំព័រ**


| | | | |
|---|---|---|---|
| ១ | ពាក្យសុំដីកាសំរេចរក្សាការពារ | | ១ |
| | ឯកសារភ្ជាប់ | លិខិតកិច្ចសន្យាខ្ចីបរិភោគ | ៦ |
| | ឯកសារភ្ជាប់ | ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអំពីអចលនវត្ថុ | ៧ |
| | ឯកសារភ្ជាប់ | របាយការណ៍របស់ម្ចាស់បំណុល | ៨ |
| | ឯកសារភ្ជាប់ | លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ | ១០ |
| ២ | ដីកាសម្រេចអំពី ប្រាតិភោគ | | ១១ |
| ៣ | របាយការណ៍អំពីការផ្ញើប្រាក់ | | ១៤ |
| ៤ | ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន | | ១៦ |
| ៥ | របាយការណ៍អំពីការបញ្ជូនដីកាសម្រេចទៅម្ចាស់បំណុល | | ២១ |
| ៦ | ពាក្យសុំអនុវត្តការចាត់ចែងរក្សាការពារ | | ២៣ |
| | ឯកសារភ្ជាប់ | លិខិតចម្លងយថាភូតនៃដីកាសម្រេចការរឹបអូសជាបណ្តោះអាសន្ន | ២៨ |
| | ឯកសារភ្ជាប់ | លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ | ២៩ |
| ៧ | លិខិតផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន | | ៣០ |
| ៨ | សេចក្តីបញ្ជាក់ នៃសៀវភៅចុះបញ្ជី (ការចុះបញ្ជីការរឹបអូសជាបណ្តោះអាសន្ន) | | ៣២ |
| ៩ | របាយការណ៍ស្តីពី ការបញ្ជូនដីកាសម្រេចទៅកូនបំណុល | | ៣៣ |
| ១០ | ពាក្យសុំលុបប្រាតិភោគ | | ៣៥ |
| | ឯកសារភ្ជាប់ | អនុសារសាលក្រមលើបណ្តឹងអង្គសេចក្តី | ៣៧ |
| | ឯកសារភ្ជាប់ | លិខិតបញ្ជាក់អំពីហេតុដែលសាលក្រមបានចូលជាស្ថាពរ | ៣៨ |
| ១១ | ដីកាសម្រេចលុបប្រាតិភោគ | | ៣៩ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៧

## ពាក្យសុំដីកាសម្រេចរក្សាការពារ

ខ្ញុំបាទឈ្មោះ មាស ពេជ្រ ជាមេធាវី អ្នកតំណាងដោយអាណត្តិ របស់លោក ខៀវ អាត ដូចដែលមានបញ្ជាក់ក្នុង បញ្ជីភាគី ដែលមាននៅក្នុងឯកសារឧបសម្ពន្ធ ។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងក្រុងភ្នំពេញ**

**កម្មវត្ថុៈ ពាក្យសុំដីកាសំរេចរឹបអូសជាបណ្តោះអាសន្ន**

ខ្ញុំបាទឈ្មោះ ខៀវ អាត សុំដីកាសម្រេចរឹបអូសជាបណ្តោះអាន្នចំពោះអចលនវត្ថុដូចដែលមានបញ្ជាក់នៅក្នុង បញ្ជីអចលនវត្ថុនៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធរបស់កូនបំណុលឈ្មោះ សុខ បូរ៉ា ដូចដែលមានបញ្ជាក់ក្នុង បញ្ជីភាគីនៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធ ដើម្បីធានានូវការអនុវត្តសិទ្ធិលើបំណុលរបស់ខ្ញុំបាទចំពោះកូនបំណុល ដូចមាននៅក្នុងឯកសារឧបសម្ព័ន្ធស្តីពី បញ្ជីសិទ្ធិលើបំណុល។

## មូលដ្ឋាននៃពាក្យសុំ

**១_សិទ្ធិនឹងត្រូវបានរក្សាការពារ :**

ម្ចាស់បំណុលឈ្មោះ ខៀវ អាត បានឱ្យកូនបំណុលឈ្មោះ សុខ បូរ៉ា ខ្ចីប្រាក់ចំនួន ៨.០០០ ដុល្លា ដោយ មានការ ព្រមព្រៀងសងនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៤ ប៉ុន្តែកូនបំណុលមិនបានសងប្រាក់ទៅម្ចាស់បំណុលទេ ទោះបីកាល បរិច្ឆេទនៃការកំណត់សងថ្ងៃទី០១ ខែមថុនា ឆ្នាំ២០០៦ បានកន្លងហួសទៅហើយក៏ដោយ។ ប្រហែលនៅខែកក្កដា ឆ្នាំ ២០០៦ ម្ចាស់បំណុលបានដាស់តឿនជាញឹកញាប់ ប៉ុន្តែកូនបំណុលមិនបានសងប្រាក់ឡើយ ។

**២_ភាពចាំបាច់សម្រាប់នៃការរក្សាការពារៈ**

កូនបំណុលបានអះអាងថា គាត់បានសងប្រាក់ចំនួន ៦.០០០ដូល្លារ មុនកាលកំណត់សង ហើយបំណុលដែលនៅ សល់ម្ចាស់បំណុលបានលើកលែងទៅវិញ។

-កូនបំណុលបានជំពាក់ប្រាក់ញាតិសណ្ដានច្រើនណាស់ ដោយកូនបំណុលយកប្រាក់នោះទៅចំណាយលើថ្លៃព្យាបាលឪពុករបស់គាត់ ហើយគាត់ស្ថិតនៅក្រោមសំពាធត្រូវសងប្រាក់កំចីទៀត។ បន្ថែមលើនេះការរកស៊ីរបស់កូនបំណុល មើលទៅមិនដំណើរការល្អសោះ។ កូនបំណុលជាម្ចាស់នៃអាគារ និងដីមួយកន្លែង (A២) ប៉ុន្តែគ្មានទ្រព្យពិសេសផ្សេង ទៀតក្រៅពីនេះទេ។ បន្ថែមលើបំណុលក្នុងរឿងក្ដីបច្ចុប្បន្ន ហើយស្ថិតក្នុងស្ថានភាពមួយដែលកូនបំណុលអាចចាត់ចែង ទ្រព្យរបស់ខ្លួនគ្រប់ពេល ដូចមានការបង្ហាញក្នុងបញ្ជីអំពីអចលនវត្ថុ (A៣) ។

-មានតែទ្រព្យនីមួយៗដែលបានរៀបរាប់នៅក្នុងឯកសារពិពណ៌នាអំពីអចលនវត្ថុ ត្រូវបានរឹបអូសជាបណ្ដោះអាសន្នជាមុនទេ ទើបម្ចាស់បំណុលអាចអនុវត្តសិទ្ធិបាន បើមិនដូច្នោះទេ ម្ចាស់បំណុលមិនអាច ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសាលក្រមនៅពេលដែលម្ចាស់បំណុលឈ្នះក្ដី។

## ឯកសារបញ្ជាក់ដំបូង

A១ : លិខិតកិច្ចសន្យាខ្ចីបរិភោគ

A២ : លិខិតយថាភូតនៃការចុះបញ្ជីអចលនវត្ថុ

A៣ : របាយការណ៍រៀបចំដោយម្ចាស់បំណុល

## ឯកសារភ្ជាប់

| | |
|---|---|
| ភស្តុតាង A១. A២. និងA៣ | ១ច្បាប់សម្រាប់ភស្តុតាងនីមួយៗ (ថតចម្លង) |
| លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ | ១ច្បាប់ (ថតចម្លង) |

**ហត្ថលេខា**

**មាស ពេជ្រ**

## **បញ្ជីភាគី**

ម្ចាស់បំណុល: **ខៀវ អាត** អាយុ ៤៦ ឆ្នាំ

អាស័យដ្ឋាន: ផ្ទះលេខ ១២ សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ

អត្តសញ្ញាណប័ណ្ណលេខ ១១១

អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល មាស-ពេជ្រ (មេធាវី)

អាស័យដ្ឋាន: លេខ XX,00 ភ្នំពេញ (កន្លែងដែលត្រូវធ្វើការបញ្ជូន)

លេខទូរស័ព្ទ:0២៣-###-###

កូនបំណុល: **សុខ បូរ៉ា** អាយុ ៤៦ ឆ្នាំ អត្តសញ្ញាណប័ណ្ណលេខ ២២២២

អាស័យដ្ឋាន: លេខ ៣៤ សង្កាត់ ផ្សារកណ្ដាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ។

# បញ្ជីសិទ្ធិលើបំណុលដែលទាមទារ

ទឹកប្រាក់ចំនួន ៨០០០ដុល្លារ ( ប្រាំបីពាន់ដុល្លារ)

សិទ្ធិលើបំណុលដែលទាមទារឱ្យសងប្រាក់ដែលដើមចោទបានឱ្យចុងចំលើយខ្ចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដែលបានបង្កើតឡើងរវាង ដើមចោទ និងចុងចំលើយនៅថ្ងៃ ០១ ខែ មិថុនា ឆ្នាំ ២០០៤ កាលបរិច្ឆេទនៃការសងគឺ នៅថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០០៦។

## បញ្ជីអចលនវត្ថុ

ទីតាំង ផ្ទះលេខ ៣៤ សង្កាត់ ផ្សារកណ្តាល ខណ្ឌដូនពេញ ក្រុង ភ្នំពេញ

លេខ 000

ប្រភេទនៃដី ជាតំបន់សម្រាប់រស់នៅ

ទំហំ:.........ម៉ែត្រការេ

សមាសភាពនៃដីខាងលើៈ ជាអាគារ (ផ្ទះ)

ប្រភេទនៃផ្ទះ: សម្រាប់លំនៅដ្ឋាន

លក្ខណៈនៃអាគារៈ ធ្វើពីថ្ម

ទំហំអាគារ 00ម$^{២}$

# កិច្ចសន្យាខ្ចីបរិភោគ

លិខិតនៃកិច្ចសន្យាខ្ចីបរិភោគ លេខ 0A-99999A
កិច្ចសន្យាខ្ចីបរិភោគនេះត្រូវបានធ្វើឡើងរវាងម្ចាស់បំណុល និងកូនបំណុលខាងក្រោមនេះ :

ម្ចាស់បំណុល : ខៀវ អាត អត្តសញ្ញាណបណ្ណ លេខ 1 1 1 1
ទូរសព្ទលេខ : 012-999-111
អាសយដ្ឋាន : No. 12 ផ្លូវលេខ 00 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ

កូនបំណុល : សុខ បូរា អត្តសញ្ញាណបណ្ណ លេខ 2 2 2 2
ទូរសព្ទលេខ : 012-999-222
អាសយដ្ឋាន : No. 34 ផ្លូវលេខ 00 សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ ភ្នំពេញ

ភាគីទាំងពីរខាងលើនេះ បានព្រមព្រៀងដូចតទៅ :

1. កូនបំណុលបានខ្ចីប្រាក់ចំនួន ៨000ដូល្លារ ពីម្ចាស់បំណុល នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២00៤ ហើយនាថ្ងៃដដែលនេះ ក៏បានទទួលប្រាក់ ៨000ដូល្លារនេះ ពីម្ចាស់បំណុល ។
2. រយៈពេលខ្ចី ២៤ខែ ( គិតពីថ្ងៃដែលបានប្រគល់ប្រាក់)
3. ការប្រាក់ក្នុងរយៈពេលខ្ចី ១0% ក្នុងមួយឆ្នាំ
4. កូនបំណុលត្រូវសង ៨000ដូល្លារ និងការប្រាក់ទៅឱ្យម្ចាស់បំណុល ២៤ខែក្រោយ គឺនៅថ្ងៃទី១ ខែ មិថុនា ឆ្នាំ ២00៦ ។
5. ក្នុងករណីដែលកូនបំណុលមិនអាចសងប្រាក់ទាំងអស់ តាមកាលកំណត់ខាងលើនេះទេ កូនបំណុលត្រូវបង់ការប្រាក់នៃការយឺតយ៉ាវ ។
   ការប្រាក់នៃការយឺតយ៉ាងគឺ ២0%ក្នុងមួយឆ្នាំ ដែលស្មើនឹងទ្វេដងនៃការប្រាក់ ហើយត្រូវគណនាដោយផ្អែកលើទឹកប្រាក់ដែលសងយឺតយ៉ាវ និងរយៈពេលនៃការសងយឺតយ៉ាវ ។

ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២00៤ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២00៤

មេដៃស្តាំរបស់ម្ចាស់បំណុល មេដៃស្តាំរបស់កូនបំណុល

A ( ហត្ថលេខា ) B ( ហត្ថលេខា )

# ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ នៃសៀវភៅ
# ចុះបញ្ជីអំពី អចលនវត្ថុ

# (លុបចោល)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ ថ្ងៃទី ៤ ខែមករា ឆ្នាំ ២០០៧

## របាយការណ៍

ខ្ញុំបាទឈ្មោះ ខៀវ អាត ដែលមានអាសយដ្ឋាន ផ្ទះលេខ ១២ សង្កាត់ ទន្លេ បាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ។

**គោរពជូន**

**ប្រធានសាលាដំបូងក្រុងភ្នំពេញ**

### ១. សេចក្តីផ្តើម

ខ្ញុំសូមជម្រាបជូនលោកប្រធានអំពីមូលហេតុដែលខ្ញុំសម្រេចដាក់ពាក្យសុំមក សាលាដំបូងក្រុងភ្នំពេញដើម្បីចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះដី និង អាគាររបស់សុក បូរ៉ា (កូនបំណុល)។

### ២. កិច្ចសន្យាខ្ចីបរិភោគរវាង សុក បូរ៉ា និង ខ្ញុំ

ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៤ សុក បូរ៉ា ដែលមានអាស័យដ្ឋានផ្ទះលេខ ៣៤ សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ ក្រុងភ្នំពេញ បានខ្ចីប្រាក់ពីខ្ញុំចំនួន ៨.០០០ដូល្លារ ហើយសន្យាសងប្រាក់នៅ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦។ កូនបំណុលបានយល់ព្រមបង់ការប្រាក់ចំនួន ១០ភាគរយ ក្នុងមួយឆ្នាំ និង ការប្រាក់យឺតយ៉ាវ ចំនួន ២០ភាគរយ ក្នុងមួយឆ្នាំ ក្នុងករណីដែលកូនបំណុលមិនសងប្រាក់នៅថ្ងៃកំណត់សង។

### ៣. ភាពយឺតយ៉ាវនៃការសងប្រាក់

នៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៦ ដែលជាថ្ងៃកំណត់សង កូនបំណុលបានមកផ្ទះរបស់ខ្ញុំ ហើយគាត់បាននិយាយថា គាត់ត្រូវការប្រាក់ដើម្បីព្យាបាលជម្ងឺឪពុករបស់គាត់។ ប្រហែលជាក្នុង ខែកក្កដា ឆ្នាំ ២០០៦ ខ្ញុំបានដាស់តឿនជាញឹកញាប់ឱ្យកូនបំណុលសងប្រាក់ ប៉ុន្តែកូនបំណុលមិនបានសងទេ សរុបមកកូនបំណុលមិនដែលសងទាំងប្រាក់ដើម និង ការប្រាក់រហូតមកដល់សព្វថ្ងៃនេះ។

## ៤. ស្ថានភាពសេដ្ឋកិច្ចរបស់កូនបំណុល

ក្រោយមកខ្ញុំបានឮថា កូនបំណុលបានជំពាក់ប្រាក់ញាតិសណ្ដានរបស់គាត់ជាច្រើននាក់ ដោយគាត់យកប្រាក់នោះទៅព្យាបាលជម្ងឺឪពុករបស់គាត់ ហើយគាត់កំពុងស្ថិតនៅក្រោមសំពាធដែលត្រូវសងប្រាក់កំចីទៀត។ បន្ថែមពីលើនេះ របរអាជីវកម្មរបស់កូនបំណុលមើលទៅមិនដំណើរការល្អសោះ ហើយកាលបរិច្ឆេទកំណត់សងបានកន្លងហួសដែរ។

កូនបំណុលមានតែដី និងអាគារមួយកន្លែងប៉ុណ្ណោះ គាត់គ្មានទ្រព្យសម្បត្តិអ្វីក្រៅពីនេះទេ។ ក្នុងករណីដែលកូនបំណុលលក់ដី និងអាគារដែលគាត់មាននោះទៅឱ្យតតិយជន ហើយធ្វើការចាយវាយអស់នោះ កូនបំណុលនឹងគ្មានទ្រព្យសម្បត្តអ្វីសេសសល់ឡើយ។ ខ្ញុំមានការបារម្ភថា អាចនឹងមានការលំបាកក្នុងការអនុវត្តនូវសិទ្ធិរបស់ខ្ញុំ។

## ៥. សន្និដ្ឋាន

ដូច្នេះ ខ្ញុំដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដើម្បីធានានូវសិទ្ធិរបស់ខ្ញុំក្នុងការទាមទារឱ្យសងប្រាក់។

ហត្ថលេខា

**ខៀវ អាត**

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ថ្ងៃទី ២ ខែមករា ឆ្នាំ២០០៧

អាសយដ្ឋាន : No. 12 ផ្លូវលេខ 00 សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ
អាណត្តិទាយក : ខៀវអាត អត្តសញ្ញាណបណ្ណលេខ : ១១១១

តាមរយៈលិខិតនេះ ខ្ញុំសូមតែងតាំងមេធាវីខាងក្រោមនេះ ឱ្យធ្វើជាតំណាងដោយអាណត្តិរបស់ខ្ញុំ ព្រមទាំងប្រគល់សិទ្ធិបំពេញកិច្ចការខាងក្រោម ដែលពាក់ព័ន្ធទៅនឹងរឿងក្តីនេះ :

មេធាវី : មាស ពេជ្រ
អាសយដ្ឋាន : ××, ○○, ភ្នំពេញ
ទូរស័ព្ទ : ០២៣-###-###
ទូរសារ : 000-000-111

ការពិពណ៌នា

I . រឿងក្តី :

1. ភាគីម្ខាងទៀត
   កូនបំណុល : សុក បូរ៉ា
2. តុលាការ :
   សាលាដំបូងក្រុងភ្នំពេញ
3. សញ្ញាណនៃរឿងក្តី :
   រឿងក្តីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុរបស់កូនបំណុល ដោយម្ចាស់បំណុល

II. ចំណុចដែលអាណត្តិ

1. សិទ្ធិអំណាចពេញលេញក្នុងការធ្វើសកម្មភាពតំណាងឱ្យម្ចាស់បំណុល
2. ការដាក់ពាក្យបណ្តឹងតប
3. ការដកពាក្យបណ្តឹង ការផ្សះផ្សា ការបោះបង់ឬការទទួលស្គាល់ការទាមទារ ឬ ការចូលរួមអន្តរាគមន៍ក្នុង បណ្តឹង
4. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ ឬ ពាក្យបណ្តឹងតវ៉ា ឬការដកពាក្យបណ្តឹងទាំងនេះ
5. ការតែងតាំងអនុតំណាង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងក្រុងភ្នំពេញ

លេខ ៥ ឆ្នាំ ២០០៧

## ដីកាសម្រេចអំពីប្រាតិភោគ

-បានឃើញសំណុំរឿងរក្សាការពារ លេខ ០៩ ឆ្នាំ ២០០៧

**ភាគី:** ដូចមានចង្អុលបង្ហាញនៅក្នុងបញ្ជីពណ៌នាអំពីភាគីដែលមានភ្ជាប់មកជាមួយ

**សិទ្ធិលើបំណុលដែលបានទាមទារ:** ដូចមានចង្អុលបង្ហាញនៅក្នុងបញ្ជីពណ៌នាអំពីសិទ្ធិលើបំណុលដែលមានភ្ជាប់មកជាមួយ ។

យោងលើករណីនៃពាក្យសុំសម្រាប់ការរឹបអូសជាបណ្ដោះអាសន្នរវាងភាគីខាងលើ (លេខ ៩ ឆ្នាំ ២០០៧) តុលាការបានសម្រេចដូចខាងក្រោម:

## សេចក្ដីសម្រេចបញ្ចប់

ម្ចាស់បំណុលត្រូវផ្ញើប្រាក់ចំនួន ៨.០០០.០០០ រៀល (ប្រាំបីលានរៀល) ជាប្រាតិភោគសម្រាប់កូនបំណុល នៅត្រឹមថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០៧ ។

ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៧

សាលាដំបូងក្រុងភ្នំពេញ

ចៅក្រម **ឧត្តម បញ្ញា**

# បញ្ជីឈ្មោះភាគី

**ម្ចាស់បំណុលៈ** **ខៀវ អាត** អាយុ ៤៦ ឆ្នាំ

អត្តសញ្ញាណប័ណ្ណលេខៈ ១១១១

អសយដ្ឋានៈ ផ្ទះលេខ ១២ សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុលៈ** **មាស ពេជ្រ** (មេធាវី)

អាសយដ្ឋានៈ ផ្ទះលេខ xxx, 00 ក្រុង ភ្នំពេញ (អសយដ្ឋានដែលត្រូវធ្វើការបញ្ជូន)

ទូរស័ព្ទលេខៈ 0២៣-###-###

**កូនបំណុលៈ** **សុក បូរ៉ា** អាយុ ៤៦ ឆ្នាំ

អត្តសញ្ញាណប័ណ្ណលេខៈ ២២២២

អសយដ្ឋានៈ ផ្ទះលេខ ៣៤ សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ

# បញ្ជីសិទ្ធិលើបំណុលដែលទាមទារ

ចំនួនទឹកប្រាក់: ៨.០០០ដុល្លារ ( ប្រាំបីពាន់ដុល្លារ)

សិទ្ធិលើបំណុលដែលទាមទារឱ្យសងប្រាក់ដែលត្រូវបានឱ្យចុងចម្លើយខ្ចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគរវាងដើមចោទ និង ចុងចម្លើយ ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៤។ កាលបរិច្ឆេទកំណត់សងគឺថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៦។

ទម្រង់លេខ ១ (ទាក់ទងនឹងមាត្រា ៥ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)

## (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

| | |
|---|---|
| ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧ | បញ្ញើលេខ : ០៧ ឆ្នាំ ២០០៧ |
| ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :<br>សាលាដំបូងក្រុងភ្នំពេញ | ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍<br>តុលាការ : សាលាដំបូងក្រុងភ្នំពេញ<br>សំណុំរឿងលេខ : ០៩ ឆ្នាំ ២០០៧<br>(ឈ្មោះនៃរឿងក្ដី) រឿងក្ដីនៃការរឹបអូសជាបណ្ដោះ អាសន្នចំពោះអចលនវត្ថុ<br>(ភាគីពាក់ព័ន្ធ):<br>ម្ចាស់បំណុល: ខៀវ អាត<br>កូនបំណុល: សុក បូរ៉ា |
| ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ : ***ខៀវ អាត***<br>*អាសយដ្ឋានផ្ទះលេខ ១២ សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ*<br>ភេទ: *ប្រុស*<br>ថ្ងៃខែឆ្នាំកំណើត:<br>អាសយដ្ឋាន ឬទីតាំងទីស្នាក់ការចម្បង:<br>ហត្ថលេខា ឬស្នាមមេដៃ : ហត្ថលេខារបស់ ខៀវ អាត<br>(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិ) : *មាស ពេជ្រ*<br>(អាសយដ្ឋាន) : XX, 00 ក្រុងភ្នំពេញ<br>(ហត្ថលេខា ឬស្នាមមេដៃ): ហត្ថលេខារបស់ មាស ពេជ្រ | អង្គហេតុដែលជាមូលហេតុនៃការផ្ញើ<br>☐ ១. ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី<br>☐ ២. ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន<br>☐ ៣. ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន<br>☐ ៤. ធានានូវការបង្អង់នូវការអនុវត្តដោយបង្ខំ<br>☐ ៥. ធានានូវការលុបចោលនូវការអនុវត្តដោយបង្ខំ<br>☐ ៦. ធានានូវការបន្តនូវការអនុវត្តដោយបង្ខំ<br>☑ ៧. ធានានូវការរឹបអូសជាបណ្ដោះអាសន្ន<br>☐ ៨. ធានានូវការចាត់ចែងជាបណ្ដោះអាសន្ន<br>☐ ៩. ធានានូវការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន<br>☐ ១០. ប្រាក់លុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន<br>☐ ១១. ( )<br><br>(សូមគូស ☑ នៅមុខលេខសមស្រប) |
| ឈ្មោះអ្នកមានសិទ្ធិទទួលការផ្ញើ: សុក បូរ៉ា<br>ឈ្មោះអ្នកតំណាងនីតិបុគ្គល:<br>អាសយដ្ឋាន ឬទីតាំងនៃទីស្នាក់ការចម្បង: ផ្ទះលេខ ៣៤ សង្កាត់ផ្សារកណ្ដាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ | |
| បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>*មាត្រា ៥៤២ និង មាត្រា ៧១ កថាខណ្ឌទី១_នៃក្រមនីតិវិធីរដ្ឋប្បវេណី* | ផ្សេងៗ |
| ទឹកប្រាក់ផ្ញើ (ឯកតា : រៀល)<br>(ហាមកែ ឬ កោសលុប) | ៨ ០ ០ ០ ០ ០ ០ |
| សរសេរជាអក្សរ | ប្រាំបីលានរៀល |

បានទទួលការផ្ញើដូចខាងលើនេះ ។

បានទទួលប្រាក់បញ្ញើដូចខាងលើនេះ ។

ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧
តុលាការ : សាលាដំបូងក្រុងភ្នំពេញ

ក្រឡាបញ្ជី : **ម៉ា វិទូ**

( កំណត់ )

១ ក្នុងករណីដែលធ្វើការធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ ម្ចាស់សិទ្ធិទេ

## ព្រះរាជាណាចក្រកម្ពុជា

សាលាដំបូងរាជធានីភ្នំពេញ **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ ០៨ ឆ្នាំ ២០០៧**

## ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

### យើង ឧត្តម បញ្ញា ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ៖

-បានឃើញក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស / រកម / ០៧០៦ / ២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៦ ។

-បានឃើញសំណុំរឿងរក្សាការពារលេខ ០៩ ឆ្នាំ ២០០៧

-បានឃើញពាក្យសុំដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី ០៤-០១-២០០៧ ។

**កម្មវត្ថុ:** សុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដូចមាននៅក្នុងបញ្ជីឯកសារ ស្តីពីអចលនវត្ថុភ្ជាប់មកជាមួយ ។

- **ភាគី:** ដូចមានពិពណ៌នានៅក្នុងឯកសារភ្ជាប់ស្តីពី ភាគី

- **សិទ្ធិលើបំណុលដែលទាមទារ:** ដូចមានពិពណ៌នានៅក្នុងឯកសារភ្ជាប់ស្តីពី សិទ្ធិលើបំណុល

- បានឃើញរបាយការណ៍ស្តីពីប្រាក់តំកល់( ប្រាតិភោគ)ចំនួន ៨.០០០.០០០ រៀល

### សំអាងហេតុ

តាមលិខិតនៃកិច្ចសន្យាខ្ចីបរិភោគរវាងឈ្មោះ ខៀវ អាត និងឈ្មោះ សុក បូរា ឃើញថា ឈ្មោះ សុក បូរា បានខ្ចីប្រាក់ពីឈ្មោះ ខៀវ អាត ចំនួន ៨០០០ ដុល្លា នៅថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០៤ ដែលអាចបង្ហាញឱ្យឃើញពីអត្ថិភាពនៃសិទ្ធិលើបំណុល ដែលមានគោលបំណងសងជាប្រាក់រវាងម្ចាស់បំណុល និងកូនបំណុល ។

តាមរបាយការណ៍បំភ្លឺរបស់ម្ចាស់បំណុល ខៀវ អាត បង្ហាញឱ្យឃើញថា កូនបំណុលឈ្មោះ សុក បូរា មានជំពាក់បំណុលគេជាច្រើនទៀត ដែលជាហេតុនាំឱ្យមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។

តាមលិខិតយថាភូត នៃការចុះបញ្ជីអចលនវត្ថុដែលម្ចាស់បំណុលផ្តល់ជូនតុលាការឃើញថា កម្ម-វត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុមានភាពច្បាស់លាស់ ហើយជាកម្មសិទ្ធិរបស់កូនបំណុលឈ្មោះ សុក បូរ៉ា ។

## ហេតុដូច្នេះសម្រេច

១-រឹបអូសជាបណ្តោះអាសន្ននូវអចលនវត្ថុរបស់កូនបំណុលឈ្មោះ **សុក បូរ៉ា** ដូចមានក្នុងបញ្ជីអំពី អចលនវត្ថុភ្ជាប់មកជាមួយ ។

២-ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននេះ កូនបំណុលត្រូវផ្ញើប្រាក់តម្កល់នៅតុលាការចំនួន ៨០០០ ដុល្លា ( ប្រាំបីពាន់) ជាប្រាក់រំដោះ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល ។

ដីកាសំរេចរឹបអូសនេះ យោងតាមមាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីអាចដាក់ពាក្យសុំតវ៉ា បាន ។

ថ្ងៃទី ៩ ខែ មករា ឆ្នាំ២០០៧

**ចៅក្រម**

**ឧត្តម បញ្ញា**

# បញ្ជីឈ្មោះភាគី

**ម្ចាស់បំណុលៈ ខៀវ អាត** អាយុ ៤៦ ឆ្នាំ

អត្តសញ្ញាណប័ណ្ណលេខៈ ១១១១

អសយដ្ឋានៈ ផ្ទះលេខ ១២ សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់ម្ចាស់បំណុលៈ មាស ពេជ្រ** (មេធាវី)

អាសយដ្ឋានៈ ផ្ទះលេខ xxx, 00 ក្រុង ភ្នំពេញ (អសយដ្ឋានដែលត្រូវធ្វើការបញ្ជូន)

ទូរស័ព្ទលេខៈ 0២៣-###-###

**កូនបំណុលៈ សុក បូរ៉ា** អាយុ ៤៦ ឆ្នាំ

អត្តសញ្ញាណប័ណ្ណលេខៈ ២២២២

អសយដ្ឋានៈ ផ្ទះលេខ ៣៤ សង្កាត់ ផ្សារកណ្ដាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ

# បញ្ជីសិទ្ធិលើបំណុលដែលទាមទារ

ចំនួនទឹកប្រាក់: ៨.០០០ដូល្លារ (ប្រាំបីពាន់ដូល្លារ)

សិទ្ធិលើបំណុលដែលទាមទារឱ្យសងប្រាក់ដែលបានឱ្យចុងចម្លើយខ្ចី ដោយផ្អែកលើ កិច្ចសន្យា ខ្ចីបរិភោគរវាងដើមចោទ និង ចុងចម្លើយ ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៤។ កាលបរិច្ឆេទនៃការកំណត់សងគឺ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៦។

## បញ្ជីអចលនវត្ថុ

ទីតាំង ផ្ទះលេខ ៣៤ សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ

លេខ 000

ប្រភេទនៃដី ជាតំបន់សម្រាប់រស់នៅ

ទំហំ:.........ម៉ែត្រការេ

សមាសភាពនៃដីខាងលើ: ជាអាគារ (ផ្ទះ)

ប្រភេទនៃផ្ទះ: សម្រាប់លំនៅដ្ឋាន

លក្ខណៈនៃអាគារ: ធ្វើពីថ្ម

ទំហំអាគារ 00ម$^{២}$

ឧបសម្ព័ន្ធ

## (គំរូ)របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទផ្ញើចេញ : ថ្ងៃទី .៩ ខែ មករា ឆ្នាំ ២០០៧ |
| លេខសំណុំរឿង : លេខ ០៩ ឆ្នាំ ២០០៧ |
| ឈ្មោះឯកសារដែលត្រូវបានបញ្ជូន : ដីកាសម្រេចស្តីពី ការរឹបអូសជាបណ្តោះអាសន្ន |
| ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : ស៊ឹង សូរិយា ( ក្រឡាបញ្ជី) |
| អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : ផ្ទះលេខ XX,00 ក្រុង ភ្នំពេញ |
| ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: មាស ពេជ្រ |

**ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង** :ហត្ថលេខា ( *មាស ពេជ្រ*)

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី )

| | |
|---|---|
| ទីកន្លែងដែលបានធ្វើការបញ្ជូន : សាលាដំបូងក្រុងភ្នំពេញ ផ្ទះលេខ ៣១ ផ្លូវ មនីរ៉េត ( ផ្លូវលេខ ២១៧) កាច់ជ្រុងផ្លូវ ២១៣ | |
| កាលបរិច្ឆេទនៃការបញ្ជូន : ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧ ម៉ោង ១០ ព្រឹក | |
| **វិធីជាក់ស្តែងក្នុងការបញ្ជូន** | |
| ☑ ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | ☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ |
| ☐ ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ |
| | ☐ អ្នកបម្រើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | ឈ្មោះ : |
| ☐ ៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ<br>☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ : |
| ☑ **ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ** | |
| ☐ **ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះឡើយ** | |
| កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧ | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍ : ស៊ឹង សូរិយា ហត្ថលេខា ( ស៊ឹង សូរិយា) | |

**កំណត់សំគាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូន :**

១. ប្រសិនបើជនដែលទទួលឯកសារជាក់ស្តែង (ជនដែលត្រូវទទួលការបញ្ជូន ឬ បុគ្គលផ្សេង) មិនចេះ សរសេរ ឬចុះ ហត្ថលេខា ឬមិនអាចផ្តិតម្រាមដៃបានទេ អ្នកប្រតិបត្តិការបញ្ជូនត្រូវចុះនិទ្ទេស ពីការណ៍នោះនៅកន្លែង "**ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង**"

២. "ទីកន្លែងដែលបានធ្វើការបញ្ជូន" ត្រូវតែសរសេរឱ្យបានច្បាស់ៗ និងត្រឹមត្រូវ ។

៣. ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ១ អ្នកបញ្ជូនត្រូវគូស ☑ ហើយប្រសិនបើបានពន្យល់ជូន ពីខ្លឹមសារសង្ខេប ត្រូវគូស ☑ នៅក្នុងប្រអប់ដែរ ។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាម ចំណុចលេខ ២ ត្រូវគូស ☑ នៅក្នុងប្រអប់មុខលេខ ២ ហើយត្រូវបញ្ជាក់ពីបុគ្គលទទួលដោយគូស ☑ នៅក្នុងប្រអប់កំណត់បុគ្គលទទួល និង សរសេរឈ្មោះបុគ្គលដែលបានទទួលនោះផង ។ ប្រសិនបើ ការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ៣ អ្នកបញ្ជូន ត្រូវគូស ☑ នៅក្នុងប្រអប់មុខលេខ ៣ ហើយត្រូវបញ្ជាក់ពីបុគ្គលដែលមិនព្រមទទួលការបញ្ជូន ដោយគ្មានហេតុផលនេះ ដោយការគូស ☑នៅក្នុងប្រអប់កំណត់បុគ្គលដែលមិនព្រមទទួលការបញ្ជូន ហើយត្រូវសរសេរឈ្មោះបុគ្គល ដែល មិនព្រមទទួលការបញ្ជូននោះចូលផង ។

៤. ក្នុងករណីដែលអ្នកធ្វើរបាយការណ៍មិនអាចធ្វើការបញ្ជូនឯកសារបានសម្រេច អ្នកធ្វើរបាយការណ៍នោះ ត្រូវគូស ☑ នៅក្នុងប្រអប់នៅពីមុខឃ្លាដែលសរសេរថា "**ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាង លើនេះបានសម្រេចទេ ពីព្រោះ នៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួល ការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យ ក្នុងការទទួលឯកសារនេះ**" ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*****

# ពាក្យសុំអនុវត្តដីកាសម្រេចរក្សាការពារចំពោះអចលនវត្ថុ

ភ្នំពេញ ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧

ខ្ញុំបាទឈ្មោះ មាស ពេជ្រ ជាមេធាវីតំណាងដោយអាណត្តិរបស់ឈ្មោះ ខៀវ អាត ដូចមានបញ្ជាក់នៅក្នុងបញ្ជីភាគីនៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធ ។

**<u>សូមគោរពចូលមក</u>**
**លោកប្រធានសាលាដំបូងក្រុងភ្នំពេញ**

**កម្មវត្ថុ:** ស្នើសុំអនុវត្តដីកាសម្រេចការពារលេខ ០៩ ឆ្នាំ ២០០៧ ចុះថ្ងៃទី៩ ខែ មករា ឆ្នាំ ២០០៧ របស់សាលាដំបូងក្រុង ភ្នំពេញ ។

**យោង:** មាត្រា ៥៣២ មាត្រា ៥៣៤ ចំណុច ច នៃក្រមនីតិវិធិរដ្ឋប្បវេណី ។

**ភាគី:** ដូចមាននៅក្នុងបញ្ជីពិពណ៌នាអំពីភាគីដែលមានភ្ជាប់មកជាមួយ ។

**សិទ្ធិលើបំណុលដែលបាននាមទារ:** ដូចមាននៅក្នុងបញ្ជីពិពណ៌នាអំពីសិទ្ធិលើបំណុលដែលមានភ្ជាប់មកជាមួយ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនលោកប្រធានសាលាដំបូងក្រុងភ្នំមេត្តាជ្រាបថា:

ខ្ញុំបាទបានទទួលដីកាសម្រេចរក្សាការពារលេខ ០៩ ឆ្នាំ ២០០៧ ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ២០០៧ របស់សាលាដំបូងក្រុងភ្នំពេញ ។

ដូច្នេះហើយខ្ញុំសូមអោយលោកប្រធានសាលាដំបូង អនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុរបស់កូនបំណុល ដូចមានបង្ហាញនៅក្នុងបញ្ជីពិពណ៌នាអំពីអចលនវត្ថុដែលមានភ្ជាប់មកជាមួយ ដោយផ្អែកលើខ្លឹមសារសេចក្តីសំរេចដីកាសម្រេចរក្សាការពារលេខ ០៩ ឆ្នាំ ២០០៧ ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧ របស់សាលាដំបូងក្រុងភ្នំពេញ ដើម្បីអោយការិយាល័យជំនាញសុរិយោដីធ្វើការចុះបញ្ជីកត់ត្រាអំពី អចលនវត្ថុដែលត្រូវបានរឹបអូសបណ្តោះអាសន្ន ។

សេចក្តីដូចបានគោរព និងជំរាបជូនខាងលើ សូមលោកប្រធានទទួលនូវពាក្យសុំអនុវត្តរបស់ខ្ញុំ ដោយអនុគ្រោះ។

ហត្ថលេខា និងត្រា

**មាស ពេជ្រ**

<u>ឯកសារភ្ជាប់មកជាមួយ</u>

-លិខិតចំលងយថាភូតនៃដីកាសំរេចរក្សាការពារ ១ ច្បាប់

-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ១ ច្បាប់

## បញ្ជីឈ្មោះភាគី

ម្ចាស់បំណុលៈ ខៀវ អាត អាយុ ៤៦ ឆ្នាំ

អាស័យដ្ឋានៈ ផ្ទះលេខ ១២ សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ

អត្តសញ្ញាណប័ណ្ណលេខ ១១១

អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល មាស ពេជ្រ (មេធាវី)

អាស័យដ្ឋានៈ លេខ XX,00 ភ្នំពេញ (កន្លែងដែលត្រូវធ្វើការបញ្ជូន)

លេខទូរស័ព្ទៈ0២៣-###-###

កូនបំណុលៈ សុខ បូរា អាយុ ៤៦ ឆ្នាំ អត្តសញ្ញាណប័ណ្ណលេខ ២២២២

អាស័យដ្ឋានៈ លេខ ៣៤ សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ។

# បញ្ជីសិទ្ធិលើបំណុលដែលទាមទារ

ទឹកប្រាក់ចំនួន ៨០០០ដូល្លារ ( ប្រាំបីពាន់ដូល្លារ)

សិទ្ធិលើបំណុលដែលទាមទារឱ្យសងប្រាក់ដែលដើមចោទបានឱ្យចុងចំលើយខ្ចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដែលបានបង្កើតឡើងរវាង ដើមចោទ និងចុងចំលើយនៅថ្ងៃ ០១ ខែ មិថុនា ឆ្នាំ ២០០៤ កាលបរិច្ឆេទនៃការសង គឺនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦។

# **បញ្ជីអចលនវត្ថុ**

ទីតាំង ផ្ទះលេខ ៣៤ សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ

លេខ 000

ប្រភេទនៃដី ជាតំបន់សម្រាប់រស់នៅ

ទំហំ.........ម៉ែត្រការេ

សមាសភាពនៃដីខាងលើៈ ជាអាគារ (ផ្ទះ)

ប្រភេទនៃផ្ទះៈ សម្រាប់លំនៅដ្ឋាន

លក្ខណៈនៃអាគារៈ ធ្វើពីថ្ម

ទំហំអាគារ 00ម$^{២}$

# ឯកសារចម្លងយថាភូត នៃដីកាសម្រេច
# រឹបអូសជាបណ្តោះអាសន្ន

(លុបចោល)

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ថ្ងៃទី ២ ខែមករា ឆ្នាំ២០០៧

អាសយដ្ឋាន : No. 12 ផ្លូវលេខ 00 សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ
អាណត្តិទាយក : ខៀវអាត អត្តសញ្ញាណបណ្ណលេខ : ១១១១

តាមរយៈលិខិតនេះ ខ្ញុំសូមតែងតាំងមេធាវីខាងក្រោមនេះ ឱ្យធ្វើជាតំណាងដោយអាណត្តិរបស់ខ្ញុំ ព្រមទាំងប្រគល់សិទ្ធិបំពេញកិច្ចការខាងក្រោម ដែលពាក់ព័ន្ធទៅនឹងរឿងក្តីនេះ :

មេធាវី : មាស ពេជ្រ
អាសយដ្ឋាន : ××,○○, ភ្នំពេញ
ទូរស័ព្ទ : ០២៣-###-###
ទូរសារ : 000-000-111

ការពិពណ៌នា

I. រឿងក្តី :

1. ភាគីម្ខាងទៀត
   កូនបំណុល : សុក បូរ៉ា
2. តុលាការ :
   សាលាដំបូងក្រុងភ្នំពេញ
3. សញ្ញាណនៃរឿងក្តី :
   រឿងក្តីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុរបស់កូនបំណុល ដោយម្ចាស់បំណុល

II. ចំណុចដែលអាណត្តិ

1. សិទ្ធិអំណាចពេញលេញក្នុងការធ្វើសកម្មភាពតំណាងឱ្យម្ចាស់បំណុល
2. ការដាក់ពាក្យបណ្តឹងតប
3. ការដកពាក្យបណ្តឹង ការផ្សះផ្សា ការបោះបង់ឬការទទួលស្គាល់ការទាមទារ ឬ ការចូលរួមអន្តរាគមន៍ក្នុង បណ្តឹង
4. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ ឬ ពាក្យបណ្តឹងតវ៉ា ឬការដកពាក្យបណ្តឹងទាំងនេះ
5. ការតែងតាំងអនុតំណាង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

# លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជី

ភ្នំពេញ ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧

ខ្ញុំឈ្មោះ **ម៉េង តារ៉ា** ជាក្រឡាបញ្ជីនៃសាលាតំបូងក្រុងភ្នំពេញ

**ជូនចំពោះប្រធានមន្ទីរការិយាល័យសុរិយោដី ខណ្ឌ ដូនពេញ**

**កម្មវត្ថុ:** ការផ្ទុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន

**សញ្ញាណនៃអចលនវត្ថុ:** ដូចមានបញ្ជាក់នៅក្នុងបញ្ជីស្ដីពី អចលនវត្ថុដែលមានភ្ជាប់មកជាមួយ

**គោលបំណងនៃការចុះបញ្ជី** ការរឹបអូសជាបណ្ដោះអាសន្ន

**មូលហេតុ** ដីកាសំរេចរឹបអូសជាបណ្ដោះអាសន្ន សាលាដំបូងក្រុងភ្នំពេញ រឿងក្ដីលេខ ០៩ ឆ្នាំ ២០០៧ ដែលបានចេញនៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧

ម្ចាស់បំណុលចុះបញ្ជី ឈ្មោះ ខៀវ អាត អាយុ ៤៦ ឆ្នាំ
អត្តសញ្ញាណប័ណ្ណលេខ: ១១១១
អាសយដ្ឋាន : ផ្ទះលេខ ១២ សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ

កូនបំណុលចុះបញ្ជី ឈ្មោះ សុក បូរ៉ា
អត្តសញ្ញាណប័ណ្ណលេខ: ២២២២
អាសយដ្ឋាន : ផ្ទះលេខ ៣៤ សង្កាត់ ផ្សារកណ្ដាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ

ឯកសារដែលភ្ជាប់ជាមួយ លិខិតចម្លងយថាភូតនៃដីកាសម្រេចនៃការរឹបអូសជាបណ្ដោះអាសន្ន

ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧

សាលាតំបូងក្រុងភ្នំពេញ

ក្រឡាបញ្ជី **ម៉េង តារ៉ា**

ពន្ធចុះបញ្ជី xxx រៀល

# បញ្ជីអចលនវត្ថុ

ទីតាំង ផ្ទះលេខ ៣៤ សង្កាត់ ផ្សារកណ្ដាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ

លេខ 000

ប្រភេទនៃដី ជាតំបន់សម្រាប់រស់នៅ

ទំហំ:.........ម៉ែត្រការេ

សមាសភាពនៃដីខាងលើ: ជាអាគារ (ផ្ទះ)

ប្រភេទនៃផ្ទះ: សម្រាប់លំនៅដ្ឋាន

លក្ខណ:នៃអាគារ: ធ្វើពីថ្ម

ទំហំអាគារ 00ម$^{២}$

# ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ នៃសៀវភៅ
# ចុះបញ្ជីអំពី ការរើបអូសជាបណ្ដោះអាសន្ន

(លុបចោល)

# (គំរូ)របាយការណ៍អំពីការបញ្ជូន

## ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទផ្ញើចេញ : ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧ |
| លេខសំណុំរឿង : លេខ ០៩ ឆ្នាំ ២០០៧ |
| ឈ្មោះឯកសារដែលត្រូវបានបញ្ជូន : ដីកាសម្រេចស្តីពី ការរឹបអូសជាបណ្តោះអាសន្ន |
| ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : **នេង សុភ័ក្រ** |
| អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : ផ្ទះលេខ ៣៤ សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ |
| ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: សុក បូរ៉ា |

**ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង** :ហត្ថលេខា ( គ្រឿង បុប្ផា)

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី )

| | |
|---|---|
| ទីកន្លែងដែលបានធ្វើការបញ្ជូន : ផ្ទះលេខ ៣៤ សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ | |
| កាលបរិច្ឆេទនៃការបញ្ជូន : ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៧ ម៉ោង ១២ ថ្ងៃត្រង់ | |
| **វិធីជាក់ស្តែងក្នុងការបញ្ជូន** | |
| ☐ ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | ☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ |
| ☑ ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ |
| | ☐ អ្នកបម្រើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☑ អ្នកនៅជាមួយ |
| | ឈ្មោះ : |
| ☐ ៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ<br>☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ : |
| ☑ **ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ** | |
| ☐ **ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះឡើយ** | |
| កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៧ | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍ : នេង សុភ័ក្រ្ត ហត្ថលេខា ( នេង សុភ័ក្រ្ត) | |

**កំណត់សំគាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូន :**

១. ប្រសិនបើជនដែលទទួលឯកសារជាក់ស្តែង (ជនដែលត្រូវទទួលការបញ្ជូន ឬ បុគ្គលផ្សេង) មិនចេះសរសេរ ឬចុះហត្ថលេខា ឬមិនអាចផ្តិតស្រាមដៃបានទេ អ្នកប្រតិបត្តិការបញ្ជូនត្រូវចុះនិទ្ទេសពីការណ៍នោះនៅកន្លែង **"ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង"**

២. "ទីកន្លែងដែលបានធ្វើការបញ្ជូន" ត្រូវតែសរសេរឱ្យបានច្បាស់ៗ និងត្រឹមត្រូវ ។

៣. ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ១ អ្នកបញ្ជូនត្រូវគូស ☑ ហើយប្រសិនបើបានពន្យល់ជូនពីខ្លឹមសារសង្ខេប ត្រូវគូស ☑ នៅក្នុងប្រអប់ដែរ។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ២ ត្រូវគូស ☑ នៅក្នុងប្រអប់មុខលេខ ២ ហើយត្រូវបញ្ជាក់ពីបុគ្គលទទួលដោយគូស ☑ នៅក្នុងប្រអប់កំណត់បុគ្គលទទួល និង សរសេរឈ្មោះបុគ្គលដែលបានទទួលនោះផង។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ៣ អ្នកបញ្ជូនត្រូវគូស ☑ នៅក្នុងប្រអប់មុខលេខ ៣ ហើយត្រូវបញ្ជាក់ពីបុគ្គលដែលមិនព្រមទទួលការបញ្ជូន ដោយគ្មានហេតុផលនេះ ដោយការគូស ☑នៅក្នុងប្រអប់កំណត់បុគ្គលដែលមិនព្រមទទួលការបញ្ជូន ហើយត្រូវសរសេរឈ្មោះបុគ្គល ដែលមិនព្រមទទួលការបញ្ជូននោះចូលផង ។

៤. ក្នុងករណីដែលអ្នកធ្វើរបាយការណ៍មិនអាចធ្វើការបញ្ជូនឯកសារបានសម្រេច អ្នកធ្វើរបាយការណ៍នោះត្រូវគូស ☑នៅក្នុងប្រអប់នៅពីមុខឃ្លាដែលសរសេរថា " **ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេពីព្រោះ នៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យ ក្នុងការទទួលឯកសារនេះ**"។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

**ពាក្យសុំលុបចោលប្រាតិភោគ**

**គោរពជូន លោកប្រធានសាលាដំបូងក្រុងភ្នំពេញ**

ពីអ្នកតំណាងដោយអាណត្តិរបស់អ្នកដាក់ពាក្យសុំ

អ្នកដាក់ពាក្យសុំ (ម្ចាស់បំណុល)

ឈ្មោះ ខៀវ អាត ភេទ ប្រុស អាយុ ៤៦ ឆ្នាំ

អាស័យដ្ឋានៈ ផ្ទះលេខ ១២ សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ

អ្នកតំណាងដោយអាណត្តិ

ឈ្មោះ មាស ពេជ្រ មេធាវី ភេទប្រុស អាយុ៤៦

អាស័យដ្ឋានៈ ផ្ទះលេខ .xx ផ្លូវ 00 ភ្នំពេញ (ទូរស័ព្ទ) ០២៣-###-###

ភាគីម្ខាងទៀត (កូនបំណុល)

ឈ្មោះ សុខ បូរា ភេទ ប្រុស អាយ ៤៦

អាស័យដ្ឋានៈ ផ្ទះ លេខ ៣៤ សង្កាត់ផ្សារកណ្តាល ខណ្ឌ ដូនពេញ ភ្នំពេញ

**ចំណុចចម្បង និងមូលដ្ឋានសំរាប់ពាក្យសុំ**

យោងតាមប្រាតិភោគដែលអ្នកដាក់ពាក្យសុំ (ម្ចាស់បំណុល) បានដាក់ទាក់ទងនឹង រឿងក្តីស្តីពី (ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ) មូលដ្ឋានសំរាប់ការដាក់ប្រាតិភោគត្រូវបានរលត់ ដោយសារតែ តុលាការបានចេញសាលក្រមឱ្យអ្នកដាក់ពាក្យសុំឈ្នះបណ្តឹងអង្គសេចក្តី ហើយសាលក្រមនោះបានចូលជាស្ថាពរបន្ទាប់ពី ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០០៧។

ហេតុដូច្នេះហើយ ខ្ញុំបាទ / នាងខ្ញុំសំណូមពរឱ្យតុលាការចេញដីកាសំរេចលុបចោលប្រាតិភោគនេះ។

-កាលបរិច្ឆេទនៃការដាក់ប្រាតិភោគៈ ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧

-ទីកន្លែងនៃការដាក់ប្រាតិភោគៈ នៅសាលាដំបូងក្រុងភ្នំពេញ

-លេខដាក់ប្រាតិភោគៈ ឆ្នាំ ២០០៧ លេខ ០៧។

-ចំនួនទឹកប្រាក់ដែលបានដាក់ប្រាតិភោគៈ ៨ លាន រៀល

ឯកសារដែលភ្ជាប់មកជាមួយ

១/ អនុសារសាលក្រម ចំនួន ១ច្បាប់

២/លិខិតបញ្ជាក់អំពីហេតុដែលសាលក្រមបានចូលជាស្ថាពរ ចំនួន១ច្បាប់

អាស្រ័យដូចបានជំរាប និងភ្ជាប់ជូនខាងលើ សូមតុលាការមេត្តាចេញដីកាសំរេចលុបចោលនូវប្រាតិភោគតាមពាក្យសុំដោយក្តីអនុគ្រោះ។

ធ្វើនៅសាលាដំបូងក្រុងភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នំ ២០០៧

អ្នកតំណាងដោយអាណត្តិរបស់អ្នកដាក់ពាក្យសុំ

មេធាវី

ឈ្មោះ **មាស ពេជ្រ**

# អនុសារសាលាក្រម នៃបណ្ដឹងអន្តរសេចក្ដី ដែលសម្រេចឱ្យម្ចាស់បំណុលឈ្នះក្ដី

## (លុបចោល)

# លិខិតបញ្ជាក់អំពីហេតុដែលសាលក្រមបានចូលជាស្ថាពរ

# (លុបចោល)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

# ដីកាសម្រេចលុបប្រាតិភោគ

អ្នកដាក់ពាក្យសុំៈ ខៀវ អាត

ភាគីម្ខាងទៀតៈ សុក បូរ៉ា

យោងលើរឿងក្តីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុរវាងភាគីខាងលើ ដែលបានប្តឹងមកតុលាការនៅថ្ងៃទី ៤ ខែមករា ឆ្នាំ ២០០៧ (សាលាដំបូងក្រុងភ្នំពេញ សំណុំរឿងរក្សាការពារលេខ ០៩ ឆ្នាំ ២០០៧) មូលដ្ឋាននៃការដាក់ប្រាតិភោគដែលបានដាក់ ដោយ អ្នកដាក់ពាក្យសុំចំនួន ៨លានរៀល ទៅតុលាការនៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧ (ការដាក់ប្រាតិភោគ ឆ្នាំ ២០០៧ លេខ ០៧) បានរលត់។ ដូច្នេះតុលាការសម្រេចលុបប្រាតិភោគចោល។

ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧

សាលាដំបូងក្រុងភ្នំពេញ

ចៅក្រម **ចែម មករា**

# មាតិកា

## (មេរៀន)

ទំព័រ

**ជំពូកទី ១ ខ្លឹមសារសំខាន់ៗ អំពីការចាត់ចែងរក្សាការពារ.................................... ១**

ផ្នែកទី១ កម្មវត្ថុនៃការចាត់ចែងរក្សាការពារ.............................. ១

ផ្នែកទី២ ប្រភេទនៃការចាត់ចែងរក្សាការពារ............................. ៣

ផ្នែកទី៣ នីតិវិធីរក្សាការចាត់ចែងរក្សាការពារ.......................... ៧

ផ្នែកទី៤ ចរិកលក្ខណៈនៃការចាត់ចែងរក្សាការពារ.......................... ៩

**ជំពូកទី ២ ការដាក់ពាក្យសុំ.......................................................... ១៣**

ផ្នែកទី១: របៀបដាក់ពាក្យសុំ.................................... ១៣

ផ្នែកទី២: សមត្ថកិច្ច (មាត្រា៥៤០ មាត្រា៥៣៣)............................ ១៣

ផ្នែកទី៣: ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ(មាត្រា៥៤១ កថាខណ្ឌទី១).... ១៤

៣-១ ឈ្មោះ និង អាសដ្ឋានរបស់ភាគី និងឈ្មោះ និងអាសយដ្ឋាន របស់អ្នកតំណាងដែលច្បាប់បានកំណត់(មាត្រា៥៤១ កថាខណ្ឌទី១ ចំណុច ក)........................................ ១៤

៣-២ ខ្លឹមសារលំអិតនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំ ទាមទារ(មាត្រា៥៤៣ កថាខណ្ឌទី១ ចំណុច ខ មាត្រា ៥៤៦).១៥

៣-៣ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលត្រូវបានរក្សាការពារ(មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច គ មាត្រា៥៤១ កថាខណ្ឌទី២).... ១៥

៣-៤ ភាពចាំបាច់នៃការរក្សាការពារ (មាត្រា៥៤១ កថាខណ្ឌទី ១ ចំណុច ឃ មាត្រា ៥៤១ កថាខណ្ឌទី២)...................... ១៦

៣-៥ ភស្តុតាងតាមហេតុនីមួយៗ (មាត្រា ៥៤១ កថាខណ្ឌទី២).... ១៦

៣-៦ បញ្ជីសារពើភ័ណ្ឌ.................................... ១៦

ផ្នែកទី៤: ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំ ............................ ១៧

៤-១ ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង(មាត្រា៥៤១ កថាខណ្ឌទី៣). ១៧

៤-២ ឯកសារដើម្បីបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ (មាត្រា ៥៣ កថាខណ្ឌទី២)............................ ២០

៤-៣ ឯកសារដើម្បីបញ្ជាក់កម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៤៦)........................................ ២១
៤-៤ ផ្សេងៗ................................................ ២២
ផ្នែកទី៥: សោហ៊ុយ........................................... ២៣
ផ្នែកទី៦: ការបែងចែករឿងក្ដី.................................... ២៣
ផ្នែកទី៧: ការពិនិត្យពាក្យសុំ..................................... ២៤

**ជំពូកទី ៣ ការពិនិត្យរឿងក្ដី.............................................. ២៦**

ផ្នែកទី១ វិធីនៃការពិនិត្យរឿងក្ដី.................................... ២៦
១-១ ការពិនិត្យភស្តុតាងជាឯកសារ........................... ២៦
១-២ ការសួរម្ចាស់បំណុល.................................... ២៦
១-៣ ការសួរកូនបំណុល...................................... ២៧
១-៤ ការទាញហេតុផលដោយផ្ទាល់មាត់......................... ២៨
ផ្នែកទី២ កម្មវត្ថុនៃការពិនិត្យ.......................................... ២៨
២-១ ទំនាក់ទំនងសិទ្ធិ ឬគតិយុត្តិដែលត្រូវបានរក្សាការពារ(មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច គ មាត្រា៥៤១ កថាខណ្ឌទី២)... ២៨
២-២ ភាពចាំបាច់នៃការរក្សាការពារ(មាត្រា៥៤១ កថាខណ្ឌទី១ ចំណុច គ និង មាត្រា៥៤១ កថាខណ្ឌទី២)...................... ២៩
ផ្នែកទី៣ សេចក្ដីបញ្ជាក់តំបូង......................................២៩
ផ្នែកទី៤ ប្រាតិភោគ (មាត្រា ៥៤២)................................. ៣០
៤-១ គោលបំណងនៃប្រាតិភោគ................................ ៣១
៤-២ ចំនួននៃប្រាតិភោគ...................................... ៣១
៤-៣ វិធីនៃការដាក់ប្រាតិភោគ (មាត្រា ៧១ កថាខណ្ឌទី១)....... ៣២

**ជំពូកទី ៤ ដីកាសម្រេច.................................................... ៣៤**

ផ្នែកទី១ ទម្រង់នៃដីកាសម្រេចរក្សាការពារ............................ ៣៤
ផ្នែកទី២ ចំណុចដែលត្រូវសរសេរនៅក្នុងដីកាសម្រេចរក្សាការពារ (មាត្រា៥៤៥. មាត្រា៥៤៦ មាត្រា៥៤៧)................................... ៣៤
២-១ ចំណុចចាំបាច់ដើម្បីបញ្ជាក់រឿងក្ដី............................ ៣៤

២-២ ចំនួនទឹកប្រាក់សម្រាប់ដាក់ប្រាតិភោគ និងវិធីនៃការដាក់ប្រាតិភោគ ៣៥
២-៣ សេចក្តីសម្រេច........................................ ៣៦
២-៤ ការកំណត់ជាក់លាក់នូវកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះ
អាសន្ន (មាត្រា៥៤៦)........................................ ៣៦
២-៥ ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (មាត្រា៥៤៧)......... ៣៧
២-៦ មូលដ្ឋាននៃដីកាសម្រេច........................................ ៣៨
២-៧ បន្ទុកនៃប្រាក់ប្រដាប់ក្តី........................................ ៣៨
ផ្នែកទី៣ ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន........................ ៣៩
៣-១ គោលបំណងនៃប្រាក់រំដោះ........................................ ៣៩
៣-២ ចំនួននៃប្រាក់រំដោះ........................................ ៤០
៣-៣ វិធីនៃការដាក់ប្រាក់រំដោះ........................................ ៤១
ផ្នែកទី៤ ការបញ្ជូនដីកាសម្រេចរក្សាការពារ (មាត្រា៥៤៣)................ ៤១
៤-១ ដីកាសម្រេចបង្គាប់ឱ្យរក្សារការពារ........................................ ៤១
៤-២ ដីកាសម្រេចលើកចោលពាក្យសុំ........................................ ៤២

**ជំពូកទី ៥ ការអនុវត្តការរក្សាការពារ........................................ ៤៣**
ផ្នែកទី១ ស្ថាប័នអនុវត្តដីកាសម្រេចករក្សាការពារ (មាត្រា៥៣២ មាត្រា៥៦៧
កថាខណ្ឌទី២. មាត្រា៥៦៥ និង មាត្រា៥៦៦).................. ៤៣
ផ្នែកទី២ របៀបដាក់ពាក្យសុំអនុវត្តដីកាសម្រេចរក្សាការពារ.................. ៤៤
ផ្នែកទី៣ ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំអនុវត្តដីកាសម្រេចរក្សាការពារ. ៤៤
ផ្នែកទី៤ ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំឱ្យអនុវត្តដីកាសម្រេចរក្សាការពារ.. ៤៦
ផ្នែកទី៥ សោហ៊ុយការអនុវត្តដីកាសម្រេចរក្សាការពារ........................ ៤៧
ផ្នែកទី៦ ការពិនិត្យពាក្យសុំឱ្យអនុវត្តដីកាសម្រេចរក្សារពារ........................ ៤៧
ផ្នែកទី៧ ការពិនិត្យលើលក្ខខណ្ឌចាំបាច់នៃការអនុវត្តដីកាសម្រេចរក្សាការពារ.... ៤៨
៧-១ លិខិតយថាភូតនៃដីកាសម្រេចរក្សាការពារ (មាត្រា៥៦២
កថាខណ្ឌទី ១)........................................ ៤៨
៧-២ អំឡុងពេល (មាត្រា៥៦២ កថាខណ្ឌទី ២)........................ ៤៨
៧-៣ ផ្សេងៗ........................................ ៤៩

ផ្នែកទី៨ វិធីនៃការអនុវត្តដីកាសម្រេចរក្សាការពារ............................ ៤៩

**ជំពូកទី ៦ ការលុបប្រាតិភោគ...................................................... ៥០**

## ជំពូកទី ១ ខ្លឹមសារសំខាន់ៗអំពីការចាត់ចែងរក្សាការពារ

របបរក្សាការពាររដ្ឋប្បវេណីជានីតិវិធីមួយមានលក្ខណៈបណ្តោះអាសន្នដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុល នៅពេលដែលរង់ចាំសាលក្រមចុងក្រោយដែលត្រូវអនុវត្ត។ នៅពេលដែលមានបណ្តឹងអង្គសេចក្តីដែលត្រូវចាត់ការនោះ គឺត្រូវចំណាយពេលវេលាមួយវែងដែលមិនអាចកំណត់បាន ដូច្នេះនៅក្នុងអំឡុងពេលនីតិវិធីអង្គសេចក្តីនេះ ពេលខ្លះម្ចាស់បំណុលអាចបាត់បង់ផលប្រយោជន៍ ដោយសារតែចេតនាទុច្ចរិតរបស់កូន-បំណុលដែលលាក់ទុកទ្រព្យសម្បត្តិ តាមរយៈការផ្ទេរ ការដោះដូរ ការលក់ ការបញ្ចាំ ប្រទានកម្មជាដើម។ល។ ដែលធ្វើឱ្យម្ចាស់បំណុលជួបការលំបាកក្នុងការអនុវត្តសិទ្ធិនៅពេលឈ្នះក្តី។ ដូច្នេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាបានគិតដល់ផលលំបាកនេះហើយក៏បានកំណត់ជាក្បួនច្បាប់ ក្នុងការធ្វើការចាត់ចែងការរក្សារការពារក្នុងគោលបំណងការពារផលប្រយោជន៍របស់ម្ចាស់បំណុលរហូតដល់នីតិវិធីនៃបណ្តឹងត្រូវបានបញ្ចប់ ។

ការចាត់ចែងរក្សាការពារ គឺជាវិធានការមួយមានលក្ខណៈបន្ទាន់បង្ខំ ហើយត្រូវ បានធ្វើឡើង ដោយមានលក្ខណៈសំងាត់ មុនពេលចេញដីកាសម្រេចរក្សាការពារនេះ។ វាជាយន្តការការពារជាបឋមចំពោះផលប្រយោជន៍របស់ម្ចាស់បំណុល។ ការចាត់ចែងរក្សាការពារអាចត្រូវបានចេញមុននីតិវិធីនៃបណ្តឹងអង្គសេចក្តីក៏បាន ឬក្នុងអំឡុងពេលនីតិវិធីនៃបណ្តឹងអង្គសេចក្តីក៏បាន ។

### ផ្នែកទី ១ កម្មវត្ថុនៃការចាត់ចែងរក្សាការពារ

កម្មវត្ថុនៃការរក្សាការពារមាន សិទ្ធិលើបំណុល ឬទ្រព្យសម្បត្តិផ្សេងៗទៀតវត្ថុ និងឋានៈបុគ្គល។

#### ១ សិទ្ធិលើបំណុល

សិទ្ធិលើបំណុលរបស់កូនបំណុលលើកូនបំណុលទី៣ជាប្រភេទសិទ្ធិមួយដែលជាកម្មវត្ថុនៃការចាត់ចែងរក្សាការពារ។ នៅក្នុងករណីនេះតុលាការត្រូវចាត់ចែងរក្សាការពារ(ដោយការរឹបអូសជាបណ្តោះអាសន្ន) ចំពោះសិទ្ធិលើបំណុលរបស់កូនបំណុលទី៣។ ឧទាហរណ៍

ក្នុងករណីដែលកូនបំណុលមានគណនេយ្យធនាគារ ម្ចាស់បំណុលអាចរឹបអូសជាបណ្ដោះអាសន្នលើបំណុលរបស់កូនបំណុលដើម្បីដកប្រាក់ពីធានាគាររបស់គាត់ តាមរយៈតុលា-ការអនុវត្ត ដោយបង្គាប់ទៅធនាគារ (កូនបំណុលទី៣)មិនត្រូវបើប្រាក់ឱ្យកូនបំណុលឡើយ។

**២ វត្ថុ**

វត្ថុនៅក្នុងន័យនេះគឺសំដៅដល់ ចលនវត្ថុ និង អចលនវត្ថុ។ នៅក្នុងករណីដែលមានការបារម្ភណ៍ថាកូនបំណុលអាចនឹងលាក់បាំង ឬផ្ទេរនូវទ្រព្យរបស់ខ្លួនដែលជាចលន-វត្ថុ ឬអចលនវត្ថុនោះ តុលាការអាចចេញដីកាសម្រេចចាត់ចែងរក្សាការពារតាមពាក្យសុំរបស់ម្ចាស់បំណុលដើម្បីធ្វើការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុនោះបាន។ នៅក្នុងន័យនេះ វត្ថុដែលនឹងត្រូវបានរក្សាការពារអាចជាវត្ថុដែលជាកម្មវត្ថុនៃវិវាទ ឬអាចជាវត្ថុមួយផ្សេងទៀតរបស់កូនបំណុលដែលត្រូវបានចាត់ចែងរក្សាការពារទុកសម្រាប់ធ្វើការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលនៅពេលក្រោយ។

**៣ ឋានៈបុគ្គល**

ឋានៈបុគ្គលពាក់ព័ន្ធនឹងការចាត់ចែងរក្សាការពារនេះគឺជាឋានៈរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលតុលាការសម្រេចចេញជាដីកាសម្រេចរក្សាការពារ ដើម្បីកំណត់ជាបណ្ដោះអាសន្ននូវឋានៈរបស់បុគ្គល។ ពេលខ្លះនៅពេលមានបណ្ដឹងមួយត្រូវបានកំពុងចាត់ការវាមានការលំបាកក្នុងការកំណត់សិទ្ធិរបស់ម្ចាស់បំណុល ដូច្នេះចាំបាច់ត្រូវកំណត់នូវឋានៈរបស់បុគ្គលជាបណ្ដោះអាសន្នសិនដើម្បីបន្តឱ្យមាននិរន្តភាពនៃដំណើការរឿងក្ដីរបស់គូភាគី ។ បើមិនកំណត់ឋានៈជាបណ្ដោះអាសន្នទេ ពេលខ្លះទាំងតុលាការ ទាំងគូភាគីនឹងជួបការលំបាកក្នុងការបន្តនីតិវិធីនៃបណ្ដឹងឱ្យទៅមុខទៀត។ វាជាការកំណត់ជាបណ្ដោះអាសន្ននូវឋានៈរបស់ភាគី ប្រសិនបើមិនកំណត់ឋានៈជាបណ្ដោះអាសន្នទេ នោះវានឹងធ្វើឱ្យភាគីម្ខាងដែលដាក់ពាក្យសុំឱ្យកំណត់ឋានៈនោះនឹងទទួលរងនូវការខូចខាតផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ។ ករណីនេះវាហាក់ដូចជាការសន្មត់ទុកជាមុនថា អ្នកដាក់ពាក្យសុំដើម្បីកំណត់ឋានៈរបស់ខ្លួនថាខ្លួនមានសិទ្ធិអ្វីមួយនោះ គឺពិតជាមានសិទ្ធិនោះមែន ហើយតុលាការត្រូវសម្រេចកំណត់ជាបណ្ដោះអាសន្ននូវសិទ្ធិនោះ ដើម្បីឱ្យភាគីដែលដាក់ពាក្យសុំអាចអនុវត្ត

សិទ្ធិនោះជាបណ្តោះអាសន្នរហូតដល់តុលាការកំណត់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិរបស់ភាគីនៅពេលក្រោយបាន ។

ចំពោះករណីនេះ នឹងមានឧទាហរណ៍នៅក្នុងផ្នែកខាងក្រោយទៀត។

## ផ្នែកទី ២ ប្រភេទនៃការចាត់ចែងរក្សាការពារ

- **ការរឹបអូសជាបណ្តោះអាសន្ន**

ការរឹបអូសជាបណ្តោះអាសន្ន គឺជាវិធានការមួយដើម្បីការពារជាបណ្តោះអាសន្ននូវសិទ្ធិរបស់ម្ចាស់បំណុល។

ការរឹបអូសជាបណ្តោះអាសន្នអាចអនុវត្តបានចំពោះវត្ថុផ្សេងទៀតដែលជាទ្រព្យរបស់កូនបំណុលដើម្បីចៀសវាងនូវចេតនាទុច្ចរិតរបស់កូនបំណុលដែលអាចធ្វើឱ្យទ្រព្យផ្សេងនោះបាត់បង់ ដោយការលក់ឱ្យតតិយជនជាដើម។ល។

ការរឹបអូសជាបណ្តោះអាសន្នអាចធ្វើបានចំពោះ ចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើបំណុល។

- **ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ**

ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាវិធានការមួយដើម្បីការពារ ការខូចខាតដែលអាចកើតឡើងផ្ទាល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ។ ជានីតិវិធីដើម្បីរក្សារការពារវត្ថុដែលជាកម្មវត្ថុនៃវិវាទ។ ក្នុងករណីនេះ បើម្ចាស់បំណុលមិនបានគិតដល់ការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះទេ គឺវាបណ្តាលឱ្យមានការលំបាកនៅពេលឈ្នះក្តី។ ប៉ុន្តែប្រសិនបើម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យតុលាការធ្វើការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុ ដែលជាកម្មវត្ថុនៃវិវាទនោះគឺថាការខូចខាតដែលអាចកើតមាន វានឹងមិនកើតមាននោះទេ ទោះបីជាកូនបំណុលធ្វើការផ្ទេរ ឬលក់វត្ថុដែលកម្មវត្ថុនៃចំណុចវិវាទទៅអ្នកដទៃក៏ដោយ ពីព្រោះវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះត្រូវបានចាត់ចែងជាបណ្តោះអាសន្នរួចហើយ ទោះជានៅក្រោយពេលធ្វើការចាត់ចែងជាបណ្តោះអាសន្ននោះ កូនបំណុលបានយកវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះទៅផ្ទេរ ឬក៏លក់ដូរជាដើម។ល។ ក៏ដោយ ក៏នៅពេលឈ្នះក្តី គឺម្ចាស់បំណុលនៅតែអាចអនុវត្តសិទ្ធិរបស់គាត់បាន លើវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ។

## ៤. ការចាត់ចែងជាបណ្ដោះអាសន្នដើម្បីកំណត់ឋានៈជាបណ្ដោះអាសន្ន

ការចាត់ចែងជាបណ្ដោះអាសន្នដើម្បីកំណត់ឋានៈជាបណ្ដោះអាសន្ននេះ ជានីតិវិធីមួយដើម្បីកំណត់ជាបណ្ដោះអាសន្ននូវឋានៈរបស់ភាគីដែលដាក់ពាក្យសុំទំរាំនីតិវិធីនៃបណ្ដឹងត្រូវបានបញ្ចប់។ ជាវិធានការមួយដើម្បីចៀសវាងនូវការខូចខាតធ្ងន់ធ្ងរ ដោយសារការយឺតយ៉ាវក្នុងការកំណត់សិទ្ធិ។ វាជានីតិវិធីដ៏សំខាន់ដើម្បីកំណត់នូវសិទ្ធិរបស់អ្នកដាក់ពាក្យសុំដើម្បីឱ្យគាត់បន្តនីតិវិធីនៃបណ្ដឹងអង្គសេចក្ដី។ ជានីតិវិធីមួយចាំបាច់សម្រាប់កំណត់ជាបណ្ដោះអាសន្ននូវសិទ្ធិណាមួយរបស់អ្នកដាក់ពាក្យសុំ ដើម្បីឱ្យអ្នកដាក់ពាក្យសុំនោះមានលទ្ធភាពបន្តនីតិវិធីនៃបណ្ដឹងបាន។ ក្នុងករណីដែលតុលាការមិនបានកំណត់ជាបណ្ដោះអាសន្ននូវឋានៈនេះទេ ភាគីដែលដាក់ពាក្យសុំនឹងជួបការលំបាកក្នុងការតតាំងក្ដីជាមួយភាគីម្ខាងទៀត។ ការកំណត់ជាបណ្ដោះអាសន្ននូវឋានៈនេះគ្រាន់តែជាការផ្ដល់ឱ្យភាគីដែលដាក់ពាក្យសុំនូវលទ្ធភាពមួយ ឬច្រើន ដើម្បីធ្វើយ៉ាងណាកុំឱ្យភាគីដែលដាក់ពាក្យសុំជួបនូវការខូចខាតយ៉ាងធ្ងន់ធ្ងរនៅពេលដែលគាត់ឈ្នះក្ដី។ ប៉ុន្តែផ្ទុយទៅវិញ នៅពេលដែលតុលាការបានសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ននេះហើយ ការខូចខាតរបស់ភាគីដែលដាក់ពាក្យសុំអាចនឹងមិនកើតមានឡើង ឬអាចមានតិចតួចបំផុត ប្រសិនបើតុលាការសម្រេចទាន់ពេលវេលា។

## ✻ ករណីសាមញ្ញៗនៃនីតិវិធីនីមួយៗ (លើកឧទាហរណ៍ជារឿងក្ដី)

### ក/ ការរឹបអូសជាបណ្ដោះអាសន្ន

ឧទាហរណ៍: **ខ** ជំពាក់ប្រាក់ **ក** ចំនួន២០លានរៀល។ **ខ** ជាកូនបំណុលមានប្រាក់នៅធនាគារ **B** ដែលមានតម្លៃប្រហែល២៥លានរៀល។ នៅក្នុងនីតិវិធីនៃបណ្ដឹងទាមទារប្រាក់កំចីនេះ ត្រូវចំណាយពេលវេលាច្រើន ករណីនេះម្ចាស់បំណុល **ក** អាចនឹង បាត់បង់ផលប្រយោជន៍ក្នុងករណីដែល **ខ** បានទៅធនាគារ ហើយដកយកប្រាក់បញ្ញើ ទាំងនោះទៅចំណាយអស់។ ដូច្នេះដើម្បីការពារផលប្រយោជន៍របស់ខ្លួន **ក** ត្រូវដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននូវគណនីធនាគាររបស់ **ខ**

ដើម្បីធានាការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល **ក** នៅពេលគាត់ឈ្នះក្តី។ ដូច្នេះ ក្រោយពេលមានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននូវគណនីធនាគាររបស់ **ខ** ហើយ **ខ** នឹងមិនអាចទៅដកយកប្រាក់បញ្ញើរបស់ខ្លួនបានទៀតទេ ។

## ខ/ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

**ឧទាហរណ៍:** **ក** បានទិញរថយន្តពី **ខ** ក្នុងតម្លៃ ១០លានរៀល។ **ក** បានប្រគល់ប្រាក់គ្រប់ចំនួនឱ្យ **ខ** រួចរាល់អស់ហើយ រង់ចាំតែការផ្ទេរឈ្មោះពី **ខ** មក **ក** និងការប្រគល់រថយន្តប៉ុណ្ណោះ ។ ប៉ុន្តែក្រោយមក ដល់កាលកំណត់ដែលត្រូវប្រគល់រថយន្តហើយ **ខ** បែរជាមិនព្រមប្រគល់ទេ។ **ក** ក៏បានដាក់ពាក្យបណ្តឹងទាមទារឱ្យ **ខ** ប្រគល់រថយន្តមកឱ្យខ្លួនតាមកិច្ចសន្យាទិញ-លក់នោះ។ នៅក្នុងនីតិវិធីនៃបណ្តឹងនេះ តុលាការត្រូវចំណាយពេលច្រើនក្នុងការកំណត់នូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិរបស់ **ក** ដូច្នេះនៅក្នុងកំឡុងពេលនេះ **ខ** អាចនឹងលក់រថយន្តនោះទៅឱ្យតតិយជនផ្សេងទៀត បាន ដែលជាហេតុធ្វើឱ្យ **ក** ខូចខាតផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ដូច្នេះ **ក** ត្រូវដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះរថយន្តនោះ ដើម្បីកុំឱ្យ **ខ** លក់ ឬផ្ទេររថយន្តទៅឱ្យតតិយជនបាន។ តាមរយៈនេះរថយន្តនោះនឹងមិន បាត់បង់ ឬមិនត្រូវបានផ្ទេរទៅឱ្យតតិយជននោះទេ។ ប្រសិនបើ តុលាការរកឃើញនូវ អត្ថិភាពនៃសិទ្ធិរបស់ **ក** លើរថយន្តនោះ**ក** នឹងអាចអនុវត្តសិទ្ធិនេះលើរថយន្តនោះបាន។

## គ/ ការចាត់ចែងជាបណ្តោះអាសន្នដើម្បីកំណត់ឋានៈជាបណ្តោះអាសន្ន

ឧទាហរណ៍: **ក** មានដីមួយឡូត៍ជាកម្មសិទ្ធិរបស់ខ្លួន ក្រោយមកមានឈ្មោះ **ខ** បានមកសាងសង់សំណង់ជាផ្ទះនៅលើដីឡូត៍នោះ។ ដូច្នេះ **ក** គាត់ក៏ដាក់ពាក្យបណ្តឹងអង្គសេចក្តីទៅតុលាការដោយសុំឱ្យរុះរើសំណង់ទាំងនោះចេញ។ នៅក្នុងករណីនេះ **ក** ឈ្នះក្តី **ក** អាចទៅរុះរើសំណង់ទាំងនោះបាន ក៏ប៉ុន្តែវាគ្រាន់តែមានការលំបាកក្នុងការរុះរើ ពីព្រោះសំណង់បានសាង់ជាច្រើន ឬក៏សាងសង់ហើយទាំងស្រុង ។ ដូច្នេះ **ក** ត្រូវ

ដាក់ពាក្យសុំតាំងពីដំបូងដើម្បីហាមឃាត់មិនឱ្យ **ខ** បន្តការសាងសង់ទេ គឺត្រូវបញ្ឈប់ការសាងសង់ត្រឹមនេះ ។ ការស្នើសុំបែបនេះ ប្រសិនបើ **ខ** ទើបតែចាប់ផ្តើមទេ នៅពេលដែល **ក** បានឈ្នះក្តី **ក** នឹងមានភាពងាយស្រួលក្នុងការរុះរើសំណង់ដីតិចតួចទាំងនោះចេញ។ ប្រសិនបើ **ក** មិនបានសុំដូច្នេះទេ នោះ **ក** នឹងជួបការលំបាកដូចបានលើកពីខាងដើមនៃឧទាហរណ៍នេះ ។

ឧទាហរណ៍មួយទៀត៖ **ក** តែងតែធ្វើដំណើរចេញពីផ្ទះតាមផ្លូវតូចដើម្បីទៅដល់ផ្លូវធំ ស្រាប់មានពេលមួយនោះ **ខ** បានមកសាងសង់សំណង់ដោយបិទផ្លូវតូចនោះ។ ករណីនេះ **ក** ត្រូវដាក់ពាក្យសុំទៅតុលាការដើម្បីពិចារណាអំពីការសាងសង់នេះ ដោយសុំឱ្យ តុលាការចេញដីកាសម្រេចហាមឃាត់ ការសាងសង់ជាបណ្តោះអាសន្ន ។

## ✠ ភាពខុសគ្នាក្នុងចំណោមនីតិវិធីខាងលើ

**ការរឹបអូសជាបណ្តោះអាសន្ន៖** ដើម្បីរក្សាការពារសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ហើយវាអាចអនុវត្តបានចំពោះ ចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យ ផ្សេងៗទៀត។

**ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ៖** ដើម្បីរក្សាការពារសិទ្ធិទាមទារដែលពាក់ពន្ធ័នឹងវត្ថុដែលជាកម្មវត្ថុនៃវិវាទក្រៅពីសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។
វាអាចអនុវត្តបានតែចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទតែប៉ុណ្ណោះ ។

**ការចាត់ចែងជាបណ្តោះអាសន្នដើម្បីកំណត់ឋានៈជាបណ្តោះអាសន្ន៖** ដើម្បីចៀសវាងនូវការខូចខាតធ្ងន់ធ្ងរ ដោយសារការយឺតយ៉ាវក្នុងការកំណត់សិទ្ធិ។ វាជាការកំណត់ជាបណ្តោះអាសន្ននូវឋានៈរបស់ភាគីដើម្បីកុំឱ្យភាគីនោះទទួលនូវការខាតបង់នូវផលប្រយោជន៍ដ៏ធ្ងន់ធ្ងរ។ អានុភាពនៃការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ននៃកម្មវត្ថុដែលមានវិវាទគឺដើម្បីរក្សានូវស្ថានភាព ឬលក្ខខណ្ឌបច្ចុប្បន្នឱ្យនៅដដែល ប៉ុន្តែអានុភាពនៃការការចាត់ចែងជាបណ្តោះអាសន្នដើម្បីកំណត់នូវឋានៈជាបណ្តោះអាសន្ន គឺការផ្លាស់ប្តូរនូវលក្ខខណ្ឌបច្ចុប្បន្នភាព និងការទទួលបាននូវការពេញចិត្តជាបណ្តោះអាសន្ន

## ផ្នែកទី ៣ នីតិវិធីរក្សាការពារ

**- ភាពខុសគ្នារវាងនីតិវិធី នៃសេចក្ដីសម្រេចក្សាការពារ និង នីតិវិធីនៃសេចក្ដីសម្រេចលើបណ្ដឹងអង្គសេចក្ដី**

ជាទូទៅនៅក្នុងនីតិវិធីការសម្រេចរក្សាការពារ និងនីតិវិធីនៃបណ្ដឹងអង្គសេចក្ដីចាប់ពីគន្ថីទី២ ដល់ គន្ថីទី៤ នៃក្រមនីនិវិធីរដ្ឋប្បវេណីត្រូវអនុវត្តដូចគ្នា ក៏ប៉ុន្តែលើកលែងតែមានបញ្ញត្តិពិសេស (មាត្រា ៥៣៩)។ ដូច្នេះបញ្ញត្តិពិសេសនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីគឺជាភាពខុសគ្នា តើភាពខុសគ្នាមានអ្វីខ្លះ យើងនឹងបកស្រាយដូចតទៅ :

នៅក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយសមត្ថកិច្ចផ្ដាច់មុខ មានន័យថា មិនអាចផ្លាស់ប្ដូរ ដោយការព្រមព្រៀងរបស់ភាគីទៅលើសមត្ថកិច្ចទេ ព្រោះវាមានភាពចាំបាច់ត្រូវធ្វើបន្ទាន់ (មាត្រា ៥៣៣) ហើយនីតិវិធីនេះត្រូវធ្វើឡើង ដោយឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ឬក៏ការសួរភាគី គឺទៅតាមការជ្រើសរើសរបស់តុលាការ (ឆន្ទានុសិទ្ធិ) ហើយការសួរភាគីនេះពុំចាំបាច់ធ្វើនៅក្នុងបន្ទប់តុលាការទេ គឺអាចធ្វើក្នុងបន្ទប់ធម្មតាបាន និងពុំចាំបាច់មានភាគីម្ខាងទៀតក៏បានដែរ (មាត្រា ១១៤ កថាខណ្ឌទី១) តុលាការត្រូវឱ្យភាគីដែលស្នើសុំចេញដីការក្សាការពារធ្វើសេចក្ដីបញ្ជាក់ដំបូង (មាត្រា៥៤១ កថាខណ្ឌទី៣) ដោយពិនិត្យត្រួសៗនូវឯកសារដែលពាក់ព័ន្ធ ឬភស្តុតាងដែលអាចពិនិត្យភ្លាមៗ ក្នុងការស្នើសុំនេះគឺគ្រាន់តែឱ្យតុលាការជឿទុកចិត្តតែប៉ុណ្ណោះ មិនមែនជាការបញ្ជាក់ច្បាស់លាស់ និង មានកំរិតខ្ពស់ទេ (មាត្រា ១៣១) ព្រោះជានីតិវិធីដែលធ្វើឡើងដើម្បីចាត់ចែងជាបណ្ដោះអាសន្ន
ហើយវានឹងត្រូវបញ្ចប់វិញដោយសាលក្រមស្ថាពរ ។

**ឧទាហរណ៍** ភាគីមួយគាត់ចង់សុំដីកាសម្រេចចាត់ចែងរក្សាការពារហាមឃាត់ដីរបស់ភាគីម្ខាងទៀតមិនឱ្យលក់ ដូរ បញ្ចាំ ផ្ទេរសិទ្ធិ ធ្វើអនុប្បទាន ឬ អំណោយជាដើម ភាគីនោះ ចាំបាច់ដាក់ឯកសារបញ្ជាក់ដំបូងនូវកម្មសិទ្ធិដីរបស់ខ្លួន តែបើពុំមានទេ យ៉ាងហោចណាស់ ក៏មានការបញ្ជាក់ពីរដ្ឋអំណាចមូលដ្ឋាន ឬក៏សាក្សីជិតខាងដែរ។

រីឯនីតិវិធីបណ្ដឹងអង្គសេចក្ដីវិញ គឺភាគីនៃបណ្ដឹងអាចធ្វើការព្រមព្រៀងគ្នាបានទៅលើសមត្ថកិច្ចជម្រះក្ដី ហើយការព្រមព្រៀងនេះនឹងមានអានុភាពបាន លុះត្រាតែធ្វើឡើងជាលាយលក្ខណ៍អក្សរចំពោះបណ្ដឹងដែលផ្អែកលើទំនាក់ទំនងគតិយុត្ត។ ម្យ៉ាងទៀតដើមចោទដែលបានដាក់បណ្ដឹងទៅតុលាការជំនុំជំរះលើកទី១ ហើយតុលាការបញ្ជូនបណ្ដឹងនោះទៅចុងចម្លើយ រួចចុងចម្លើយបានធ្វើសេចក្ដីដោះសារ អំពីអង្គហេតុនៅក្នុងនីតិវិធីណាមួយ

រួចហើយ គឺនីតិវិធីត្រៀមទាញហេតុផល ឬបានឆ្លើយដោះសារនៅក្នុងការទាញហេតុផល ដោយផ្ទាល់មាត់ ភាគីចុងចម្លើយមិនអាចធ្វើវិវាទអំពីកំហុសសមត្ថកិច្ចទេ ព្រោះដើម្បីធានាស្ថេរភាពនីតិវិធី (មាត្រា ១៤)។

ក្នុងការដោះស្រាយបណ្ដឹងអង្គសេចក្ដី តុលាការត្រូវតែធ្វើនីតិវិធីត្រៀមសំរាប់ការទាញហេតុផល ដោយតុលាការរៀបចំការអះអាងរបស់ភាគី រៀបចំចំណុចវិវាទ និង ភស្តុតាងដែលត្រូវពិនិត្យនៅក្នុងពេលទាញហេតុផលផ្ទាល់មាត់ ប៉ុន្តែមិនបើកជាសាធារណៈទេ (មាត្រា ១០៣ មាត្រា១០៤) រីឯនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ក៏ត្រូវធ្វើដោយខានមិនបានដែរ ដើម្បីចេញសាលក្រម ដូច្នេះតុលាការគ្មានជំរើសទេ។ ហើយតុលាការត្រូវតែធ្វើការទាញហេតុផលផ្ទាល់មាត់ នៅក្នុងបន្ទប់តុលាការជាសាធារណៈដែលភាគីសងខាងអាចមានវត្តមានបាន យើងធ្វើបែបនេះ ព្រោះដោយសារបណ្ដឹងអង្គសេចក្ដីជាបណ្ដឹងដែលត្រូវកំណត់សិទ្ធិជាស្ថាពរ ដូច្នេះត្រូវតែឱ្យភាគីដែលពាក់ព័ន្ធមានឱកាសដើម្បីអះអាងត៉វ៉ា គឺអាចរក្សាន្ធូវតម្លាភាពបាន (មាត្រា ១១៤ មាត្រា១១៥)។ នៅក្នុងនីតិវិធីបណ្ដឹងអង្គសេចក្ដីនេះ ក៏មានការបញ្ជាក់ គឺត្រូវតែមានកំរិតខ្ពស់ជាងការបញ្ជាក់ដំបូង នៅក្នុងការចាត់ចែងរក្សាការពារដើម្បីកំណត់អំពីអង្គហេតុដែលគេបានប្តឹងនោះថាតើមានអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនោះដែរឬទេ? ហើយដើម្បីកំណត់ដូច្នេះគូភាគីត្រូវតែបង្ហាញភស្តុតាងសំខាន់ៗសំរាប់បញ្ជាក់អង្គហេតុ ។

### - ភាពខុសគ្នារវាងនីតិវិធីអនុវត្តកិច្ចការរក្សាការពារ និង នីតិវិធីអនុវត្តដោយបង្ខំ

ក្រោយពីតុលាការសំរេចន្ធូវវិធានការណ៍ចាត់ចែងរក្សាការពារ ភាគីអ្នកស្នើសុំត្រូវដាក់ពាក្យសុំអនុវត្ត (មាត្រា៥៣២ កថាខណ្ឌទី២) ហើយតុលាការអនុវត្តការរក្សាការពារយកដីកាសម្រេចនេះទៅអនុវត្តពុំចាំបាច់មានរូបមន្តអនុវត្ត ដូចលិខិតអនុវត្តដទៃទេ ប៉ុន្តែការអនុវត្តរក្សាការពារត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ លើកលែងតែការអនុវត្តរក្សាការពារចំពោះ ឬសំរាប់ជនក្រៅពីភាគីត្រូវធ្វើឡើង ដោយផ្អែក លើឯកសារចម្លងយថាភូតនៃដីកាសម្រេចការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត(មាត្រា៥៦២ កថាខណ្ឌទី១)។ ប្រសិនបើដីការក្សាការពារបានចាត់បញ្ជូនដល់ម្ចាស់បំណុលដែលជាអ្នកស្នើសុំ ហើយខ្លួនពុំបានសុំអនុវត្តទេ
ដោយទុកអំឡុងពេល២សប្តាហ៍ បានកន្លងហួសនោះ
ការអនុវត្តរក្សាការពារមិនត្រូវធ្វើឡើយ(មាត្រា ៥៦២ កថាខណ្ឌ ទី ២)។

ផ្ទុយទៅវិញដីកាសម្រេចរក្សាការពារក្រោយពីបានធ្វើឡើង ដោយតុលាការហើយ

ម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យអនុវត្តរួចហើយ ដីកាសម្រេចនោះអាចអនុវត្តភ្លាម ទោះបីមិនទាន់ចាត់បញ្ជូនទៅដល់កូនបំណុលក៏ដោយ (មាត្រា ៥៦២ កថាខណ្ឌទី៣) ។

រីឯការអនុវត្តដោយបង្ខំមានលក្ខណៈខុសពីនីតិវិធីនៃការអនុវត្តការរក្សាការពារ គឺថាភាគីដែលទទួលបានលិខិតអនុវត្ត ហើយត្រូវយកទៅសុំអនុវត្តដោយបង្ខំនៅតុលាការអនុវត្ត ឬអាជ្ញាសាលា ហើយលិខិតអនុវត្តត្រូវតែជាឯកសារចម្លងយថាភូតដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តជាចាំបាច់ (មាត្រា៣៥៤ កថាខណ្ឌទី១) ប៉ុន្តែទោះបីច្បាប់តម្រូវដូច្នេះក៏ដោយ ក៏មានករណីលើកលែងខ្លះដែរ ចំពោះលិខិតអនុវត្តដែលមិនចាំបាច់មានរូបមន្តអនុវតត្ត ដូចជា :

- សាលក្រមនៃបណ្តឹងរឿងក្តីនេះ ចំនួនទឹកប្រាក់តិចដែលចូលជាស្ថាពរ

- សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

- ដីកាសម្រេចដាស់តឿនដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ។

ដូចបានបញ្ជាក់ខាងលើរួចហើយ ការអនុវត្តដោយបង្ខំត្រូវតែជាឯកសារយថាភូត ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់លើលិខិតអនុវត្ត ឬលិខិតអនុវត្តនេះចូលជាស្ថាពររួចហើយ ដែលក្រឡាបញ្ជីជាអ្នករៀបចំ ប៉ុន្តែលិខិតទាំងនេះអាចនឹងចាប់ផ្តើមអនុវត្តបានលុះណាតែត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តន៍ជាមុនសិន ទើបអនុវត្តបាន(មាត្រា ៣៦០) ។

ភាពខុសគ្នាមួយទៀត រាល់លិខិតអនុវត្តដែលបានចូលជាស្ថាពរហើយ ទោះភាគីមិនទាន់យកមកអនុវត្តភ្លាមក៏ដោយ ក៏លិខិតអនុវត្តនោះនៅតែមានអានុភាព ឬអាជ្ញាយុកាលរយៈពេល០៥ឆ្នាំ បន្ទាប់ពីការចូលជាស្ថាពរនៃលិខិតនោះ (យោងតាមមាត្រា ៤៨៤ នៃក្រមរដ្ឋប្បវេណី) មានន័យថា សិទ្ធិលើបំណុលដែលចូលជាស្ថាពរដោយសាលក្រម ឬសាលដីកាស្ថាពរ ឬដោយការផ្សះផ្សាតាមផ្លូវតុលាការ ឬតាមវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ អាជ្ញាយុកាលនៃការរលត់សិទ្ធិនោះត្រូវមានអំឡុងពេល០៥ឆ្នាំ គិតចាប់ពីសិទ្ធិលើបំណុលនោះចូលជាស្ថាពរ ទោះបីមានបញ្ញត្តិដែលកំណត់អំឡុងពេលនៃអាជ្ញាយុកាលតិចជាង០៥ឆ្នាំក៏ដោយ។

## ផ្នែកទី ៤ ចរិកលក្ខណៈនៃការរក្សាការពារ

### ~ លក្ខណៈបណ្តោះអាសន្ន

ដីកាសម្រេចរក្សាការពារ គឺជានីតិវិធីមួយដែលធ្វើឡើងដោយបណ្តោះអាសន្ន បានន័យថា ដីកាសម្រេចរក្សាការពារពុំមានឥទ្ធិពលទៅលើសេចក្តីសំរេច ដោយសាលក្រម

ក្នុងបណ្តឹងអង្គសេចក្តីឡើយ ឬធ្វើឱ្យសេចក្តីសម្រេចប្រែប្រួលទេ។ ទោះបីដីកាសម្រេចរក្សាការពារដែលបានចេញដោយតុលាការក៏ដោយ ក៏សិទ្ធិលើបំណុល ឬសិទ្ធិទាមទារផ្សេងៗទៀតរបស់បណ្តឹងអង្គសេចក្តីមិនត្រូវបានបញ្ជាក់ថា មានអត្ថិភាព ឬនត្ថិភាពឡើយ។

### ~ លក្ខណៈបន្ទាន់បន្ទំ

នីតិវិធីនៃការចេញដីកាសម្រេចរក្សាការពារ គឺជាការប្រញាប់ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬការពារការខូចខាតដែលរំពឹងថានឹងកើតមានឡើងនាពេលឆាប់ៗខាងមុខជាក់ជាមិនខាន ដូច្នេះចៅក្រមមានឆន្ទានុសិទ្ធិជ្រើសរើសយកនីតិវិធីណាមួយក៏បាន ប៉ុន្តែនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចៅក្រមកម្រនឹងធ្វើណាស់ ព្រោះពេលខ្លះធ្វើឱ្យខូចខាតដល់កម្មវត្ថុដែលត្រូវរក្សាការពារដែលបង្កឡើងដោយកូនបំណុល ចៅក្រមច្រើនតែជ្រើសរើសយកនីតិវិធីការសួរម្ចាស់បំណុល គឺមានលក្ខណៈល្អជាង គ្រាន់តែពិនិត្យភស្តុតាងជាឯកសារ ឬឱ្យភាគីធ្វើសេចក្តីបញ្ជាក់ដំបូងល្មមៗបានហើយ។ សេចក្តីបញ្ជាក់តំបូងត្រូវធ្វើ ដោយផ្អែកលើ ភស្តុតាងដែលអាចឱ្យគេពិនិត្យបានភ្លាមៗ។ បន្ទាប់ពីធ្វើសេចក្តីបញ្ជាក់ដំបូងដែលនាំឱ្យចេញការរក្សាការពារ ហើយដីកាសម្រេចនេះត្រូវទុករយៈ ពេលនៃការអនុវត្តក្នុងអំឡុង២សប្តាហ៍ចាប់ពីថ្ងៃដែលចាប់បញ្ជូនទៅម្ចាស់បំណុល បើម្ចាស់បំណុលមិនសុំអនុវត្តទេ នោះដីកាសម្រេចត្រូវអស់អានុភាព ប៉ុន្តែពេលអនុវត្តដីកាសម្រេចនេះមិនចាំបាច់មានរូបមន្តអនុវត្ត។ ម៉្យាងទៀតដើម្បីឱ្យបានលឿន និងបន្ទាន់ផង ច្បាប់បានតម្រូវទៅលើសមត្ថកិច្ចផ្តាច់មុខ បានន័យថា ភាគីមិនអាចផ្លាស់ប្តូរសមត្ថកិច្ច ដោយការព្រមព្រៀងឡើយ។

### ~ លក្ខណៈបន្ទាប់បន្សំ

នីតិវិធីនៃការចាត់ចែងរក្សាការពារ គឺជានីតិវិធីបន្ទាប់បន្សំដើម្បីធ្វើបណ្តឹងអង្គសេចក្តីនៅក្នុងចំណុចមួយចំនួន។ ដូចដែលបានរៀបរាប់រួចមកហើយ ដីកាសម្រេចរក្សាការពារជានីតិវិធីមួយដែលធ្វើឡើងបណ្តោះអាសន្ន វាពុំមានឥទ្ធិពលទៅលើបណ្តឹងអង្គ-សេចក្តីទេ ហើយវាកំណត់ដោយសមត្ថកិច្ចផ្តាច់មុខ នៅពេលដែលភាគីបានដាក់បណ្តឹងអង្គសេចក្តីទៅតុលាការដែលមានសមត្ថកិច្ច នោះការរក្សាការពារត្រូវតែសុំទៅតុលាការដែលមានសមត្ថកិច្ច លើអង្គសេចក្តីនោះដែរ។

ដូច្នេះរឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ (មាត្រា ៥៤០ កថាខណ្ឌទី ១) ។

យោងលើពាក្យសុំរបស់កូនបំណុល តុលាការត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់បណ្ដឹងអង្គសេចក្ដីក្នុងអំឡុងពេលសមរម្យ បើម្ចាស់បំណុលខកខានមិនដាក់បណ្ដឹងអង្គសេចក្ដីក្នុងកំឡុងពេលដែលបានកំណត់ទេ នោះតុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារនោះ តាមការស្នើសុំរបស់កូនបំណុល (មាត្រា ៥៥៧ កថាខណ្ឌទី ១, ៣) ។

ម្យ៉ាងវិញ ទៀតនៅក្នុងបណ្ដឹងរក្សាការពារលុះណាតែមានទំនាក់ទំនងគតិយុត្ត ឬការបង្កើតសិទ្ធិដែលត្រូវការពារ ឬភាពចាំបាច់ក្នុងការរក្សាការពារ។ ក្នុងករណីដែលមានការរលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តនឹងត្រូវបានរក្សាការពារ ឬភាពចាំបាច់នៃការរក្សាការពារ ឬមានការផ្លាស់ប្ដូរស្ថានភាពផ្សេងៗទៀត តុលាការមិនត្រឹមតែបានចេញដីកាសម្រេចរក្សា-ការពារប៉ុណ្ណោះទេ ថែមទាំងធ្វើការជំនុំជម្រះក្ដីបណ្ដឹងអង្គសេចក្ដី អាចលុបដីកាសម្រេចនោះចោលបាន(មាត្រា៥៥៨ កថាខណ្ឌទី១) ។

ឧទាហរណ៍: ការចាត់ចែងរក្សាការពាររឹបអូសរថយន្តរបស់កូនបំណុលដើម្បីធានាសំណងដល់ម្ចាស់បំណុល ប៉ុន្តែបន្ទាប់មកកូនបំណុលបានយកទៅសងម្ចាស់បំណុលតាមការទាមទារហើយនោះ ធ្វើឱ្យរលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តរវាងកូនបំណុល និងម្ចាស់បំណុល ដូច្នេះ មិនត្រឹមតែតុលាការដែលបានចេញដីកាសម្រេចរក្សាការពារប៉ុណ្ណោះទេ ដែលអាចលុបចោលដីកាសម្រេចរក្សាការពារនេះបាន គឺថែមទាំងតុលា-ការដែលវិនិច្ឆ័យលើបណ្ដឹងអង្គសេចក្ដី អាចលុបដីកាសម្រេចរក្សាការពារនោះវិញបានតាមពាក្យសុំ (មាត្រា ៥៥៨ កថាខណ្ឌទី១) ។

## ៶ លក្ខណៈសម្ងាត់

ម្ចាស់បំណុល ឬអ្នកប្ដឹងសុំការចាត់ចែងរក្សាការពារតែងតែបារម្ភថា នៅពេលតុលាការកំណត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិជាស្ថាពរហើយ ខ្លួនមិនអាចអនុវត្តនូវកិច្ចការទាំងនោះបានទេ ហើយម្ចាស់បំណុលតែងតែស្នើសុំមកតុលាការឱ្យចាត់ចែងការរក្សាការពារ ប៉ុន្តែពេលខ្លះតុលាការតម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ដើម្បីកុំឱ្យប្រើសិទ្ធិនេះហួសហេតុពេក រីឯកូនបំណុលវិញ កាលបើខ្លួនដឹងថាចាញ់ក្ដី ពេលនោះខ្លួនក៏បានលួចចាត់ចែងទ្រព្យនោះទៅឱ្យអ្នកដទៃផ្សេងទៀត ក្នុងគោលបំណងគេចវេសមិនទទួលខុសត្រូវ។ ភាពសម្ងាត់នេះ គឺរក្សាផលប្រយោជន៍ឱ្យអ្នកប្ដឹងសុំដែលនីតិវិធីនេះធ្វើឱ្យបាត់បង់ គោលការណ៍ចំពោះមុខ ប៉ុន្តែដោយសារមានលក្ខណៈសម្ងាត់បែបនេះហើយទើបច្បាប់តម្រូវឱ្យម្ចាស់បំណុលដែលជាអ្នកស្នើសុំយកដីកាសម្រេចរក្សាការពារនេះ
ទៅអនុវត្តមុនការបញ្ជូនទៅដល់កូនបំណុល បានទៀតផង(មាត្រា៥៦២ កថាខណ្ឌទី៣)។
ចៅក្រមអាចជ្រើសរើសយកនីតិវិធីនៃការ ទាញហេតុផលដោយផ្ទាល់មាត់
ដូចជាការការពិនិត្យភស្តុតាង និងការសាកសួរសាមី ភាគីបានដែរ
ប៉ុន្តែនីតិវិធីនេះអាចធ្វើជាសាធារណៈ ដូច្នេះអាចមានហានិយភ័យកើតឡើង

ដោយកូនបំណុល ឬតតិយជនផ្សេងទៀតធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់បំណុល។ ដើម្បីចៀសវាងនូវហានិភ័យនេះ តុលាការត្រូវធ្វើនីតិវិធីរក្សាការពារជាសំងាត់ ដូច្នេះតុលាការអាចជ្រើសរើសនីតិវិធីនៃការពិនិត្យឯកសារ ឬសួរម្ចាស់បំណុល(មាត្រា១១៤ កថាខណ្ឌទី២) ដើម្បីចេញដីកាសម្រេច។

បើកូនបំណុលយល់ឃើញថា ការចាត់ចែងរក្សាការពារនេះប៉ះពាល់ផលប្រយោជន៍របស់ខ្លួន ដោយមិនសមរម្យ ទើបរបបចាត់ចែងរក្សាការពារនេះអាចអនុញ្ញាតឱ្យកូនបំណុលប្តឹងតវ៉ាបាន ហើយយតុលាការក៏ពិចារណាពីបណ្តឹងតវ៉ានេះដែលនាំឱ្យតុលាការទទួលស្គាល់ផ្លាស់ប្តូរ ឬលុបចោលការចាត់ចែងរក្សាការពារនេះបានតែម្តង។

## ជំពូកទី ២ ការដាក់ពាក្យសុំ

### ផ្នែកទី១ របៀបដាក់ពាក្យសុំ

ដើម្បីធ្វើឱ្យនីតិវិធីដំណើរការទៅស្រួល ពាក្យសុំឱ្យចេញដីការក្សាការពារត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ (មាត្រា ៥៣៤ ចំណុច ក)។

### ផ្នែកទី២ សមត្ថកិច្ចសាលាជម្រះក្តី

#### ១- តុលាការដែលមានសមត្ថកិច្ច

តុលាការមានសមត្ថកិច្ចលើរឿងក្តីនៃការរក្សាការពារមានដូចខាងក្រោម(មាត្រា ៥៤០ កថាខណ្ឌ ១)។

នេះជាសមត្ថកិច្ចផ្តាច់មុខ (មាត្រា ៥៣៣) មានន័យថា តុលាការដែលមានសមត្ថកិច្ចមិនអាចត្រូវបានផ្លាស់ប្តូរដោយការព្រមព្រៀងរបស់ភាគីទាំងពីរបានទេ។

**ក- តុលាការមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី (មាត្រា ៥៤០-១)**

តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទី១។ ប៉ុន្តែបើអង្គសេចក្តីត្រូវបានចាត់ការក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ (មាត្រា ៥៤០ កថាខណ្ឌទី ២)។

បើអង្គសេចក្តីត្រូវបានចាត់ការនៅឯតុលាការកំពូល ដោយត្រឡប់ទៅរកគោលការណ៍វិញ តុលាការដែលមានសមត្ថកិច្ចលើរឿងក្តីនៃដីកាសំរេចរក្សាការពារ គឺជាតុលាការនៃការជំនុំជំរះលើកទី ១។

**ខ- សាលាដំបូងមានសមត្ថកិច្ចលើវត្ថុដែលនឹងត្រូវរឹបអូស ឬ កម្មវត្ថុនៃវិវាទ (មាត្រា ៥៤០-១)។**

#### ២- ករណីមិនចូលក្នុងសមត្ថកិច្ច

ពេលដែលពាក្យសុំត្រូវបានដាក់នៅតុលាការមួយ តុលាការនោះត្រូវពិនិត្យអំពីអត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចព្រមទាំងភាពត្រឹមត្រូវនៃពាក្យសុំ។

បើតុលាការរកឃើញថាមិនមានសមត្ថកិច្ចលើរឿងក្តីនៃការរក្សាការពារ តុលាការនោះត្រូវផ្ទេររឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ច យោងតាមពាក្យសុំ ឬតាមឆន្ទានុសិទ្ធិរបស់ខ្លួន (មាត្រា ៥៣៩ និង មាត្រា ១៩ កថាខណ្ឌទី ១)។

## ផ្នែកទី៣ ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ (មាត្រា៥៤១ កថាខណ្ឌទី ១ ចំណុច គ)

ដីកាសំរេចក្នុងការចាត់ចែងរក្សាការពារត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ (មាត្រា ៥៣២-១) ។ និយាយម្យ៉ាងទៀត តុលាការអាចចេញដីកាសម្រេចរក្សាការពារ បាន លុះណាតែមាន ពាក្យសុំរបស់ភាគីណាម្ខាងទើបជាការត្រឹមត្រូវតាមនីតិវិធី។

ខ្លឹមសារដែលមាននៅក្នុងពាក្យសុំឱ្យចេញដីការក្សាការពារត្រូវសរសេរឱ្យបានច្បាស់លាស់ទៅលើចំណុចសំខាន់ៗដែលរួមមាន : ទី១- ឈ្មោះ និងអាសយដ្ឋានរបស់ភាគីនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់, ទី២- ខ្លឹមសារលំអិតនៃដីកាសម្រេចរក្សាការពារនៃដីការក្សាការពារដែលអ្នកសុំទាមទារ, ទី៣- សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ, ទី៤- ភាពចាំបាច់នៃដីកាសម្រេចរក្សាការពារ។

ចំណុចទាំង៤ខាងលើនេះជាមូលដ្ឋានដ៏សំខាន់ដែលត្រូវសរសេរបញ្ជាក់នៅក្នុងពាក្យសុំ(មាត្រា៥៤១)។ ចំពោះអត្ថន័យដែលមាននៅក្នុងចំណុចនីមួយៗដែលគួរត្រូវបានសរ-សេរបែបណានោះ នឹងមានបញ្ជាក់យ៉ាងច្បាស់តាមលំដាប់ដូចខាងក្រោម:

### ៣.១ ឈ្មោះ និងអាសយដ្ឋានរបស់ភាគី និង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា ៥៤១ កថាខណ្ឌទី ១ ចំណុច ក)

នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារត្រូវសរសេរឱ្យបានច្បាស់ថា:នរណាជាអ្នកប្តឹងសុំ? តើអ្នកនោះមានអាសយដ្ឋាននៅទីណា? ហើយអ្នកតំណាងដែលច្បាប់បានកំណត់របស់ជននោះជានរណា? មិនតែប៉ុណ្ណោះពាក់ព័ន្ធដល់ប្រសិទ្ធិភាពនៃការទាក់ទងដែលសមស្របទៅនឹងការជឿនលឿនរបស់សង្គមនាពេលបច្ចុប្បន្ន គឺលេខទូរស័ព្ទដែលគួរត្រូវបានសរសេរភ្ជាប់មកជាមួយ ពីព្រោះនាំឱ្យមានភាពងាយស្រួលក្នុងជូនដំណឹង។

ឧទាហរណ៍ សូមមើលទំព័រទី ១, ៣ នៅក្នុងឯកសារគំរូ។

**៣.២ ខ្លឹមសារលំអិតនៃដីកាសម្រេចរក្សាការពារ ដែលអ្នកដាក់ពាក្យសុំទាមទារ (មាត្រា៥៤១ កថាខណ្ឌទី១ ចំណុច ខ និង មាត្រា ៥៤១)**

ការចាត់ចែងរក្សាការពារមានរហូតដល់ ៣ ប្រភេទ ហើយដំណើរការនីតិវិធីនៃប្រភេទនីមួយៗមានលក្ខណៈខុសគ្នា(មាត្រា ៥៤៨ កថាខណ្ឌទី៤)។ ដូច្នេះ ខ្លឹមសារនៃដីការក្សាការពារ គឺជាការសំខាន់ដែលពុំអាចខ្វះបាន លើសពីនេះទៀត ត្រូវមានអត្ថន័យច្បាស់លាស់ ដើម្បីបញ្ជាក់ពីប្រភេទនៃដីការក្សាការពារណាមួយអាចជា:

-ដីការក្សាការពារ ដើម្បីធ្វើការរឹបអូសជាបណ្តោះអាសន្ន

-ដីការក្សាការពារការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

-ដីការក្សាការពារការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន (មាត្រា៥៣១)។

ច្បាស់ជាងនេះ ខ្លឹមសារនៃការចេញដីការក្សាការពារ គឺជាកម្មវត្ថុនៃការចេញដីកាសម្រេចរក្សាការពារ។ ឧទាហរណ៍ នៅក្នុងរឿងក្តីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ការកំណត់ជាក់លាក់នូវអចលវត្ថុដែលត្រូវរឹបអូសជាបណ្តោះអាសន្ន និងការកំណត់ជាក់លាក់ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ គឺត្រូវសរសេរបញ្ចូលនៅក្នុងពាក្យសុំដើម្បីកំណត់ជាក់លាក់នូវកម្មវត្ថុនៃដីកាសម្រេច។

ឧទាហរណ៍ សូមមើលទំព័រទី ១ នៅក្នុងឯកសារគំរូ។

**៣.៣ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលត្រូវបានរក្សាការពារ (មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច គ មាត្រា៥៤២ កថាខណ្ឌទី២)**

សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ត្រង់ចំណុចនេះត្រូវសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗផ្សេងទៀតបើមាន ពីព្រោះថា ការសរសេរអំពីអង្គហេតុទាំងពីរនេះ គឺដើម្បីបង្កើតសិទ្ធិ។ ជាការពិតអង្គហេតុដែលជាមូលហេតុនៃការទាមទារ យោងលើមាត្រា៧៥ គឺត្រូវសរសេរនៅក្នុងពាក្យបណ្តឹងឯណោះ ប៉ុន្តែ ដីការក្សាការពារអាចចេញបានមុនការដាក់ពាក្យបណ្តឹង ត្រង់នេះមានន័យថា “សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ” ត្រូវសរសេរយ៉ាងណាឱ្យអត្ថន័យ និងខ្លឹមសារដូចការសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ បើម្ចាស់បំណុលអាចមើលឃើញអំពីអង្គហេតុតវ៉ាដែលនឹងអះអាង ដោយកូន

បំណុលជាការប្រសើរ ម្ចាស់បំណុលត្រូវបញ្ចូលនូវការបដិសេធអំពីអង្គហេតុតវ៉ានោះ ពីព្រោះវាមានប្រយោជន៍សម្រាប់តុលាការក្នុងការចេញដីកាសម្រេច និងសម្រេចអំពីចំនួនប្រាតិភោគ។

ឧទាហរណ៍ សូមមើលទំព័ទី ១, ២ នៃសំណុំឯកសារគំរូ។

## ៣.៤ ភាពចាំបាច់នៃការរក្សាការពារ (មាត្រា៥៤១ កថាខណ្ឌទី ១ ចំណុច ឃ មាត្រា ៥៤២ កថាខណ្ឌទី២)

នៅក្នុងពាក្យសុំដីការក្សាការពារ ភាគីអ្នកសុំត្រូវសរសេរយ៉ាងណាបញ្ជាក់ឱ្យបានច្បាស់អំពីតំរូវការចាំបាច់ដើម្បីឱ្យចៅក្រមចេញដីការក្សាការពារ។ ជាពិសេសព័ត៌មានដែលភាគីម្ចាស់បំណុលមានទាក់ទិនស្ថានភាពស្ថិតក្នុងហានិភ័យលើទ្រព្យសម្បត្តិរបស់កូនបំណុល ។ ដូច្នេះពាក់ព័ន្ធចំណុចភាពចាំបាច់ដែលត្រូវសរសេរនៅក្នុងពាក្យសុំចេញដីការក្សាការពារ គប្បីសរសេរយ៉ាងណាបង្ហាញឱ្យឃើញពីភាពចាំបាច់ដើម្បីឱ្យចៅក្រមយល់ព្រមចេញដីការក្សាការពារ (មាត្រា៥៤៥ កថាខណ្ឌទី១ មាត្រា៥៤៨ កថាខណ្ឌទី១ និង កថាខណ្ឌទី ២)។

ឧទាហរណ៍ សូមមើលទំព័រទី ២ នៃសំណុំឯកសារគំរូ។

## ៣.៥ ភស្តុតាងតាមហេតុនីមួយៗ (មាត្រា៥៤១ កថាខណ្ឌទី ២)

ពេលដែលម្ចាស់បំណុលសរសេរ*អំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ(មាត្រា៥៤១ កថាខណ្ឌទី១ ចំណុចគ មាត្រា៥៤២ កថាខណ្ឌទី២) ឬ ភាពចាំបាច់នៃការក្សាការពារ (មាត្រា៥៤១ កថាខណ្ឌទី១ ចំណុច ឃ មាត្រា ៥៤២ កថាខណ្ឌទី២)* នៅក្នុងពាក្យសុំ ម្ចាស់បំណុលគប្បីសរសេរឱ្យបានច្បាស់លាស់ និងសរសេរនូវភស្តុតាង(ឯកសារអំពីសេចក្តីបញ្ជាក់តំបូង)ដែលបញ្ជាក់នូវ*សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ* ពីព្រោះ ការយោងនេះមានប្រយោជន៍សម្រាប់តុលាការក្នុងការស្វែងរកនូវទំនាក់ទំនងរវាងអង្គហេតុ និងភស្តុតាង។

ឧទាហរណ៍ សូមមើលទំព័រទី ១ , ២ នៃសំណុំឯកសារគំរូ

## ៣.៦ បញ្ជីសារពើភ័ណ្ឌ

ចំពោះការពិពណ៌នាគឺផ្តោតជាសំខាន់ទៅលើ ឯកសារដែលភ្ជាប់មកជាមួយពាក្យសុំឱ្យចេញដីការក្សាការពារអាចជា : បញ្ជីភាគី បញ្ជីសិទ្ធិលើបំណុល បញ្ជីសារពើភ័ណ្ឌអំពីទ្រព្យដែលត្រូវរឹបអូស និងបញ្ជីសិទ្ធិលើបំណុលដែលនឹងត្រូវបានរក្សាការពារ។ និយាយតាមពិតទៅ ប្រភេទបញ្ជីពិណ៌នាទាំងបីនេះគឺមិនត្រូវភ្ជាប់ជាមួយពាក្យសុំទេ ប៉ុន្តែវាជាផ្នែកមួយនៃពាក្យសុំ។ បញ្ជីសារពើភ័ណ្ឌទាំងនេះមានតួនាទីមួយផ្សេងទៀតគឺ ផ្តល់ភាពងាយស្រួលដល់ចៅក្រមដែលចេញដីការក្សាការពារ ដោយពុំចាំបាច់សរសេរខ្លឹមសារនៅឯកសារដែលភ្ជាប់មកនោះ នៅលើដីកាសម្រេចរក្សាការពារនោះទៀតទេ ដោយហេតុថាចៅក្រម គ្រាន់តែឆ្លើយតបអនុញ្ញាតចេញដីកាសម្រេចរក្សាការពារនៅលើលិខិតមួយយ៉ាងខ្លី តែមានភ្ជាប់ទៅវិញនូវឯកសារដែលម្ចាស់បំណុលបានភ្ជាប់មក។ ជម្រើសឆ្លើយតបដែលយកឯកសារភ្ជាប់ដាក់ទៅវិញនេះសំខាន់គឺ ចំណេញពេលវេលា ពីព្រោះនីតិវិធីក្នុងការចេញដីកាសម្រេចរក្សាការពារគឺ ត្រូវតែមានភាពរហ័ស ពុំដូចល្បឿននៃនីតិវិធីចេញសាលក្រមនោះទេ ។

ឧទាហរណ៍ សូមមើលទំព័រទី ៣, ៤, ៥ (ពាក្យសុំដីការក្សារការពារ) និងទំព័រទី ១៨, ១៩, ២០ (ដីកាសម្រេចរក្សាការពារ) នៅក្នុងសំណុំឯកសារគំរូ។

## ផ្នែកទី ៤ ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំ

យោងតាមខ្លឹមសារនៃក្រមនីតិវិធីរដ្ឋប្បវេណី ឯកសារភ្ជាប់ជាមួយពាក្យសុំនេះមានច្រើនប្រភេទដូចជា ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង (មាត្រា៥៤១ កថាខណ្ឌទី៣) ឯកសារដើម្បីបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ (មាត្រា៥៣ កថាខណ្ឌទី ២) ឯកសារដើម្បីបញ្ជាក់កម្មវត្ថុនៃការចាត់ចែងរក្សាការពារមាត្រា(៥៤១ កថាខណ្ឌទី១ ចំណុច ខ) និង (មាត្រា ៥៤៦) និងឯកសារផ្សេងៗទៀត។

### ៤.១ ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង

តាមមាត្រា ១៣១ សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន ដូច្នេះឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង គឺជាឯកសារជាភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន នៅពេលធ្វើសេចក្តីបញ្ជាក់ដំបូង ។

ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូងដែលត្រូវភ្ជាប់ជាមួយពាក្យសុំនោះ មានចែងក្នុងមាត្រា៥៤១ កថាខណ្ឌទី៣ មានដូចជា ឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានការពារ និងឯកសារដែលបញ្ជាក់ពីភាពចាំបាច់នៃការរក្សាការពារ។

## ៥.១. ក ឯកសារបញ្ជាក់ដំបូងអំពី សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានការពារ

អ្នកដាក់ពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារ (ម្ចាស់បំណុល) ចាំបាច់ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ចំពោះសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ។ ដើម្បីធ្វើសេចក្តីបញ្ជាក់ ចំពោះសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ អ្នកដាក់ពាក្យសុំត្រូវធ្វើការបញ្ជាក់ពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

ដូចដែលបានពន្យល់ខាងលើរួចហើយ ភស្តុតាងដែលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងគឺជាឯកសារ។ ដូច្នេះ ឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិនោះ គឺមានទៅតាមប្រភេទនៃរឿងក្តី ដូចជា រឿងក្តីទាក់ទងនឹងកិច្ចសន្យាកិច្ចបរិភោគ គឺលិខិតកិច្ចសន្យាខ្ចីបរិភោគ រឿងក្តីទាក់ទងនឹងការទាមទារឱ្យប្រគល់អចលនវត្ថុ គឺប័ណ្ណកម្មសិទ្ធិ ហើយរឿងក្តីទាក់ទងនឹងការទាមទារឱ្យប្រគល់ផ្ទះ ដោយសារការបញ្ចប់ភតិសន្យា ឬការបញ្ចប់កិច្ចសន្យាខ្ចីប្រើ គឺភតិសន្យា ឬកិច្ចសន្យាខ្ចីប្រើតាមលំដាប់លំដោយ។ល។

ហេតុអ្វីបានត្រូវធ្វើការបញ្ជាក់របៀបនេះ? ឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានការពារនេះមានសារសំខាន់ណាស់សំរាប់ឱ្យចៅក្រមអាចពិនិត្យភ្លាមៗ និងកំណត់ថាតើម្ចាស់បំណុលមានសិទ្ធិ
ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវ បានរក្សាការពារ ឬអត់។

ផ្ទុយទៅវិញ បើម្ចាស់បំណុលខកខានមិនបានដាក់ឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលត្រូវបានការពារទេ គឺចៅក្រមមិនអាចដឹង ឬអាចកំណត់សិទ្ធិរបស់ម្ចាស់បំណុលបានឡើយ។ ការខ្វះឯកសារនេះ គឺខុសពីលក្ខខណ្ឌចាំបាច់ក្នុងការដាក់ពាក្យសុំ (មាត្រា ៥៤១) ជាហេតុនាំឱ្យចៅក្រមត្រូវលើកពាក្យសុំនេះចោល ដោយដីកាសម្រេច។

### ៤.១.២ ឯកសារបញ្ជាក់ដំបូងអំពី ភាពចាំបាច់នៃការរក្សាការពារ

លើសពីនេះទៅទៀត មានលក្ខខណ្ឌមួយទៀត ដែលចៅក្រមត្រូវពិចារណាដែរ ថាតើមានភាពចាំបាច់នៃការរក្សាការពារដែរឬទេ។ មានន័យថាចៅក្រមមិនអាចចេញដីកាសម្រេចរក្សាការពារ ដោយសំអាងទៅលើលក្ខខណ្ឌ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិតែមួយប៉ុណ្ណោះទេ គឺចាំបាច់ត្រូវមានលក្ខខណ្ឌនៃភាពចាំបាច់នៃការរក្សាការពារ ទើបចៅក្រមអាចចេញដីកាសម្រេចបាន។ ភាពចាំបាច់នៃការរក្សាការពារនេះមានសារសំខាន់ណាស់ដែលមិនអាចខ្វះបាន ព្រោះថាការចេញដីកាសម្រេចរក្សាការពារ គឺមានការប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់កូនបំណុល ។

គោលគំនិតរួមនៃភាពចាំបាច់នៃដីកាសម្រេចរក្សាការពារ មានចែងក្នុងមាត្រា ៥៣០។ ប៉ុន្តែភាពដោយឡែកត្រូវបានកំណត់នៅក្នុងមាត្រាផ្សេងទៀត អាស្រ័យទៅតាមប្រភេទនៃដីកាសម្រេច ឬទៅតាមកម្មវត្ថុនៃដីកាសម្រេច ដូចជា ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មាត្រា ៥៤៥ (គឺចេញសម្រាប់កម្មវត្ថុចំពោះសិទ្ធិលើបំណុលមានគោលបំណងសងជាប្រាក់ដែលភាពចាំបាច់របស់ដីកានេះ (គោលបំណងនៃដីកាសម្រេច) គឺក្នុងការបារម្ភណ៍ថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ) ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន (មាត្រា ៥៤៨ កថាខណ្ឌទី ១) (ដែលចេញសម្រាប់កម្មវត្ថុ ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ភាពចាំបាច់នៃដីកា នេះ គឺម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវុត្ថុនោះ) និងដីកាសម្រេច ចាត់ចែងជាបណ្តោះអាសន្ន (មាត្រា៥៤៨ កថាខណ្ឌទី២) (ដែលចេញសម្រាប់កម្មវត្ថុ ដើម្បីកំណត់ឋានៈជាបណ្តោះអាសន្ន ភាពចាំបាច់នៃដីកាសម្រេចនេះគឺដើម្បីជៀសវាង ការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ)។

ដូច្នេះ ម្ចាស់បំណុលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ចាំបាច់ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងពីភាពចាំបាច់នេះ គឺត្រូវផ្តល់ឯកសារដែលបញ្ជាក់ពីភាពចាំបាច់នៃការរក្សាការពារ ដោយសរសេរពីមូលហេតុ និងស្ថានភាពផ្សេងៗដែលកូនបំណុលរបស់ខ្លួន

មានដើម្បីបង្ហាញពីភាពចាំបាច់របស់ខ្លួន ដើម្បីធ្វើការរក្សាការពារ(ធ្វើឱ្យខ្លួនមានការបារម្ភពីសិទ្ធិរបស់ខ្លួនចំពោះកូនបំណុល)ដើម្បីឱ្យចៅក្រមពិចារណាឈានទៅចេញដីកាសម្រេច។

វាជាការលំបាកដែរសម្រាប់ម្ចាស់បំណុល ក្នុងការស្វែងរកភស្តុតាងផ្សេងៗដែលបញ្ជាក់ថា កូនបំណុលរបស់ខ្លួនជួបនឹងស្ថានភាពលំបាក ប៉ុន្តែនេះជាកាតព្វកិច្ចរបស់ម្ចាស់បំណុលដែលចាំបាច់ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង។ ឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍សាមញ្ញនៃឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូងដែលបញ្ជាក់ពីភាពចាំបាច់សម្រាប់ការចាត់ចែងរក្សាការពារនេះ ជាទូទៅគ្រាន់តែជារបាយការណ៍ដែលរៀបចំ ដោយម្ចាស់បំណុល គឺគ្រប់គ្រាន់ហើយ (លិខិតបំភ្លឺដែលធ្វើឡើង ដោយម្ចាស់បំណុល)។

ឧទាហរណ៍: ដូចក្នុងរឿងកិច្ចសន្យាខ្ចីបរិភោគ រវាងលោក ខៀវ អាត (ម្ចាស់បំណុល) និងលោក សុក បូរ៉ា (កូនបំណុល) សេចក្តីបញ្ជាក់ដំបូងដែលម្ចាស់បំណុលត្រូវធ្វើទី១គឺ លិខិតកិច្ចសន្យាខ្ចីបរិភោគ ដើម្បីបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិរបស់ខ្លួនមានចំពោះកូនបំណុល និងទី២ គឺរបាយការណ៍បញ្ជាក់ពីភាពចាំបាច់សម្រាប់កិច្ចការរក្សាការពារ(ដោយសរសេរថា កូនបំណុលបានជំពាក់ប្រាក់ញាតិសណ្តានរបស់គាត់ច្រើនណាស់ ដោយគាត់យកប្រាក់នេះទៅចំណាយលើថ្លៃព្យាបាលឪពុករបស់គាត់ ហើយគាត់ស្ថិតនៅក្រោមសំពាធត្រូវសងប្រាក់កំចីទៀត។ បន្ថែមលើនេះទៀត ការរកស៊ីរបស់កូនបំណុលមើលទៅមិនដំណើរការល្អសោះ។ កូនបំណុលជាម្ចាស់នៃអាគារ និងដីមួយកន្លែង ប៉ុន្តែគ្មានទ្រព្យសម្បត្តិពិសេសផ្សេងៗក្រៅពីនេះទេ)។

ឧទាហរណ៍ សូមមើលទំព័រ ៨, ៩ នៅក្នុងឯកសារគំរូ

មូលហេតុ និងស្ថានភាពផ្សេងៗរបស់កូនបំណុលដែលម្ចាស់បំណុលបានលើកឡើងក្នុងរបាយការណ៍នេះជាភស្តុតាងដែលអាចបញ្ជាក់ពីភាពចាំបាច់សម្រាប់ការចាត់ចែងរក្សាការពារ(បើមិនដូច្នេះទេ ម្ចាស់បំណុលមិនអាច ឬមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដីកាសម្រេច នៅកាលបរិច្ឆេទក្រោយ បើម្ចាស់បំណុលឈ្នះក្តី) ។

## ៤.២ ឯកសារដើម្បីបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ (មាត្រា៥៣ កថាខណ្ឌទី២)

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានអនុញ្ញាតឱ្យមានអ្នកតំណាងដោយអាណត្តិនៅក្នុងនីតិវិធីរក្សាការពារដែរ (មាត្រា៥៤ កថាខណ្ឌទី២)។ នីតិវិធីរក្សាការពារ ក៏ដូចនីតិវិធី

សម្រាប់ការជំនុំជម្រះដែរ គឺអ្នកដាក់ពាក្យសុំដីកាសម្រេចរក្សាការពារមានសិទ្ធិជ្រើសតាំងអ្នកតំណាង ដោយអាណត្តិដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនបាន ដោយធ្វើសកម្មភាពបណ្តឹងជំនួសខ្លួន ។

បើមានអ្នកតំណាងដោយអាណត្តិ អ្នកដាក់ពាក្យសុំដីកាសម្រេចរក្សាការពារត្រូវដាក់ឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិនេះភ្ជាប់ជាមួយពាក្យសុំ (មាត្រា ៥៣ កថាខណ្ឌទី២) ។

ឧទាហរណ៍ សូមមើល ទំព័រទី ១០ នៅក្នុងឯកសារគំរូ

បើគ្មានលិខិតបញ្ជាក់ពីសិទ្ធិតំណាង ដោយអាណត្តិទេ តុលាការមិនអាចលើកពាក្យសុំនេះបានទេ គឺគ្រាន់តែឱ្យភាគីកែតម្រូវ ដោយណែនាំឱ្យភាគីដាក់លិខិតនេះ។ ផ្ទុយទៅវិញ បើភាគីមិនបានដាក់ទៀត តុលាការមិនអាចទទួលស្គាល់អ្នកតំណាងដោយអាណត្តិនោះទេ គឺភាគីត្រូវមកធ្វើសកម្មភាពក្នុងនីតិវិធីរក្សាការពារនេះដោយខ្លួនឯង។

ឯកសារដែលបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ(លិខិតប្រគល់សិទ្ធិឱ្យអ្នកតំណាងដោយអាណត្តិ) ដែលជាលក្ខខណ្ឌចាំបាច់ត្រូវតែមាន បើភាគីមានអ្នកតំណាងដោយអាណត្តិ។ ជាគោលការណ៍ អ្នកតំណាងដោយអាណត្តិជាមេធាវី លើកលែង តាមលក្ខខណ្ឌមួយចំនួនតាមមាត្រា៥៣ កថាខណ្ឌទី ១។ ឯកសារដែលបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិមានសារសំខាន់សំរាប់ចៅក្រម ដើម្បីកំណត់ពីទំហំសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ ដើម្បីធានាស្ថេរភាពនៃនីតិវិធីរក្សាការពារ។ បើអ្នកតំណាងដោយអាណត្តិធ្វើសកម្មភាពក្នុងនីតិវិធីរក្សាការពារ ដោយគ្មានលិខិតប្រគល់សិទ្ធិទេ គឺតុលាការមិនអាចកំណត់ពីទំហំសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិបានទេ។ ការធ្វើរបៀបនេះនាំឱ្យមានការប្រើសិទ្ធិហួសពីឆន្ទៈរបស់ភាគីផ្ទាល់ ដែលអាចបណ្តាលឱ្យមានអស្ថេរភាពក្នុងនីតិវិធីរក្សាការពារ និងសង្គមទាំងមូលទៀតផង។

ដូច្នេះ លិខិតប្រគល់សិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ គឺមានផលប្រយោជន៍សម្រាប់តុលាការក្នុងការចាត់ការនីតិវិធីរក្សាការពារប្រកបដោយយុត្តិធម៌ និងស្ថេរភាព និងសម្រាប់ការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី នៃនីតិវិធីរក្សាការពារផងដែរ។

## ៤.៣. ឯកសារដើម្បីបញ្ជាក់កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៤៦)

ខ្លឹមសារមាត្រា៥៤១ កថាខណ្ឌទី ១ ចំណុច ខ ពាក្យសុំត្រូវសរសេរនូវចំណុចខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារដែលរួមមានប្រភេទដីកាសម្រេចកម្មវត្ថុនៃការរឹបអូស និងគោលបំណងនៃការរក្សាការពារ។ កម្មវត្ថុនៃការរឹបអូសក៏ត្រូវមានឯកសារដើម្បីបញ្ជាក់ ដើម្បីភ្ជាប់ជាមួយពាក្យសុំ ពីព្រោះថាដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវបញ្ជាក់ពីកម្មវត្ថុនៃការរឹបអូស លើកលែងតែករណីចលនវត្ថុ។

ក្នុងករណីកម្មវត្ថុនៃការរឹបអូសបណ្ដោះអាសន្នជាអចលនវត្ថុ ឬសិទ្ធិលើបំណុល តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុនេះ។ ប៉ុន្តែចំពោះចលនវត្ថុវិញ តុលាការអាចចេញដីកាសម្រេចបាន ដោយមិនចាំបាច់កំណត់កម្មវត្ថុទេ មាត្រា៥៤៦។ មូលហេតុ គឺថាមានការលំបាកសម្រាប់ម្ចាស់បំណុល ឬតុលាការ ក្នុងការរកថាតើប្រភេទចលនទ្រព្យអ្វីខ្លះដែលកូនបំណុលមាន ហើយពេលមានការអនុវត្ត ដោយបង្ខំចំពោះចលនវត្ថុ អ្នកអនុវត្តគេនឹងដឹងនីតិវិធីនៃការអនុវត្តហើយដូចជា ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ (មាត្រា៣៩១) និង ចលនវត្ថុណាដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា៣៨០)។ ឯកសារដើម្បីបញ្ជាក់កម្មវត្ថុនៃការរឹបអូសបណ្ដោះអាសន្ន គឺអ្នកដាក់ពាក្យសុំត្រូវធ្វើការបញ្ជាក់យ៉ាងណា ដើម្បីឱ្យតុលាការជឿថាកម្មវត្ថុដែលសុំឱ្យតុលាការធ្វើការរឹបអូសជាបណ្ដោះអាសន្ននោះ ពិតជាទ្រព្យសម្បត្តិរបស់កូនបំណុល តាមធម្មតា ឯកសារជាលិខិតបញ្ជាក់ពីកម្មសិទ្ធិរបស់កូនបំណុល ចំពោះទ្រព្យសម្បត្តិ ដូចជា បញ្ជាក់ថា ដី និង ផ្ទះទំហំ ០០ ជាកម្មសិទ្ធិរបស់លោក **ខ** ជាដើម។ ការបញ្ជាក់ពីកម្មសិទ្ធិលើអចលនវត្ថុ ជាភារកិច្ចរបស់មន្ត្រីសុយោដី។ នៅប្រទេសជប៉ុន ដើម្បីទទួលការបញ្ជាក់បែបនេះជាការងាយស្រួលណាស់។ ផ្ទុយទៅវិញ
បើមិនអាចទទួល បានការបញ្ជាក់ពីមន្ត្រីមានសមត្ថកិច្ចទេ
ម្ចាស់បំណុលអាចរកឯកសារតាមមធ្យោបាយ
ផ្សេងៗដែលឯកសារនោះតុលាការអាចទទួលយកបាន ដូចជា មានការបញ្ជាក់ពីមេភូមិ ឬចៅសង្កាត់ជាដើម ។

ឧទាហរណ៏ សូមមើលទំព័រទី ៧ នៅក្នុងឯកសារគំរូ

## ៤.៤ ផ្សេងៗ

ក្រៅពីឯកសារសម្រាប់ធ្វើសេចក្ដីបញ្ជាក់ដំបូង ឯកសារដើម្បីបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ និងឯកសារដើម្បីបញ្ជាក់កម្មវត្ថុនៃការរឹបអូសបណ្ដោះអាសន្ន មានឯកសារជាច្រើនទៀតដែលតុលាការអាចទាមទារឱ្យអ្នកដាក់ពាក្យសុំដាក់ភ្ជាប់ជាមួយពាក្យសុំ ដូចជា ឯកសារបញ្ជាក់ពីភាគី លិខិតបញ្ជាក់របស់នីតិបុគ្គលដើម្បីបញ្ជាក់ពីសមត្ថភាពធ្វើជាភាគី (មាត្រា ៣២ និងមាត្រា ៦ មាត្រា ៤៦) ឯកសារបញ្ជាក់ពីអ្នកតំណាងដែលច្បាប់កំណត់ បើម្ចាស់បំណុលជាអនីតិជន ឬជនវិកលចរិត និងឯកសារបញ្ជាក់ហិត្ថបត្ថម្ភកៈជាដើម។

## ផ្នែកទី៥ សោហ៊ុយ

### ~ ពន្ធពាក្យសុំ

ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលត្រូវបង់ពន្ធចំនួន ៥.០០០រៀល (មាត្រា៥៣៧ កថាខណ្ឌទី ១)។

បើពន្ធពាក្យសុំខាងលើមិនត្រូវបានបង់ទេ តុលាការត្រូវបង្គាប់ម្ចាស់បំណុលបង់ពន្ធពាក្យសុំក្នុងអំឡុងពេលសមរម្យ (មាត្រា៥៣៩ និង មាត្រា៧៨ កថាខណ្ឌទី ១)។

បើម្ចាស់បំណុលមិនបង់ពន្ធពាក្យសុំតាមការបង្គប់ខាងលើទេ តុលាការត្រូវលើកពាក្យសុំចោល ដោយដីកាសម្រេច (មាត្រា៧៨ កថាខណ្ឌទី ២)។

### ~ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

បន្ថែមលើពន្ធពាក្យសុំដែលបានលើកឡើងខាងលើម្ចាស់បំណុលត្រូវបង់ប្រាក់ប្រដាប់ក្ដីតុលាការផ្សេងទៀត សម្រាប់តុលាការបញ្ជូនឯកសារ។ល។ ដែលស្របតាមមាត្រា ៦២ កថាខណ្ឌទី ១ ឧទាហរណ៍ សោហ៊ុយសម្រាប់ការបញ្ជូនដីកាសម្រេច ទៅកូនបំណុល (មាត្រា ៥៤៣)។

លើកលែងតែមានបញ្ញត្តិពិសេសក្នុងគន្ថីទី៧ (ការរក្សាការពារ)នៃក្រមនីតិវិធីរដ្ឋប្បវេណី បញ្ញត្តិនៃគន្ថីទី១ (បទបញ្ញត្តិទូទៅ) ត្រូវបានយកទៅអនុវត្ត ចំពោះនីតិវិធីនៃការរក្សាការពារដែរ ដូច្នេះមាត្រា៦២ត្រូវបានអនុវត្ត ចំពោះប្រាក់ប្រដាប់ក្ដីតុលាការសម្រាប់ចេញដីកាសម្រេចរក្សាការពារផងដែរ។

## ផ្នែកទី៦ ការបែងចែករឿងក្ដីចាត់ចែងរក្សាការពារ

ពេលដែលតុលាការទទួលបាននូវពាក្យសុំការចាត់ចែងរក្សាការពារ រឿងក្តីនៃការចាត់ចែងរក្សាការពារនោះ ត្រូវធ្វើការបែងចែកទៅឱ្យចៅក្រមណាមួយដែលស្របតាមមាត្រា ២៦។

យោងតាមគន្លឹទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលចែងអំពី បទប្បញ្ញត្តិទូទៅ គឺមានវិសាលភាពគ្របដណ្តប់លើគន្លឹទាំងអស់ បានន័យថា បទប្បញ្ញត្តិនៃគន្លឹទី១នេះអាចអនុវត្តបានចំពោះគ្រប់គន្លឹ លើកលែងតែមានបទបញ្ញត្តិពិសេសដែលនៅក្នុងគន្លឹផ្សេងដូច្នេះ ទាក់ទងនឹងការបែងចែងសំណុំរឿងរក្សាការពារ ទៅឱ្យចៅក្រមទទួលបន្ទុក ឃើញថា យោងតាមមាត្រា២៦នេះ គឺបានកំណត់ពីលំដាប់លេខរៀង នៃចៅក្រមដែលត្រូវទទួលសំណុំរឿងអង្គសេចក្តី។ ដោយហេតុថា មាត្រា ២៦ នេះស្ថិតនៅក្នុងគន្លឹទី១ ស្តីពីបទ ប្បញ្ញត្តិទូទៅ ជំពូកទី២ ស្តីពីតុលាការ ផ្នែកទី៣ ស្តីពី ការបែងចែករឿងក្តី និងការដកហូតសមត្ថកិច្ចជំនុំជម្រះ និងបណ្តឹងជិតចិត្ត។ តាមរយៈនេះធ្វើឱ្យយើងឃើញថា ការបែងចែងរឿងក្តីរក្សាការពារ (គន្លឹទី៧) ក៏ត្រូវអនុវត្តតាមការបែងចែករឿងក្តីអង្គសេចក្តីដែរ ពោលគឺប្រធានតុលាការត្រូវបង្កើតលំដាប់លេខរៀងប្រចាំឆ្នាំ ស្តីពីការបែងចែករឿងក្តីរក្សាការពារទៅឱ្យចៅក្រមម្នាក់ៗ ហើយរឿងក្តីទាំងនោះនឹងត្រូវបានបែងចែកជាស្វ័យប្រវត្តិទៅចៅក្រមនីមួយៗ ដោយផ្អែកលើដីកាសម្រេច។

## ផ្នែកទី៧ ការពិនិត្យលើពាក្យសុំដីកាសម្រេចរក្សាការពារ

នៅពេលពាក្យសុំដីកាសម្រេចរក្សាការពារ បានបញ្ជូនមកដល់ចៅក្រមដែលទទួលបន្ទុកចាត់ការលើបណ្តឹងសុំដីកាសម្រេចរក្សាការពារ តាមដីកាសម្រេចប្រចាំឆ្នាំរបស់ប្រធានតុលាការរួចមក ចៅក្រមត្រូវធ្វើការពិនិត្យពាក្យសុំដីការក្សាការពារដូចខាងក្រោមៈ

ក-ឈ្មោះ ឬ នាមករណ៍ និងអាស័យដ្ឋានរបស់ភាគី ហើយនិងឈ្មោះ អាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ។

គ-សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ។

ឃ-ភាពចាំបាច់នៃការរក្សាការពារ ។

(បញ្ញត្តិមាត្រា ៥៤១ កថាខណ្ឌទី ១)

ក្នុងករណីពាក្យសុំផ្ទុយនឹងបញ្ញត្តិមាត្រា៥៤១ កថាខណ្ឌទី ១ តុលាការត្រូវបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាត ចំពោះពាក្យសុំនោះក្នុងអំឡុងពេលនោះ ( មាត្រា ៧៨

កថាខណ្ឌទី ១) ។ ប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះខាតទេ តុលាការត្រូវលើកពាក្យសុំនោះចោលដោយដីកាសម្រេច(មាត្រា៧៨ កថាខណ្ឌទី ២) ។

ការពិនិត្យនេះ ចៅក្រមក៏ត្រូវពិនិត្យអំពីសមត្ថកិច្ចតាមបញ្ញត្តិមាត្រា៥៤០ កថាខណ្ឌទី ១(តុលាការដែលមានសមត្ថកិច្ច) គឺថាមានសមត្ថកិច្ច ឬគ្មាន។ បើតុលាការកឃើញថា វាមានកង្វះសមត្ថកិច្ចចំពោះរឿងក្តីការចាត់ចែងការរក្សាការពារគេត្រូវផ្ទេររឿងក្តីនោះទៅ តុលាការដែលមានសមត្ថកិច្ច យោងតាមពាក្យសុំឬដោយឆន្ទានុសិទ្ធិរបស់តុលាការ (មាត្រា ៥៣៩ និងមាត្រា១៩ កថាខណ្ឌទី ១)។

ក្រៅពីពិនិត្យមើលពាក្យសុំ និងសមត្ថកិច្ចតុលាការមានភាពត្រឹមត្រូវ ហើយតុលា-ការត្រូវពិនិត្យមើលថាតើពន្ធពាក្យសុំ (មាត្រា៥៣៧ កថាខណ្ឌទី១)បានបង់ហើយឬនៅ។ បើពន្ធដាក់ពាក្យសុំមិនទាន់បានបង់នៅឡើយទេ តុលាការត្រូវបង្គាប់ឱ្យម្ចាស់បំណុលបង់ពន្ធពាក្យសុំនោះក្នុងអំឡុងពេលសមរម្យ (មាត្រា៥៣៩ មាត្រា៧៨ កថាខណ្ឌទី ១)។ បើម្ចាស់បំណុលមិនបានបង់តាមការបង្គាប់ខាងលើនេះ តុលាការត្រូវលើកចោលពាក្យសុំនោះ ដោយដីកាសម្រេច (មាត្រា៥៣៩ មាត្រា៧៨ កថាខណ្ឌទី ២)។

តុលាការមិនត្រូវបញ្ជូនពាក្យសុំនោះទៅកូនបំណុលទេ ពីព្រោះនីតិវិធីនៃការចាត់ចែងរក្សាការពារត្រូវបានធ្វើក្នុងវិធីដ៏សំងាត់។

## ជំពូកទី ៣ ការពិនិត្យរឿងក្តី

### ផ្នែកទី១ វិធីនៃការពិនិត្យរឿងក្តី

#### ១.១ ការពិនិត្យគ្រស្តុតាងជាឯកសារ

សម្រាប់ដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលត្រូវបង្ហាញឯកសារសេចក្តីបញ្ជាក់តំបូងដើម្បីឱ្យតុលាការអាចសម្រេចថាតើសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ ឬអត់(មាត្រា៥៤១ កថាខណ្ឌទី ១ ចំណុច គ) ឬថាតើមានភាពចាំបាច់ដើម្បីចេញដីកាសម្រេចរក្សាការពារដែរឬទេ (មាត្រា ៥៤១ កថាខណ្ឌទី ១ ចំណុច ឃ)។

សេចក្តីបញ្ជាក់ដំបូងត្រូវភ្ជាប់ជាមួយពាក្យសុំ ដើម្បីឱ្យតុលាការពិចារណា ដូច្នេះជាតំបូង តុលាការត្រូវពិនិត្យលើឯកសារអំពីសេចក្តីបញ្ជាក់តំបូងៈ

- ឯកសារបញ្ជាក់ដំបូងៈ ឯកសាចម្លងនៃ កិច្ចសន្យា ប័ណ្ណកម្មសិទ្ធិលើទ្រព្យសម្បត្តិ មូលប្បទានប័ត្រ មតកសាសន៍ បង្កាន់ដៃ កំណត់ហេតុ រូបថត របាយការណ៍ដែលធ្វើឡើង ដោយម្ចាស់បំណុល ឬ
ឯកសារបញ្ជាក់ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវ បានរក្សាការពារ
ឬឯកសារផ្សេងៗទៀតដែលចាំបាច់សម្រាប់ការរក្សាការពារ។

ឧទាហរណ៍ សូមមើលនៅក្នុងទំព័រទី ៦ ដល់ ទី ៩ នៃសំណុំឯកសារគម្រូ។

#### ១.២ ការសួរម្ចាស់បំណុល

តុលាការអាចហៅម្ចាស់បំណុលមកសួរយកពតិមានដែលទាក់ទងចំណុចខាងលើបាន ដោយឱ្យម្ចាស់បំណុលបញ្ជាក់ឱ្យបានច្បាស់លាស់នូវគោលបំណងដែលចង់ឱ្យតុលាការចាត់ចែងរក្សាការពារផ្អែកលើមាត្រា៥៣៥ កថាខណ្ឌទី១ មាត្រា១១៤ កថាខណ្ឌទី ២ (គឺថាការសួរម្ចាស់បំណុល)។ ការសួរម្ចាស់បំណុលអាចឱ្យគាត់ឆ្លើយជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ម្យ៉ាងទៀតតុលាការអាចអញ្ជើញម្ចាស់បំណុលមកតុលាការ និង សួរម្ចាស់បំណុល ឬអាចឱ្យម្ចាស់បំណុលដាក់ឯកសារបន្ថែម។ នីតិវិធីនៃការសួរម្ចាស់បំណុលគឺមិនធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ ដូច្នេះនីតិវិធីសួរម្ចាស់បំណុលមិនត្រូវធ្វើជាសាធារណៈឡើយ(សូមប្រៀបធៀបមាត្រា១១៥ កថាខណ្ឌទី២)។ គេមិនចាំបាច់តម្រូវឱ្យមានវត្តមានភាគីទាំងពីរឡើយ(សូមប្រៀធៀបមាត្រា១១៥កថាខណ្ឌទី១)។ តុលាការមិនត្រូវធ្វើកំណត់ហេតុទេ(សូមប្រៀបធៀបមាត្រា ១១៧ កថាខណ្ឌទី ១)។

ការសួរម្ចាស់បំណុលគឺជាវិធីងាយៗ សម្រាប់តុលាការក្នុងការធ្វើការបញ្ជាក់នូវខ្លឹមសារនៃពាក្យសុំ ឬភស្តុតាងជាឯកសារ។

ការសួរម្ចាស់បំណុលមិនមែនដាច់ខាតត្រូវតែធ្វើនោះទេ ប៉ុន្តែជាធម្មតានៅជប៉ុន គេតែងតែសួរម្ចាស់បំណុល។

## ១.៣ ការសួរកូនបំណុល

តុលាការអាចសួរកូនបំណុលបានផ្អែកលើមាត្រា៥៣៥ កថាខណ្ឌទី ១ មាត្រា១១៤ កថាខណ្ឌទី ២។

នីតិវិធីនៃការសួរកូនបំណុលគឺ ដូចគ្នានឹងនីតិវិធីនៃការសួរម្ចាស់បំណុលដែរ ដូច្នេះនីតិវិធីនៃការសួរកូនបំណុលមិនត្រូវធ្វើជាសាធារណៈឡើយ (សូមប្រៀបធៀបមាត្រា១១៥ កថាខណ្ឌ២)។ គេមិនចាំបាច់តម្រូវឱ្យមានវត្តមានភាគីទាំងពីរឡើយ (សូមប្រៀបធៀប មាត្រា១១៥ កថាខណ្ឌទី ១)។ តុលាការមិនត្រូវធ្វើកំណត់ហេតុទេ (សូមប្រៀបធៀប មាត្រា១១៧ កថាខណ្ឌទី ១)។

នៅក្នុងក្រមនីតិវិធីរដប្បវេណីត្រង់បទបញ្ញាតិទូទៅ ការជំនុំជំរះត្រូវធ្វើឡើងចំពោះមុខ ហើយគ្មានភាគីណាមួយត្រូវជំនុំជំរះ ដោយមិនបានសាកសួរ ឬកោះហៅឡើយ ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ (មាត្រា៣) ប៉ុន្តែនៅក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារ វាមានចរឹកលក្ខណះរបស់វា គឺលក្ខណះបណ្តោះអាសន្ន ,បន្ទាន់បង្ខំ,បន្ទាប់បន្សំ និងសំងាត់ ហេតុដូច្នេះហើយគេមិនសូវសួរកូនបំណុលទេ ព្រោះបារម្ភខ្លាចកូនបំណុលបង្កការលំបាកដល់ការអនុវត្ត ឬលួចបញ្ជៀសទ្រព្យសម្បត្តិដែលត្រូវចាត់ចែងរក្សាការពារ។ ប៉ុន្តែមានករណីលើកលែងមួយនៅក្នុងករណីនៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ជាគោលការណ៍ដីកាសម្រេចមិនអាចចេញបានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន (មាត្រា៥៤៨ កថាខណ្ឌទី ៤) ពីព្រោះការចាត់ចែងជាបណ្តោះ អាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្នអាចជះឥទ្ធិពលយ៉ាងធំធេងដល់កូនបំណុល។ វិធីនេះ (គឺថាការសួរកូនបំណុល) អាចជួយការពារផលប្រយោជន៍របស់កូនបំណុលដែរ ពេលតុលាការសួរនូវព័ត៏មានមួយចំនួននោះ។ ក្នុងករណីដែលរឿងក្តីមានលក្ខណៈស្មុគ្រស្មាញ ឬដីកាសម្រេចរក្សាការពារមើលទៅជះឥទ្ធិពលធំធេងចំពោះកូនបំណុល ឬមានលទ្ធភាពជឿជាក់ថា ការតវ៉ា

នឹងអាចធ្វើឡើងដោយកូនបំណុល
តុលាការអាចសួរកូនបំណុលដើម្បីផ្តល់ឱកាសឱ្យ កូនបំណុលធ្វើអះ អាង
ឬដាក់ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់តំបូង។

### ១.៤ ការទាញហេតុផលដោយផ្ទាល់មាត់

ដើម្បីដំណើរការនីតិវិធី តុលាការអាចជ្រើសរើសនីតិវិធីពីរគឺ ការសួរភាគី ឬការទាញហេតុផលផ្ទាល់មាត់ (មាត្រា១១៤)។ ក្នុងកិច្ចការរក្សារការពារ ភាគច្រើនតុលា-ការមិនសូវជ្រើសរើសយកការទាញហេតុផលដោយផ្ទាល់មាត់ទេ ពីព្រោះការទាញហេតុហេតុផលដោយផ្ទាល់មាត់មិនមែនជាលក្ខខណ្ឌរបស់ច្បាប់ឡើយ។ ប៉ុន្តែក្នុងករណីដែលរឿងក្តីនោះមានលក្ខណៈស្មុគស្មាញដែលតុលាការគិតថា ការសួរភាគី និងការពិនិត្យឯក-សារមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ដើម្បីចេញដីកាសម្រេច តុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ពីព្រោះការសម្រេចសេចក្តី នៅក្នុងនីតិវិធីនៃការរក្សាការពារត្រូវធ្វើឡើងដោយដីកាសម្រេច ដូច្នេះមាត្រា១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី២ ត្រូវយកមកអនុវត្ត បើតុលាការសំរេចជ្រើសរើសយកការទាញហេតុផលដោយផ្ទាល់មាត់ នីតិវិធីនេះត្រូវធ្វើជាសាធារណៈ (មាត្រា១១៥ កថាខណ្ឌទី ២) ដែលភាគីសងខាងអាចមានវត្តមានបាន (មាត្រា១១៥ កថាខណ្ឌទី ១) ហើយត្រូវធ្វើកំណត់ហេតុ (មាត្រា ១១៧ កថាខណ្ឌទី ១)។

## ផ្នែកទី ២ កម្មវត្ថុនៃការពិនិត្យ

មុននឹងចៅក្រមសម្រេចចេញដីកាសម្រេចរក្សាការពារ ចាំបាច់ត្រូវពិនិត្យភស្តុតាងឱ្យបានច្បាស់លាស់សិន ថាតើពាក្យសុំនេះមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីឱ្យតុលាការសម្រេចចេញដីកាសម្រេចរក្សាការពារឬទេ?។តាមបញ្ញត្តិមាត្រា៥៤១ បានកំណត់ពីកម្មវត្ថុនៃការពិនិត្យភស្តុតាងចំនួនពីរដែលតុលាការត្រូវការពិនិត្យ គឺសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ( មាត្រា៥៤១ កថាខណ្ឌទី ១ ចំណុច គ. ឃ និង មាត្រា៥៤១ កថាខណ្ឌទី ២)។

### ២.១ ទំនាក់ទំនងសិទ្ធិ ឬគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ

ដើម្បីពិនិត្យមើលពីទំនាក់ទំនងសិទ្ធិឬគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ គឺតុលាការត្រូវពិនិត្យមើលភស្តុតាងណាដែលបង្កើតនូវអត្ថិភាពនៃសិទ្ធិដែលម្ចាស់បំណុលមានចំពោះកូនបំណុល។ ជាទូទៅភស្តុតាងនេះ គឺជាលិខិតកិច្ចសន្យាដែលធ្វើឡើងរវាងម្ចាស់-បំណុល និងកូនបំណុល ដែលឯកសារនេះភាគច្រើនម្ចាស់បំណុលតែងភ្ជាប់មកជាមួយនឹងពាក្យសុំរបស់ខ្លួនដើម្បីជាមូលដ្ឋានក្នុងការប្តឹងសុំដីកាសម្រេច។

### ២.២.ភាពចាំបាច់សម្រាប់រក្សាការពារ

ក្រៅពីពិនិត្យមើលនូវទំនាក់ទំនងសិទ្ធិ ឬគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ តុលាការត្រូវពិនិត្យមើលតើរឿងក្តីនេះ មានភាពចាំបាច់ដើម្បីធ្វើការរក្សាការពារដែរឬអត់?។ ភស្តុតាងដែលបញ្ជាក់ពីភាពចាំបាច់ ភាគច្រើនជារបាយការណ៍ដែលម្ចាស់បំណុលរៀបចំឡើង
ដើម្បីបញ្ជាក់ពីស្ថានភាពលំបាករបស់កូនបំណុលជួបប្រទះដែលជាហេតុនាំឱ្យ ម្ចាស់បំណុលមានការបារម្ភខ្លាចកូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចបានចំពោះខ្លួន។

សរុបសេចក្តីមក ចំណុចទាំងពីរខាងលើនេះ គឺជាកម្មវត្ថុនៃការពិនិត្យភស្តុតាងដ៏សំខាន់ដែលតុលាការត្រូវពិនិត្យមុននឹងចេញដីកាសម្រេចរក្សាការពារ។ បើគ្មានចំណុចជាលក្ខខណ្ឌទាំងពីរនេះ ឬក៏ខ្វះលក្ខខណ្ឌណាមួយ តុលាការមិនអាចចេញដីកាសម្រេចរក្សាការពារនេះឡើយ គឺតុលាការត្រូវចេញដីកាសម្រេចលើកចោលពាក្យសុំ។

## ផ្នែកទី៣ សេចក្តីបញ្ជាក់ដំបូង

នៅពេលមាន ភាគីដាក់ពាក្យសុំមកតុលាការឱ្យចេញដីកាសម្រេចរក្សាការពារជាលាយលក្ខណ៍អក្សរ ដោយគោរពទៅតាម (មាត្រា៥៣៤ របៀបដាក់ពាក្យសុំ)រួចមកតុលាការត្រូវពិនិត្យនូវពាក្យសុំនោះអំពីចំណុចផ្សេងៗដែលត្រូវសរសេរនៅក្នុងពាក្យសុំដើម្បីរកឱ្យឃើញនូវៈ

- សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (មាត្រា៥៤១ កថាខណ្ឌទី ១ ចំណុច គ)
- ភាពចាំបាច់នៃការរក្សាការពារ (មាត្រា ៥៤១ កថាខណ្ឌទី ១ ចំណុចឃ)

ហើយចំណុចទាំងពីរខាងលើនេះ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងរបស់ខ្លួន ដើម្បីមានភាពងាយស្រួលក្នុងការស្វែងរកនូវចំណុចសំខាន់ទាំងពីរនេះ ដែលពេលខ្លះទោះមានសេចក្តីបញ្ជាក់ដំបូងនេះក៏ដោយ ក៏តុលាការមានការពិបាកក្នុងការស្វែងរកនូវចំណុចទាំងពីរខាងលើនេះផងដែរ។ ដូច្នេះចាំបាច់ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង (មាត្រា ៥៤១ កថាខណ្ឌទី ៣)។

ចំពោះសេចក្តីបញ្ជាក់ដំបូងនេះ គឺវាមានសារសំខាន់ណាស់ដើម្បីជាមូលដ្ឋានក្នុងការស្វែងរកថាតើមានសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារមាន ឬគ្មាន តើមានភាពចំបាច់នៃការរក្សាការពារផងដែរទេ។ ដូច្នេះ ភាគីដែលដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់តំបូង។

ដូចដែលសរសេរខាងលើ "សេចក្តីបញ្ជាក់តំបូង" គឺមានខ្លឹមសារស្រដៀងគ្នានឹងពាក្យ "ការបញ្ជាក់"ដែរ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួន។

ខុសគ្នាទី១ គឺកម្រិតនៃការបញ្ជាក់។ "ការបញ្ជាក់" សំដៅលើអ្វីៗដែលធ្វើឱ្យចៅក្រមជឿជាក់ថា មានអត្ថិភាពលើ ឬនត្ថិភាពនៃអង្គហេតុនោះ។ ម្យ៉ាងវិញទៀត "សេចក្តីបញ្ជាក់តំបូង" សំដៅលើអ្វីៗដែលធ្វើឱ្យចៅក្រម គិតថា អង្គហេតុនោះទំនងជាមាន។

ភាពខុសគ្នាផ្សេងទៀតគឺនីតិវិធី។

"សចក្តីបញ្ជាក់ដំបូង" ត្រូវបានធ្វើឡើង ដោយការដាក់ភស្តុតាងដែលអាចពិនិត្យភ្លាមៗបានផងដែរ ព្រោះវាជាដំណាក់កាលបណ្តោះអាសន្ន និងបន្ទាន់(មាត្រា ១៣១)។ ដូច្នេះជាធម្មតាឯកសារភស្តុតាងសម្រាប់ធ្វើសេចក្តីបញ្ជាក់តំបូង គឺជាភស្តុតាងជាឯកសារ ។ ហើយជាធម្មតា ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់តំបូងត្រូវបានភ្ជាប់ជាមួយពាក្យសុំ។

ឧទាហរណ៍ សូមមើលក្នុងទំព័រទី ៦ ដល់ ទី ៩ នៅក្នុងសំណុំឯកសារគម្រូ។

នៅក្នុងរឿងក្តីនៃសំណុំឯកសារគម្រូនេះ "កិច្ចសន្យាខ្ចីបរិភោគ" "លិខិតថតចម្លងយថាភូតនៃអចលវត្ថុ" និង"របាយការណ៍ដែលធ្វើឡើង ដោយម្ចាស់បំណុល" គឺជាឯក-សារសម្រាប់ធ្វើសេចក្តីបញ្ជាក់តំបូង។

ប៉ុន្តែ នីតិវិធីនៃការធ្វើសេចក្តីបញ្ជាក់តំបូងមិនត្រូវបានកំណត់តែទៅលើភស្តុតាងជាឯកសារទេ។ ការសួរភាគី ក៏ជាលទ្ធភាពមួយនៃការធ្វើសេចក្តីបញ្ជាក់តំបូងដែរ បើភាគីនោះមានវត្តមាន ពីព្រោះការសួរភាគីអាចត្រូវបានធ្វើយ៉ាងឆាប់រហ័ស ពេលដែលភាគីមានវត្តមាន។

## ផ្នែកទី ៤ ប្រាតិភោគ (មាត្រា ៥៤២)

ប្រាតិភោគមានចែងក្នុងមាត្រា ៥៤២ ដែលចែងថា “ដីកាសម្រេចរក្សាការពារអាចធ្វើ ដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគបាន”។

### ៤.១ គោលបំណងនៃប្រាតិភោគ

លក្ខណៈពិសេសនៃនីតិវិធីចេញដីកាសម្រេចរក្សាការពារ គឺតុលាការអាចចេញដីកាសម្រេចរក្សាការពារបាន ដោយពុំចាំបាច់សួរកូនបំណុល ដោយគ្រាន់តែឆ្លងកាត់ការធ្វើសេចក្ដីបញ្ជាក់ដំបូងជាការស្រេច។ ប៉ុន្តែដីកាសម្រេចរក្សាការពារ ក្នុងករណីខ្លះត្រូវប្រឈមមុខការលុបចោលទៅវិញ ត្រង់ចំណុចនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ផលប្រយោជន៍របស់កូនបំណុល គឺបណ្ដាលឱ្យកូនបំណុលខូចខាតជាច្រើន។ ដូច្នេះដើម្បីឆ្លើយតបនឹងការខូចខាតរបស់កូនបំណុលដែលកើតឡើងជាយថាហេតុ
ទើបតុលាការតម្រូវឱ្យ ម្ចាស់បំណុលដាក់ប្រាតិភោគ។
ការដាក់ប្រាតិភោគរបស់ម្ចាស់បំណុល ក្នុងបំណងទប់ស្កាត់
ការប្រើប្រាស់សិទ្ធិហួសប្រមាណ។

ជាក់ស្ដែងគោលបំណងនៃប្រាតិភោគ គឺដើម្បីធានាសងការខូចខាត និងជម្ងឺចិត្ត។ លើសពីនេះទៀត កូនបំណុលនឹងមានសិទ្ធិជាអទិភាពទៅលើម្ចាស់បំណុលផ្សេងទៀត (មាត្រា៥៣៩ មាត្រា៧២ )។

នៅប្រទេសជប៉ុនជាង៩០ភាគរយ នៃរឿងក្ដីរក្សាការពារ តុលាការតែងតែបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។

### ៤.២ ចំនួននៃប្រាតិភោគ

ពេលដែលតុលាការសម្រេចឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ តុលាការក៏ត្រូវពិចារ-ណាឱ្យបានល្អិតល្អន់លើផលប៉ះពាល់ និងឥទ្ធិពលដែលអាចនាំឱ្យមានការខូចខាតជាយថាហេតុដោយសារការចេញដីការក្សាការពារ។ ដូច្នេះ តុលាការត្រូវសាកល្បងធ្វើការវាយតំលៃលើការខូចខាត ដោយមានការប្រយត្ន័ប្រយែងបំផុតដែលនឹងអាចកើតមានឡើងចំពោះកូនបំណុល។ ទន្ទឹមនឹងនោះ តុលាការក៏ត្រូវគិតដល់លក្ខណ្ឌសំខាន់ៗដែលម្ចាស់បំណុលត្រូវទទួលបានការការពារ។ ក្រោយពីតុលាការពិចារណាលើការខូចខាតនាពេលអនាគត តុលាការក៏ត្រូវពិចារណាទៅដល់ការធ្វើសេចក្ដីបញ្ជាក់ដំបូង។

ដូច្នេះមុននឹងចេញដីការក្សាការពារ គឺតុលាការគ្រាន់តែពិនិត្យលើឯកសារនៃសេចក្តីបញ្ជាក់ដំបូង ឬ/និង សួរម្ចាស់បំណុល រួចបញ្ជូនដីកាសម្រេចរក្សាការពារនោះទៅឱ្យកូនបំណុល។ មានន័យថា “បើការបញ្ជាក់ដំបូងមានលក្ខណៈរឹងមាំ នោះចំនួននៃប្រាតិភោគ គឺ ទាប ឬតិចតួច” ។ ផ្ទុយទៅវិញ “បើការបញ្ជាក់ដំបូងពុំមានលក្ខណៈរឹងមាំ នោះតម្រូវការនៃការដាក់ប្រាតិភោគត្រូវមានកម្រិតខ្ពស់ ឬច្រើន”។ ចំណុចចុងក្រោយ តុលាការត្រូវពិចារណាដល់ប្រភេទកម្មវត្ថុ នៃការចេញដីការក្សាការពារអាចជាចលនវត្ថុ, អចលនវត្ថុ ឬសិទ្ធិលើបំណុល។ ផ្អែកលើចំណុចសំខាន់ៗទាំងប៉ុន្មានខាងលើនេះ ទើបបង្ករលក្ខណៈងាយស្រួលដល់តុលាការ ក្នុងការកំណត់ចំនួនប្រាតិភោគដែលតម្រូវឱ្យម្ចាស់បំណុលដាក់ ។

នៅប្រទេសជប៉ុន ទាក់ទិនចំនួនប្រាតិភោគគឺ មានបទដ្ឋានកម្រិតមួយជាក់លាក់ដើម្បីឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។ បទដ្ឋានកម្រិតសម្រាប់កំណត់ចំនួនប្រាតិភោគត្រូវបានកើតចេញពីការពិភាក្សារបស់ចៅក្រមដែលមានបទពិសោធន៍ច្រើនឆ្នាំ ។

## ៤.៣ វិធីនៃការដាក់ប្រាតិភោគ (មាត្រា ៥៣៦)

តើពេលណាប្រាតិភោគត្រូវបានដាក់?

ក្នុងករណី តុលាការបង្គាប់ឱ្យដាក់ប្រាតិភោគមុនពេលចេញដីកាសម្រេចរក្សាការពារការដាក់ប្រាតិភោគជាលក្ខខណ្ឌមួយដើម្បីចេញដីកាសម្រេចរក្សាការពារ។ ដូច្នេះម្ចាស់បំណុលត្រូវដាក់ប្រាតិភោគមុនចេញដីការក្សាការពារ។ម្យ៉ាងវិញទៀត តុលាការមិនចេញដីកាសម្រេចទេ រហូតដល់ប្រាតិភោគត្រូវបានដាក់។

ក្នុងករណីតុលាការចេញដីកាសម្រេចរក្សាការពារ ដែលភ្ជាប់ជាមួយនូវការបង្គាប់ឱ្យដាក់ប្រាតិភោគ ការដាក់ប្រាតិភោគ គឺជាលក្ខខណ្ឌមួយដើម្បីអនុវត្តដីកាសម្រេចរក្សាការពារ។ ដូច្នេះម្ចាស់បំណុលត្រូវដាក់ប្រាតិភោគមុនពេលអនុវត្តដីកាសម្រេចរក្សាការពារ។ ម្យ៉ាងវិញទៀត
ម្ចាស់បំណុលមិនអាចមានលទ្ធភាពអនុវត្តដីកាសម្រេចរក្សាការពារ បានឡើយ រហូតដល់ពេលដែលខ្លួនបានដាក់ប្រាតិភោគ។

នៅក្នុងរឿងក្តីនៃសំណុំឯកសារគម្រូគឺជារឿងក្តីមួយ ដែលតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគមុនពេលចេញដីកាសម្រេចរក្សាការពារ (សូមមើលទំព័រទី ១១ នៅក្នុងសំណុំ

ឯកសារគម្រូ)។ ដូច្នេះម្ចាស់បំណុលដាក់ប្រាតិភោគមុនចេញដីកាសម្រេចរក្សាការពារ និង ដាក់នូវ "សេចក្តីថ្លែងការណ៍ ឬរបាយការណ៍អំពីការដាក់ប្រាតិភោគ"ទៅតុលាការដើម្បី បង្ហាញថា ខ្លួនបានដាក់ប្រាតិភោគរួចហើយ (សូមមើលទំព័រទី ១៤ នៅក្នុងសំណុំឯកសារ គម្រូ)។

ប្រាតិភោគត្រូវមានអានុភាពដោយការផ្ញើប្រាក់ ឬឧបករណ៍អាចជួញដូរបាន ដែល តុលាការទទួលស្គាល់ថា សមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្តការរក្សាការពារ (មាត្រា ៥៣៦)។ ម្យ៉ាងវិញទៀត ប្រាតិភោគអាចត្រូវ បានដាក់ទៅតុលាការអនុវត្តការរក្សារការពារ ឬតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគ។

ចំពោះការតម្កល់ ឬការផ្ញើ គឺជារបបមួយដែលមានករណីកិច្ចដាក់ប្រាតិភោគដាក់ លុយ ឬឧបករណ៍ដែលអាចជួញដូរបាន ដើម្បីឱ្យអ្នកមានសិទ្ធិលើប្រាតិភោគនោះ មាន សិទ្ធិទាមទារយកវត្ថុដែលតម្កល់ទុកនោះបាន (មាត្រា ៥៣៩ មាត្រា ៧២)។

ករណីនេះមាត្រា៧៣ កឋាខណ្ឌទី ១ បានចែងថា "អ្នកមានសិទ្ធិលើប្រាតិភោគ ក្នុងមាត្រានេះ សំដៅទៅលើបុគ្គលដែលទទួលការផ្តល់ប្រាតិភោគ ដើម្បីជាប្រយោជន៍ របស់ខ្លួន។

ចំពោះវិធីនៃការដាក់ប្រាតិភោគលំអិតនឹងមានចែងនៅក្នុងសេចក្តីណែនាំរបស់ ក្រសួងយុត្តិធម៌ដែលបច្ចុប្បន្នកំពុងស្ថិតក្នុងសេចក្តីព្រាងនៅឡើយ ដែលនឹងត្រូវបញ្ចប់នា ពេលដ៏ខ្លីខាងមុខនេះ។

## ជំពូកទី ៤ ដីកាសម្រេចរក្សាការពារ

## ផ្នែកទី១ ទម្រង់នៃដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គ្មានមាត្រាណាមួយដែលចែងថា “ដីកាសម្រេចរក្សាការពារត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ”ទេ។ ប៉ុន្តែយើងអាចនិយាយបានថា ដីកាសម្រេចរក្សាការពារត្រូវតែសរសេរជាលក្ខណ៍អក្សរ ដោយយោងទៅលើមូលហេតុដូចខាងក្រោមនេះ:

យោងលើមាត្រា ៥៤៣ តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី។ បើដីកាសម្រេចមិនធ្វើឡើងជាលាយលក្ខណ៍អក្សរទេ នោះការបញ្ជូនដីសម្រេចមិនអាចធ្វើទៅកើតឡើយ។

ហើយការអនុវត្តការរក្សាការពារធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ (មាត្រា៥៦២ កថាខណ្ឌទី ១)។ បើដីកាសម្រេចនោះមិនធ្វើជាលាយលក្ខណ៍អក្សរនោះ ឯកសារចម្លងយថាភូតនៃដីកាសម្រេចមិនអាចធ្វើកើតឡើយ។

ដូច្នេះ ដីកាសម្រេចរក្សាការពារត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ។

## ផ្នែកទី ២ ចំណុចដែលត្រូវសរសេរនៅក្នុងដីការក្សាការពារ (មាត្រា ៥៤៥, មាត្រា ៥៤៦ និង មាត្រា៥៤៧)

### ២.១ ចំណុចចាំបាច់ដើម្បីបញ្ជាក់រឿងក្តី

ក្នុងដីកាសម្រេចរក្សាការពារ ត្រូវមានជាចាំបាច់នូវចំណុចសំខាន់ៗដើម្បីបញ្ជាក់រឿងក្តីរួមមាន: សញ្ញាណនៃភាគី, សញ្ញាណនៃសិទ្ធិលើបំណុលដែលទាមទារ, និងលេខសំណុំរឿង។

ដោយសារតែដីកាសម្រេចត្រូវបានចេញដោយផ្អែកលើពាក្យសុំ(មាត្រា ៥៣២ កថាខណ្ឌទី ១) ដីកាសម្រេចត្រូវតែជាដីកាសម្រេចដែលទាក់ទងនឹងរឿងក្តីជាក់លាក់ណាមួយដែលពាក្យសុំត្រូវបានដាក់។ ម្យ៉ាងវិញទៀត យើងមិនអាចបញ្ជាក់អំពីអត្តសញ្ញាណនៃរឿងក្តីបានឡើយ បើដីកាសម្រេចនោះមិនសរសេរអំពីចំណុចសំខាន់ៗដើម្បីបញ្ជាក់នូវរឿងក្តី។

ចំណុចមួយក្នុងចំណោមចំណុចសំខាន់ៗដើម្បីបញ្ជាក់នូវរឿងក្ដីនោះគឺ ព័ត៌មានដែលទាក់ទងនឹងភាគី ដូចជា ឈ្មោះ និងអាសយដ្ឋានរបស់ភាគី និង ឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ចំណុចផ្សេងទៀតដែលចាំបាច់ដើម្បីបញ្ជាក់នូវរឿងក្ដីនោះគឺព័ត៌មានទាក់ទងនឹងសិទ្ធិលើបំណុលដែលនឹងត្រូវបានរក្សាការពារ។

ព័ត៌មានទាក់ទងនឹងកម្មវត្ថុដែលត្រូវរក្សាការពារ អាចជាចំណុចមួយដែលចាំបាច់សម្រាប់បញ្ជាក់រឿងក្ដីផងដែរ។

ចំពោះខ្លឹមសារសរសេរសម្រាប់ការអនុវត្តជាក់ស្ដែង មានជម្រើសពីរៈ

ទី១ ចៅក្រមអាចសរសេរនូវអត្ថន័យទាំងមូលនៃភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្ដីនៅក្នុងដីកាសម្រេចតែម្ដងក៏បាន ប៉ុន្ដែផលវិបាកនៅត្រង់ថា ធ្វើឱ្យដីកាសម្រេចនោះវែង និងខាតបង់ពេលវេលាច្រើន ។

ទី២ ចៅក្រមអាចសរសេរនូវអត្ថន័យក្នុងទម្រង់សង្ខេបលើភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្ដី ដោយគ្រាន់តែដាក់ថា មានក្នុងឯកសារឧបសម្ព័ន្ធជាការស្រេច។ ម្យ៉ាងវិញទៀត ចៅក្រមអាចប្រើបញ្ជីដែលពិពណ៌នាភាគី បញ្ជីសិទ្ធិលើបំណុល និងបញ្ជីទ្រព្យសម្បត្តិដែលបានដាក់ ដោយម្ចាស់បំណុលដែលភ្ជាប់ជាមួយពាក្យសុំ និងបញ្ជាក់អំពីរឿងក្ដីដោយភ្ជាប់ជាមួយនឹងបញ្ជីទាំងនោះទៅនឹងដីកាសម្រេចតែម្ដង។ រីឯសារៈប្រយោជន៍គឺ ភាពខ្លីនៃដីកាសម្រេច ហើយថែមទាំងចំណេញពេលវេលាក្នុងការសរសេរ ពីព្រោះនីតិវិធីនៃការចេញដីកាសម្រេចរក្សាការពារគឺ ត្រូវមានភាពរហ័សដើម្បីកុំឱ្យកូនបំណុលបញ្ចៀសទ្រព្យរបស់ខ្លួនទៅឱ្យតតិយជនដែលធ្វើឱ្យខូចខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់ម្ចាស់បំណុល។

ឧទាហរណ៍សូមមើលនៅក្នុងទំព័រទី ១៦ ដល់ ទំព័រទី ២០ (ដីកាសម្រេចចាត់ចែងរក្សាការពារ)នៅក្នុងសំណុំឯកសារគម្រូ។

## ២.២ ចំនួនទឹកប្រាក់សម្រាប់ដាក់ប្រាតិភោគ និង វិធីនៃការដាក់ប្រាតិភោគ

ប្រាតិភោគ (មាត្រា៥៤២) ត្រូវបានដាក់សម្រាប់គោលបំណងដើម្បីធានាសំណងនៃការខូចខាតដែលកើតឡើងចំពោះកូនកំណុល ដោយសារតែកំហុសរបស់ដីកាសម្រេចរក្សាការពារ។ ដូច្នេះកូនបំណុលមានផលប្រយោជន៍ច្រើនណាស់ចំពោះព័ត៌មានដែលទាក់ទងនឹងប្រាតិភោគ ប៉ុន្ដែជាធម្មតា កូនបំណុលគ្មានឱកាសទទួលបាននូវព័ត៌មានបែបនេះទេ ដោយសារតែភាពជាសម្ងាត់នៃការរក្សាការពារ។ ប៉ុន្ដែលក្ខខណ្ឌនៃភាពជាសម្ងាត់

នេះលែងមានអត្ថិភាព បន្ទាប់ពីដីកាសម្រេចរក្សាការពារត្រូវបានបញ្ជូនទៅឱ្យកូនបំណុល (មាត្រា ៥៤៣)។ ដូច្នេះចៅក្រមគប្បីបញ្ចូលព័ត៌មានអំពីប្រាតិភោគ នៅក្នុងដីកាសម្រេច ដើម្បីប្រាប់ដល់កូនបំណុល អំពីចំនួននៃប្រាតិភោគដែលត្រូវបានដាក់ជាអាទិ៍។

ឧទាហរណ៍ សូមមើលទំព័រទី ១៦ (ដីកាសម្រេចចាត់ចែងរក្សាការពារ) នៅក្នុងសំណុំឯកសារគម្រូ។

## ២.៣ សេចក្តីសម្រេច

ដីកាសម្រេចចាត់ចែងរក្សាការពារ ត្រូវសរសេរបញ្ចូលនូវសេចក្តីសម្រេច ការសម្រេចបញ្ចប់នូវការវិនិច្ឆ័យលើ ពាក្យសុំដែលដាក់ ដោយម្ចាស់បំណុល។

ឧទាហរណ៍ សូមមើលទំព័រទី ១៧ (ដីកាសម្រេចចាត់ចែងការរក្សាការពារ) នៅក្នុងសំណុំឯកសារគម្រូ។

## ២.៤ ការកំណត់ជាក់លាក់នូវកម្មវត្ថុ នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៤៦)

ចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ឱ្យបានច្បាស់លាស់នូវកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ចំណុចនេះជាគោលការណ៍សំខាន់ដែលត្រូវតែគោរពជាដាច់ខាត (មាត្រា៥៤៦ វាក្យខណ្ឌទី ១)។ ប្រសិនបើតុលាការធ្វើការកំណត់កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នស្ថិតក្នុងភាពមិនច្បាស់លាស់ នោះការអនុវត្តដីកាសម្រេចនឹងជួបបញ្ហាជាក់ជាពុំខាន។ ជាពិសេស ទាក់ទិននឹងការរឹបអូសជាបណ្តោះអាសន្នលើអចលនវត្ថុដែលទាមទារឱ្យមានព័ត៌មានគ្រប់គ្រាន់អំពីអចលនវត្ថុនោះ។ រីឯព័តិមានដែលទទួលបាន គឺតាមរយៈឯកសារដែលបានភ្ជាប់ជាមួយពាក្យសុំ ឬឯកសារអំពីការធ្វើសេចក្តីបញ្ជាក់ដំបូងដែលម្ចាស់បំណុលបានដាក់ (មាត្រា១៣១)។

ចំពោះព័ត៌មានដែលសំខាន់សម្រាប់អចលនវត្ថុគឺ ឯកសារដែលចេញឱ្យដោយការិយាល័យដីធ្លីនាញភូមិបាល ជាពិសេស ប័ណ្ណកម្មសិទ្ធិអចលនវត្ថុរបស់កូនបំណុលតែម្តង ប្រសិនបើម្ចាស់អាចរកបាន។ ទន្ទឹមគ្នានោះសម្រាប់ចលនវត្ថុវិញដូចជា រថយន្តព័ត៌មានដែលអាចកំណត់បាននូវភាពជាក់លាក់នៃរថយន្តនោះ គប្បីចុះបញ្ជីលេខរថយន្តនោះ (មាត្រា៣៨៧) ដូចជា ប្រភេទ រថយន្ត, ស៊េរីឆ្នាំណា,ពណ៌អ្វី, ផលិតនៅប្រទេសណា, ស្ថានភាពរបស់រថយន្ត និងនរណាជាម្ចាស់កម្មសិទ្ធិ។

ចៅក្រមអាចប្រើប្រាស់បញ្ជីពិពណ៌នាអំពីទ្រព្យសម្បត្តិដែលម្ចាស់បំណុលបានដាក់ជាមួយពាក្យសុំ និងបញ្ជាក់ពីកម្មវត្ថុនៃដីកាសម្រេច តាមរយៈបញ្ជីពិពណ៌នាអំពីទ្រព្យដែលភ្ជាប់ជាមួយនឹងពាក្យសុំ។

សូមមើលឧទាហរណ៍នៅក្នុងទំព័រទី ២០ (ដីកាសម្រេចការចាត់ចែងរក្សាការពារ) នៅក្នុងសំណុំឯកសារគម្រូ។

ម្យ៉ាងវិញទៀត ទោះបីជាមាត្រា៥៤៦ វាក្យខណ្ឌ១ បានចែងថា "តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ" ក៏ពិតមែនដែលនេះជាគោលការណ៍ទូទៅដែលត្រូវតែគោរព។ ប៉ុន្តែ វាក្យខណ្ឌទី២ នៃមាត្រា ៥៤៦ បានចែងថា

"*ប៉ុន្តែចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្ដោះអាសន្នអាចចេញបាន ដោយមិនចាំបាច់កំណត់កម្មវត្ថុ*"។

គួរកត់សំគាល់ និងបែងចែកឱ្យបានច្បាស់ទៅលើស្ថានភាពនៃការរឹបអូសជាបណ្ដោះអាសន្នរវាងការរឹបអូសជាបណ្ដោះអាសន្នលើអចលនវត្ថុ និងការរឹបអូសជាបណ្ដោះអាសន្នលើចលនវត្ថុ។ ចំពោះអចលនវត្ថុ ពេលអនុវត្តដីកាសម្រេច គឺត្រូវធ្វើការចុះបញ្ជីដើម្បីបញ្ជាក់ថា អចលនវត្ថុនោះត្រូវបានរឹបអូសជាបណ្ដោះសិន (មាត្រា៥៦៧ កថាខណ្ឌទី ៤ និងមាត្រា៤២០ កថាខណ្ឌទី ២) ដូច្នេះដើម្បីឈានទៅធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នូវទ្រព្យបានតម្រូវឱ្យមានការកំណត់ឱ្យបានជាក់លាក់នូវព័ត៌មានជុំវិញអចលនវត្ថុនោះតាំងនៅ។ ផ្ទុយទៅវិញចំពោះចលនវត្ថុ ពេលអនុវត្តដីកាសម្រេច គឺអាជ្ញាសាលានឹងចុះទៅដល់ទីតាំងដែលចលនវត្ថុនោះតាំងនៅរួចធ្វើការរឹបអូសចលនវត្ថុនោះផ្ទាល់តែម្ដង(មាត្រា៥៦៥ កថាខណ្ឌទី ១)។ ហើយវាជាការលំបាកសម្រាប់ចៅក្រមដើម្បីកំណត់ជាក់លាក់នូវចលនវត្ថុដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន ពីព្រោះជាធម្មតាចៅក្រមមិនដឹងប្រភេទនៃចលនវត្ថុរបស់កូនបំណុលទេ។ ដូច្នេះច្បាប់មិនតម្រូវឱ្យចៅក្រមកំណត់លាក់លាក់ អំពីចលនវត្ថុនៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នឡើយ(មាត្រា ៥៤៦ វាក្យខណ្ឌទី២)។

## ២.៥ ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៤៧ )

ចំពោះខ្លឹមសារនៃសេចក្ដីសម្រេចនេះ បន្ទាប់ពីតុលាការសម្រេចធ្វើការរឹបអូសជាបណ្ដោះអាសន្នកម្មវត្ថុណាមួយនោះហើយ តុលាការក៏ត្រូវកំណត់ដោយ**ខានពុំបាន**នូវប្រាក់

វិដោះ ពីការរឹបអូសជាបណ្ដោះអាសន្នដើម្បីឱ្យកូនបំណុលរួចផុតពីការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ននោះ។ ផ្ទុយទៅវិញ បើក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នគ្មានបញ្ជាក់ពីប្រាក់វិដោះទេនោះ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់នោះទេ ពីព្រោះថា ក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ត្រង់មាត្រា៥៤៧ កថាខណ្ឌ១ចែងថា “...តុលាការ**ត្រូវ**កំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវធ្វើដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន”។

សូមមើលឧទាហរណ៍នៅក្នុងទំព័រទី ១៧ (ដីកាសម្រេចការចាត់ចែងរក្សាការពារ) នៅក្នុងសំណុំឯកសារគម្រូ។

## ២.៦ មូលហេតុនៃការចេញដីកាសម្រេច

យោងតាមមាត្រា ២១៦ ដែលយកមកអនុវត្តដូចគ្នាចំពោះរឿងក្តីការចាត់ចែងរក្សាការពារ (មាត្រា ៥៣៩) បទបញ្ញត្តិដែលទាក់ទងនឹងសាលក្រមត្រូវយកមកអនុវត្តដូចគ្នានឹងដីកាសម្រេច ដរាបណាការអនុវត្តនោះមិនប៉ះពាល់ដល់ខ្លឹមសារនៃដីកាសម្រេច។ ហើយមាត្រា១៨៩ជាមាត្រាមួយនៃបញ្ញត្តិដែលទាក់ទងនឹងសាលក្រមដែលចែងថា នៅក្នុងលិខិតសាលក្រមត្រូវសរសេរពីសំអាងហេតុ(មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច ង)។

ដូច្នេះចៅក្រមគប្បីសរសេរអំពីសំអាងហេតុដោយសង្ខេប នៅក្នុងរឿងក្តីការចាត់ចែងរក្សាការពារ ពីព្រោះខ្លឹមសារមួយក្នុងចំណោមខ្លឹមសារនៃនីតិវិធីការចាត់ចែងរក្សាការពារ គឺមានចរិកលក្ខណៈជាបន្ទាន់។

ឧទាហរណ៍សូមមើលទំព័រទី ១៦, ១៧ (ដីកាសម្រេចការចាត់ចែងរក្សាការពារ) នៅក្នុងសំណុំឯកសារគម្រូ។

## ២.៧ បន្ទុកនៃប្រាក់ប្រដាប់ក្តី

(១) ពេលដែលការសម្រេចសេចក្តីលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារត្រូវបានធ្វើឡើង សេចក្តីសម្រេចនោះត្រូវកំណត់អំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី (បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចនេះអាចត្រូវបានប្តឹងទៅតុលាការថ្នាក់ខ្ពស់ ដូច្នេះសេចក្តីសម្រេចនេះឆ្លើយតបទៅនឹង“សេចក្តីសម្រេចដែលបញ្ចប់រឿងក្តីនៅក្នុងតុលាការ” (មាត្រា ៦៥ កថាខណ្ឌទី ១)។

(២) ពេលដែលដីកាសម្រេចទទួលស្គាល់ពាក្យសុំដីកាសម្រេចរក្សាការពារត្រូវបានធ្វើ៖ មានលទ្ធភាពពីរផ្លូវ៖

ទស្សនៈទី១ គឺថាដីកាសម្រេចនេះមិនត្រូវកំណត់បន្ទុកនៃប្រាក់ប្រដាប់ក្ដី (បណ្ដឹងតវ៉ាចំពោះ ដីកាសម្រេចនេះអាចត្រូវបានដាក់ទៅតុលាការដែលចេញដីកាសម្រេច(មាត្រា ៥៥០) និង ដូច្នេះ ដីកាសម្រេចនេះមិនឆ្លើយតបទៅនឹង "ការសម្រេចសេចក្ដីដែលបញ្ចប់រឿងក្ដីនៅក្នុងតុលាការ" សូមមើលមាត្រា៦៥ កថាខណ្ឌទី ១។

ទស្សនៈផ្សេងទៀតគឺថា ដីកាសម្រេចដែលទទួលស្គាល់ពាក្យសុំដីកាសម្រេចរក្សាការពារត្រូវកំណត់នូវប្រាក់ប្រដាប់ក្ដី។ មូលហេតុនៃទស្សនៈនេះមានដូចខាងក្រោម៖

ជានិច្ចកាល បណ្ដឹងជំទាស់មិនត្រូវបានគេធ្វើចំពោះដីកាសម្រេចដែលទទួលស្គាល់នូវពាក្យសុំឡើយ។ នៅក្នុងករណីនេះ បន្ទុកនៃប្រាក់ប្រដាប់ក្ដីនឹងមិនត្រូវសម្រេចឡើយ។ ដើម្បីចៀសនូវស្ថានភាពនេះ គេបកស្រាយថា ដីកាសម្រេចដែលទទួលស្គាល់ពាក្យសុំដីកាសម្រេចរក្សាការពារត្រូវកំណត់អំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី។

ឧទាហរណ៍សូមមើលនៅទំព័រទី ១៧ (ដីកាសម្រេចរក្សាការពារ)នៅក្នុងសំណុំឯកសារគម្រូ។ ដីកាសម្រេចក្នុងសំណុំឯកសារគម្រូយកតាមយោបល់ក្រោយនេះ។

## ផ្នែកទី៣ ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

### ៣.១ គោលបំណងនៃប្រាក់រំដោះ

កាលណាដីកាសម្រេចរក្សាការពារដែលទាក់ទងនឹងការរឹបអូសជាបណ្ដោះអាសន្ន បានន័យថា ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បី ការអនុវត្តដោយបង្ខំចំពោះសិទ្ធលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ប៉ុន្តែនៅពេលដែលបានធ្វើប្រាក់ស្មើទៅនឹងចំនួនទឹកប្រាក់ នៃសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ ឬចំនួនទឹកប្រាក់នៃកម្មវត្ថុដែលបានរឹបអូសជាបណ្ដោះអាសន្ន ភាពចាំបាច់នៃការរឹបអូសជាបណ្ដោះអាសន្នមិនមានអត្ថិភាពទៀតទេ។ ដូច្នេះតុលាការត្រូវកំណត់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អំពីចំនួនទឹកប្រាក់ដែលត្រូវធ្វើដោយកូនបំណុលដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា៥៤៧ កថាខណ្ឌទី ១)។

គោលបំណងគឺការពារផលប្រយោជន៍របស់កូនបំណុល និងម្ចាស់បំណុល បើកូនបំណុលផ្ញើចំនួនទឹកប្រាក់ដែលបានកំណត់ដោយតុលាការ កូនបំណុលនោះអាចរួចផុតពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ននូវទ្រព្យដែលត្រូវរឹបអូស កូនបំណុលអាចប្រើប្រាស់ និងចាត់ចែងទ្រព្យនោះបានដោយសេរី ព្រោះការអនុវត្តការរឹបអូសជាបណ្តោះអាសន្នត្រូវ បានលុបចោល(មាត្រា ៥៦៩កថាខណ្ឌទី១) បើសិនជាមានការកើនតំលៃគាត់ក៏លក់បាន ថ្លៃដែរ រីឯម្ចាស់បំណុលនឹងទទួលបាននូវការពេញចិត្តពីចំនួនទឹកប្រាក់ដែលកូនបំណុល បានផ្ញើដូចខាងក្រោម។ ប្រាក់រំដោះគឺដើម្បីជំនួសទ្រព្យដែលត្រូវបានរឹបអូស ដូច្នេះប្រាក់ រំដោះគឺស្ថិតនៅក្រោមការអនុវត្តរបស់ម្ចាស់បំណុល។ និយាយតាមការពិតទៅ អានុភាពនៃការរឹបអូសជាបណ្តោះអាសន្នលាតសន្ធឹងដល់សិទ្ធិលើបំណុលដើម្បីឱ្យប្រគល់ប្រាក់ដែលបានផ្ញើត្រឡប់ទៅវិញ ដូច្នេះកូនបំណុលមិនអាចដកប្រាក់ដែលបានផ្ញើតាមទំនើងចិត្តឡើយ ។ ដើម្បីទទួលបាននូវប្រាក់រំដោះនេះ ម្ចាស់បំណុលត្រូវដាក់បណ្តឹងអង្គសេចក្តីថ្មីមួយទៀត ក្នុងករណីដែលម្ចាស់បំណុលឈ្នះបណ្តឹងអង្គសេចក្តី ហើយគាត់ទទួលបាននូវលិខិតអនុវត្ត (មាត្រា៣៥០) ម្ចាស់បំណុលអាចរឹបអូសសិទ្ធិលើបំណុលខាងលើដើម្បីទទួលបានមកវិញនូវប្រាក់ដែលបានផ្ញើ ដោយផ្អែកលើលិខិតអនុវត្ត។ ដូច្នេះគាត់មានភាពងាយស្រួលក្នុងការអនុវត្តនូវការអនុវត្តដោយបង្ខំបាន។

### ៣.២ ចំនួននៃប្រាក់រំដោះ

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីពុំមានមាត្រាណាមួយ ចែងអំពីចំនួនប្រាក់រំដោះដែលត្រូវដាក់នោះទេ លើកលែងតែមាត្រា៥៤៧។ ដូច្នេះចៅក្រមមានឆន្ទានុសិទ្ធិក្នុងការសម្រេចអំពីប្រាក់រំដោះ។ ប៉ុន្តែតុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងការពារផលប្រយោជន៍សំរាប់គូភាគី ដូច្នេះការដាក់ប្រាក់រំដោះត្រូវពិចារណាតាមពីរចំណុចដូចខាងក្រោម:

-ចំនួនទឹកប្រាក់នៃទ្រព្យដែលត្រូវរឹបអូស:បានន័យថា តុលាការត្រូវពិចារណាទៅលើតំលៃនៃទ្រព្យរបស់កូនបំណុលដែលម្ចាស់បំណុលធ្វើការស្នើសុំរឹបអូស និងយកចំនួនទឹកប្រាក់នៃទ្រព្យដែលត្រូវបានរឹបអូសជាបណ្តោះអាសន្នជាចំនួនប្រាក់រំដោះ ដោយសារតែប្រាក់រំដោះ គឺជាប្រាក់មួយប្រភេទសម្រាប់ដាក់ជំនួសនូវទ្រព្យដែលត្រូវបានរឹបអូសជា

បណ្តោះអាសន្ន។ ប៉ុន្តែបើទ្រព្យនោះមានតំលៃលើសពីបំណុលនោះ តុលាការត្រូវពិចារ-ណាចំនួនបំណុលដែលទាមទារ ។

-សិទ្ធិលើបំណុលត្រូវបានរក្សាការពារៈ តុលាការត្រូវធ្វើយ៉ាងណាឱ្យមានសមតុលរវាងសិទ្ធិបំណុល និងចំនួនទឹកប្រាក់នៃទ្រព្យដែលត្រូវរឹបអូស។ តុលាការត្រូវពិចារណាចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារជាចំនួនប្រាក់រំដោះ ពីព្រោះគោលបំណង នៃការរឹបអូសជាបណ្តោះអាសន្ន នឹងធានានូវការអនុវត្តដោយបង្ខំនាពេលអនាគតចំពោះកម្មវត្ថុនៃបណ្តឹង ដែលមានគោលបំណងឱ្យសងប្រាក់ និងប្រាក់ដែលមានតម្លៃសមមូលទៅនឹងចំនួននៃសិទ្ធិលើបំណុល គឺគ្រប់គ្រាន់ហើយដើម្បីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលបានលើកឡើងខាងលើ។

នៅក្នុងសំណុំឯកសារគម្រូ (សូមមើលទំព័រទី ១៧ (ដីកាសម្រេចរក្សាការពារ) ចៅក្រមអាចយកចំនួនប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល។

### ៣.៣ វិធីនៃការដាក់ប្រាក់រំដោះ

ពេលកូនបំណុលបានធ្វើប្រាក់រំដោះ កូនបំណុលត្រូវធ្វើទៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬតុលាការអនុវត្ត(មាត្រា៥៤៧ កថាខណ្ឌទី ២)។ នីតិវិធីលំអិតនៃការធ្វើប្រាក់នឹងមានកំណត់នៅក្នុង “សេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ស្តីពី នីតិវិធីនៃការធ្វើប្រាក់ប្រាតិភោគទៅតុលាការ” ដែលក្រសួងយុត្តិធម៌កំពុងធ្វើសេចក្តីព្រាង។

## ផ្នែកទី ៤ ការបញ្ជូនដីកាសម្រេចរក្សាការពារ

មាត្រា៥៤៣បានចែងថា“តុលាការត្រូវបញ្ជូនដីការសម្រេចរក្សាការពារទៅភាគី”។

### ៤.១ ដីកាសម្រេចបង្គាប់ឱ្យរក្សាការពារ

នៅពេលដែលតុលាការចេញដីកាសម្រេចរក្សាការពារតុលាការត្រូវអនុវត្តតាមមាត្រា៥៤៣ គឺត្រូវបញ្ជូនដីកាសម្រេចររក្សាកាពារទៅឱ្យភាគីទាំងម្ចាស់បំណុល និងកូនបំណុលផងដែរ។

ការបញ្ជូននេះគឺមានគោលបំណងដើម្បីឱ្យភាគីបានដឹងពីសេចក្ដីសំរេចនៃដីការរក្សាការពារហើយក៏ជាការផ្ដល់ឱកាសឱ្យដល់កូនបំណុលក្នុងការប្ដឹងតវ៉ាដែរមាត្រា៥៥០ ហើយចំពោះនីតិវិធីនៃការបញ្ជូន គឺអនុវត្តតាមមាត្រា២៤៦ ដល់ មាត្រា២៥៧។

ដើម្បីចៀសវាងនូវការរារាំងរបស់កូនបំណុល និងធានានូវការអនុវត្តការរក្សាការពារតុលាការគប្បីបញ្ជូន ដីកាសម្រេចនោះទៅកូនបំណុល បន្ទាប់ពីតុលាការបញ្ជាក់ថាការអនុវត្តបានធ្វើចប់សព្វគ្រប់ហើយ។ វិធីនេះគឺអាចធ្វើទៅបាន ពីព្រោះការអនុវត្តដីកាសម្រេចរក្សាការពារអាចត្រូវបានអនុវត្តមុនពេលដីកាសម្រេចនោះត្រូវបានបញ្ជូនដល់កូនបំណុល (មាត្រា៥៦២ កថាខណ្ឌទី ៣)។

## ៤.២ ដីកាសម្រេចលើកចោលពាក្យសុំ

ចំពោះដីកាសម្រេចលើកចោលពាក្យសុំរបស់ម្ចាស់បំណុលដែលបានប្ដឹងសុំឱ្យចេញដីកាសម្រេចរក្សាការពារ គឺពុំចាំបាច់បញ្ជូនទៅឱ្យភាគីកូនបំណុលទេ ដោយហេតុថាដីការសម្រេចលើកពាក្យសុំចោលនោះ ពុំបានប៉ះពាល់ដល់ផលប្រយោទរបស់កូនបំណុលទេ ហើយម្យ៉ាងទៀត ក៏ជាការទុកឱកាសឱ្យម្ចាស់បំណុលស្វែងរកភស្តុតាងបន្ថែមទៀត សំរាប់ប្ដឹងសុំដីកាសម្រេចរក្សាការពារជាថ្មីទៀតដែរ ហើយការអនុវត្តរបៀបនេះក៏ជាការរក្សាការសម្ងាត់ឱ្យម្ចាស់បំណុលផងដែរ។

ដូច្នេះ “ដីកាសម្រេចរក្សាការពារ” នៅក្នុងមាត្រា៥៤៣ គប្បីត្រូវពិចារណាក្នុងន័យថាជា ដីកាសម្រេចបង្គាប់ឱ្យការរក្សាការពារ។

សំណួរផ្សេងទៀតថាតើមាត្រា២១៣ អនុវត្តដូចគ្នានឹងករណីនៃការចេញដីកាសម្រេច លើកពាក្យសុំចោល ឬអត់។

ជាទូទៅ ការអនុវត្តដូចគ្នានៃមាត្រា ២១៣ គឺមិនស្របគ្នានឹងភាពជាសម្ងាត់នៃនីតិវិធីការរក្សាការពារឡើយ ដូច្នេះមាត្រា ២១៣ មិនអនុវត្តដូចគ្នាចំពោះករណីនេះទេ។

ប៉ុន្តែ បើតុលាការធ្វើការសួរកូនបំណុល ឬធ្វើការទាញហេតុផលដោយផ្ទាល់មាត់មុនពេលចេញដីកាសម្រេច តុលាការត្រូវជូនដំណឹងទៅកូនបំណុលអំពីដីការសម្រេចលើកពាក្យសុំចោល។ ពីព្រោះលក្ខខណ្ឌនៃភាពជាសម្ងាត់លែងមានអត្ថិភាពទៀតហើយ នៅក្នុងករណីនេះ ហើយតុលាការគប្បីប្រាប់ដំណឹងអំពីលទ្ធផលទៅបុគ្គលដែលពាក់ព័ន្ធនៅក្នុងនីតិវិធីនេះ។ ដូច្នេះគេអាចបកស្រាយបានថា មាត្រា២១៣ គឺអនុវត្តដូចគ្នាទៅនឹងករណីនេះ។

## ជំពូកទី ៥ ការអនុវត្តការរក្សាការពារ

### ផ្នែកទី១ ស្ថាប័នដែលអនុវត្តនូវដីកាសម្រេចការចាត់ចែងរក្សាការពារ

ក្រោយពីតុលាការចេញដីកាសម្រេចណាមួយខាងលើ តាមពាក្យសុំហើយ ម្ចាស់-បំណុលនៃការអនុវត្តការរក្សាការពារ អាចដាក់ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរក្សាការពារទៅតុលាការ ឬអាជ្ញាសាលាដែលមានសមត្ថកិច្ចអនុវត្តដីកាសម្រេចរក្សាការពារ ដោយផ្អែកលើប្រភេទ និង កម្មវត្ថុ នៃដីកាសម្រេចរក្សាការពារនីមួយៗនោះ។

ការអនុវត្តការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ (មាត្រា៥៣២ កថាខណ្ឌទី ២) ។

តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ (មាត្រា ៥៣២ កថាខណ្ឌទី ៣) ។

### ១.ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

### ស្ថាប័នអនុវត្ត ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ចំពោះការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ (មាត្រា ៥៦៧ កថាខណ្ឌទី ២) ។

### ស្ថាប័នអនុវត្ត ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា

ចំពោះការអនុវត្តការរឹបអូសជាបណ្ដោះតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ (មាត្រា ៥៦៨ កថាខណ្ឌទី ២)។

ចំពោះការអនុវត្តការរឹបអូសជាបណ្ដោះ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវាជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅត្រូវមានសមត្ថកិច្ច ជាតុលាការអនុវត្តរក្សាការពារ (មាត្រា៥៦៨ កថា-ខណ្ឌទី ២) ។

### ស្ថាប័នអនុវត្ត ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ

ស្ថាប័នដែលត្រូវធ្វើការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ គឺអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ច លើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ (មាត្រា៥៦៥ កថាខណ្ឌទី ១ ) ។

### ស្ថាប័នអនុវត្ត ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

តុលាការអនុវត្តរក្សាការពារ គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន (មាត្រា៥៦៦ កថាខណ្ឌទី ២)។

### ២. ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬវិធីអនុវត្តដោយបង្ខំ (មាត្រា៥៧០) ។

### ផ្នែកទី ២ របៀបដាក់ពាក្យសុំអនុវត្តដីកាសម្រេចរក្សាការពារ

ម្ចាស់បំណុលត្រូវសរសេរពាក្យសុំឱ្យអនុវត្តការចាត់ចែងរក្សាការពារ (មាត្រា៥៣៤ ចំណុច ច) ហើយបន្ទាប់មក គាត់ត្រូវដាក់ពាក្យសុំនោះចូលទៅការិយាល័យរដ្ឋបាលនៃតុលាការ ឬអាជ្ញាសាលាដែលមានសមត្ថកិច្ច ដើម្បីចាប់ផ្ដើមនីតិវិធីការអនុវត្តការចាត់ចែងរក្សាការពារ (មាត្រា៥៣២ កថាខណ្ឌទី ២)។

### ផ្នែកទី៣ ចំណុចដែលត្រូវសរសេរចូលនៅក្នុងពាក្យសុំឱ្យអនុវត្តការរក្សាការពារ

**ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំអនុវត្តដីកាសម្រេចរក្សាការពារត្រូវសរសេរដូចខាងក្រោម :**

ផ្អែកលើមាត្រា៥៦៤ យើងអាចយោងលើមាត្រា៣៤៩ កថាខណ្ឌទី២បាន។ មានន័យថា ចំណុចដែលត្រូវសរសេរចូលនៅក្នុងពាក្យសុំឱ្យអនុវត្តការរក្សាការពារត្រូវតែស្របតាមបញ្ញត្តិនៃមាត្រា៣៤៩ កថាខណ្ឌទី ២។

ក- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ
និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់ បានកំណត់ (មាត្រា ៥៦៤ និង មាត្រា ៣៤៩ កថាខណ្ឌទី ២ ចំណុច ក)។

ម្ចាស់បំណុលអាចប្រើប្រាស់នូវបញ្ជីពណ៌នាអំពីភាគីបាន។

ខ- សញ្ញាណនៃលិខិតអនុវត្ត (មាត្រា ៥៦៤ និងមាត្រា៣៤៩ កថាខណ្ឌទី ២ ចំណុច ខ)។

នៅក្នុងរឿងក្ដីនៃការអនុវតការរក្សាការពារ លិខិតអនុវត្តគឺដីកាសម្រេចនៃការចាត់ចែងរក្សាការពារ។

គ- សេចក្ដីសុំឱ្យអនុវត្តតាមការបង្ខំ ដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល (មាត្រា៥៦៤ និង មាត្រា៣៤៩ កថាខណ្ឌ២ ចំណុច គ)។

ក្នុងរឿងក្ដីនៃសំណុំឯកសារគម្រូនេះ“ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ”មានលក្ខខណៈគ្រប់គ្រាន់សម្រាប់សេចក្ដីសុំឱ្យអនុវត្ត ពីព្រោះការរឹបអូសជាបណ្ដោះអាសន្នគឺជាប្រភេទមួយនៃការអនុវត្តការបង្ខំ ដោយផ្ទាល់។

ឃ-សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុ នៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្ត ដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ (មាត្រា៥៦៤ និង មាត្រា៣៤៩ កថាខណ្ឌទី ២ ចំណុច ឃ)។

ម្ចាស់បំណុលអាចប្រើប្រាស់បញ្ជីពណ៌នាអំពីអចលនវត្ថុ

ង- ខ្លឹមសារនៃសេចក្ដីសម្រេចដែលម្ចាស់បំណុលសុំក្នុងករណី ដែលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តដោយជំនួស ឬវិធានបង្ខំដោយប្រយោល(មាត្រា៥៦៤ និង មាត្រា៣៤៩ កថាខណ្ឌទី២ ចំណុច ង)

សម្រាប់ឧទាហរណ៍សូមមើលទំព័រទី ២៣ (ពាក្យសុំអនុវត្តការចាត់ចែងរក្សាការពារ) នៅក្នុងសំណុំឯកសារគម្រូ។

នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុត្រូវសរសេរអំពីទីកន្លែងដែលចលនវត្ថុដែលត្រូវរឹបអូសជាបណ្តោះអាសន្ននោះស្ថិតនៅ (មាត្រា៥៦៥ កថាខណ្ឌទី ៤ និង មាត្រា ៣៨៤ កថាខណ្ឌទី ២)។

## ផ្នែកទី៤ ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំឱ្យអនុវត្តដីកាសម្រេចរក្សាការពារ

កាលណាអ្នកប្តឹងសុំឱ្យចាត់ចែងរក្សាការពារ បានទទួលដីកាសម្រេចរក្សាការពារពីតុលាការរួចហើយ អ្នកប្តឹងសុំត្រូវដាក់ពាក្យសុំឱ្យអនុវត្ត ហើយត្រូវភ្ជាប់មកជាមួយពាក្យសុំនោះគឺ:

-លិខិតចំលងយថាភូតនៃដីកាសម្រេចរក្សាការពារ ហើយករណីនេះអ្នកប្តឹងសុំនៃដីការក្សារការពារពុំចាំបាច់ស្នើសុំរូបមន្តអនុវត្តទេ(មាត្រា៥៦២ កថាខណ្ឌទី១)។ មូលហេតុអ្វីបានជាច្បាប់មិនតម្រូវឱ្យមានរូបមន្តអនុវត្ត ពីព្រោះថា ការរក្សាការពារជាបញ្ហាបន្ទាន់បង្ខំ ដូច្នេះនីតិវិធីគប្បីត្រូវបានអនុវត្តយ៉ាងលឿនបំផុតដែលអាចធ្វើទៅបាន។ មូលហេតុផ្សេងទៀត គឺដោយសារដីកាសម្រេចរក្សាការពារអាចត្រូវបានអនុវត្ត លុះត្រាតែមានពាក្យសុំពីភាគី (មាត្រា២១៣ កថាខណ្ឌទី ១) ហើយដីកានោះត្រូវអនុវត្តក្នុងអំឡុងពេល២សប្តាហ៍ (មាត្រា៥៦២ កថាខណ្ឌទី ២)។ ដូច្នេះអានុភាពដើម្បីអនុវត្តដីកាសម្រេចការចាត់ចែងរក្សាការពារ គឺមិនត្រូវឱ្យមន្ទីសារកាវីចេញនូវរូបមន្តអនុវត្តឡើយ។ ក៏ប៉ុន្តែបើសិនជាការអនុវត្តចំពោះ ឬសម្រាប់ជនក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងដីការក្សាការពារត្រូវធ្វើឡើង ដោយភ្ជាប់នឹងរូបមន្តអនុវត្ត (មាត្រា ៥៦២ កថាខណ្ឌទី ១)។

-លិខិតបញ្ជាក់អំពីអ្នកតំណាងដោយអណត្តិ: កាលណាអ្នកប្តឹងសុំឱ្យចេញដីការក្សាការពារ បានផ្តល់សិទ្ធិអំណាចឱ្យអ្នកតំណាងដោយអាណត្តិសិទ្ធអំណាចនេះត្រូវធ្វើជាលាយ-លក្ខណ៍អក្សរ (មាត្រា ៥៣ កថាខណ្ឌទី ២) ប៉ុន្តែបើមានបណ្តឹងអង្គសេចក្តី ហើយហើយមានលិខិតប្រគល់សិទ្ធិអ្នកតំណាងដោយអាណត្តិរួចហើយ សិទ្ធិតំណាងនេះក៏អាចធ្វើសកម្មភាពចំពោះការចាត់ចែងរក្សាការពារបានដែរ(មាត្រា ៥៤ កថាខណ្ឌទី ២) ដោយគ្រាន់តែធ្វើការចំលងឯកសារនេះ ផ្ទូវការរួចភ្ជាប់មកជាមួយពាក្យសុំអនុវត្តតែម្តង។

## ផ្នែកទី៥ សោហ៊ុយការអនុវត្តដីការសម្រេចរក្សាការពារ

### ពន្ធដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារ

ក្នុងករណីស្ថាប័នអនុវត្តជាតុលាការ (ឧទាហរណ៍ ករណីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល) ពន្ធដាក់ពាក្យសុំ គឺចំនួន៥.០០០រៀល (មាត្រា៥៣៧ កថាខណ្ឌទី ១) ប្រាក់ពន្ធនេះមិនត្រឹមតែប្រើសម្រាប់បង់ពន្ធពាក្យសុំដីកាសម្រេចប៉ុណ្ណោះទេ ថែមទាំងសម្រាប់សោហ៊ុយនៃការអនុវត្តដីសម្រេចរក្សាការពនោះទៀតផង។

ក្នុងករណីស្ថាប័នអនុវត្តជាអាជ្ញាសាលា (ឧទាហរណ៍ ការរឹបអូសជាបណ្តោះចំពោះចលនវត្ថុ ការចាត់ចែងជាបណ្តោះអាសន្ន) អ្នកដាក់ពាក្យសុំត្រូវបង់សោហ៊ុយដូចមានកំណត់នៅក្នុង“ច្បាប់ស្តីពីអាជ្ញាសាលា” ដែលច្បាប់នោះស្ថិតនៅជាសេចក្តីព្រាងនៅឡើយ ដែលកំពុងរៀបចំឡើងដោយក្រសួងយុត្តិធម៌ (មាត្រា ៥៣៧ កថាខណ្ឌទី ៥)។

### សោហ៊ុយក្រៅពីពន្ធពាក្យសុំ

នៅពេលម្ចាស់បំណុល ដែលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តដីកាសម្រេចររក្សាការពារត្រូវបង់សោហ៊ុយចាំបាច់ជាមុនដែលកំណត់ដោយតុលាការអនុវត្ត ឬអាជ្ញាសាលាសម្រាប់ដំណើការអនុវត្ត(មាត្រា៥៣៧ កថាខណ្ឌទី ២) ប៉ុន្តែបើអ្នកសុំអនុវត្តមិនបានបង់សោហ៊ុយជាមុនទេ នោះតុលាការអនុវត្តរក្សាការពារអាចលើកចោលពាក្យសុំនោះ ឬអាចលុបចោលនូវនីតិវិធីអនុវត្តការរក្សាការពារបាន (៥៣៧ កថាខណ្ឌទី ៣) ។

## ផ្នែកទី៦ ការពិនិត្យពាក្យសុំឱ្យអនុវត្តដីការក្សាការពារ (មាត្រា ៥៣៤ មាត្រា ៥៦៤ និងមាត្រា ៣៤៩ កថាខណ្ឌទី ២)

ពាក្យសុំឱ្យអនុវត្តដីការក្សាការពារ គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរ (មាត្រា ៥៣៤ ចំណុច ច)។ ដូច្នេះ នៅពេលដែលតុលាការអនុវត្តបានទទួលពាក្យសុំឱ្យអនុវត្តដីកាសម្រេចរក្សាការពារ តុលាការត្រូវពិនិត្យថាតើពាក្យសុំឱ្យអនុវត្តដីការក្សាការពារនេះស្របនឹងលក្ខខណ្ឌនៃរបៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំឬទេ តាមមាត្រា៥៦៤ និង មាត្រា ៣៤៩ កថាខណ្ឌទី ២ ដូចជាឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត សញ្ញាណនៃលិខិតអនុវត្ត សេចក្តីស្នើសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ និង សញ្ញាណ

នៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំ ដែលម្ចាស់បំណុលនៃការអនុវត្តសុំ។ ក្រៅពីនេះ តុលាការអនុវត្តត្រូវពិនិត្យផងដែរនូវឯកសារភ្ជាប់ដូចជា លិខិតចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារលិខិតប្រគល់សិទ្ធិតំណាង ដោយអាណត្តិ បញ្ជីឈ្មោះភាគី ។

## ផ្នែកទី៧ ការពិនិត្យលើលក្ខខណ្ឌចាំបាច់នៃការអនុវត្តដីការក្សាការពារ

បន្ទាប់ពីបានពិនិត្យលើរបៀបនៃការដាក់ពាក្យសុំឱ្យអនុវត្តដីការក្សាការពារ ហើយតុលាការអនុវត្តត្រូវពិនិត្យលើលក្ខខណ្ឌចាំបាច់នៃការអនុវត្តដីការក្សាការពារ ព្រោះថា បើមិនបានបំពេញនូវលក្ខខណ្ឌទាំងនោះទេគឺការអនុវត្តដីការក្សាការពារមិនអាចធ្វើបានឡើយ ។ ល័ក្ខខ័ណ្ឌចាំបាច់ទាំងនោះមានដូចខាងក្រោម :

### ៧.១ លិខិតយថាភូតនៃដីកាសម្រេចរក្សាការពារ (មាត្រា៥៦២ កថាខណ្ឌទី ១ )

តាមមាត្រា៥៦២ កថាខណ្ឌទី ១ គឺតុលាការត្រូវពិនិត្យ តើឈ្មោះភាគីដែលមាននៅក្នុងពាក្យសុំឱ្យអនុវត្តនោះ ដូចគ្នានឹងឈ្មោះភាគីដែលមាននៅក្នុងដីកាសម្រេចរក្សាការពារឬទេ។ បើឈ្មោះដូចគ្នា គឺការអនុវត្តដីកាសម្រេចរក្សាការពារត្រូវធ្វើឡើងដោយផ្អែកតែលើឯកសារចម្លងលិខិតយថាភូតនៃដីកាសម្រេចរក្សាការពារប៉ុណ្ណោះ។ ប៉ុន្តែបើឈ្មោះភាគីមិនដូចគ្នាទេ គឺការអនុវត្តដីកាសម្រេចរក្សាការពារត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងលិខិតយថាភូតនៃដីកាសម្រេចរក្សាការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត។

### ៧.២ អំឡុងពេល (មាត្រា ៥៦២ កថាខណ្ឌទី ២)

តាមខ្លឹមសារនៃមាត្រា៥៦២ កថាខណ្ឌទី ២ ការអនុវត្តរក្សាការពារត្រូវធ្វើ បើអំឡុងពេល០២សប្តាហ៍មិនទាន់កន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារត្រូវបានបញ្ជូនទៅម្ចាស់បំណុល។ ដូច្នេះបើម្ចាស់បំណុលបានទទួលដីកាសម្រេចរក្សាកាពារហើយ។ មិនបានដាក់ពាក្យសុំឱ្យអនុវត្តរក្សាការពារនោះ ក្នុងអំឡុងពេល០២សប្តាហ៍ទេ គឺដីកា-សម្រេចនោះនឹងគ្មានអានុភាពដើម្បីអនុវត្តនោះទេ។

### ៧.៣ ផ្សេងៗ

ក្នុងករណីដែលតុលាការចេញដីកាសម្រេចរក្សាការពារដោយឱ្យដាក់ប្រាតិភោគ (មាត្រា ៥៤២) ប្រាតិភោគនេះជាលក្ខខណ្ឌមួយសម្រាប់ការអនុវត្តដីកាសម្រេចរក្សាការពារ។ ដូច្នេះតុលាការត្រូវពិនិត្យមើលថាតើប្រាតិភោគត្រូវបានដាក់រួចហើយ ឬមិនទាន់ដាក់។

## ផ្នែកទី៨ របៀបនៃការអនុវត្តដីកាសម្រេចរក្សាការពារ

ក្នុងករណីដែលតុលាការអនុវត្តរកឃើញនូវលក្ខខណ្ឌចាំបាច់ផ្សេងៗត្រូវបានបំពេញ តុលាការអនុវត្តនោះត្រូវធ្វើនីតិវិធីអនុវត្តដីកាសម្រេចរក្សាការពារនោះ។

របៀបថាតើត្រូវធ្វើយ៉ាងដូម្តេចចំពោះការអនុវត្តដីកាសម្រេចរក្សាការពារនោះ អាស្រ័យលើ ប្រភេទនៃដីកាសម្រេច និងកម្មវត្ថុនៃដីកាសម្រេច (មាត្រា៥៦៥ មាត្រា ៥៦៦ មាត្រា៥៦៧ មាត្រា៥៦៨ មាត្រា៥៧០)។

ចំពោះករណីនៃការរឹបអូសជាបណ្តោះចំពោះអលចនវត្ថុត្រូវធ្វើតាមរបៀបនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ(មាត្រា៥៦៧ កថាខណ្ឌទី១)។

ដើម្បីចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ញើកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីការរឹបអូសជាបណ្តោះអាសន្ន (មាត្រា៥៦៧ កថាខណ្ឌទី ៣)។

ឧទាហរណ៍សូមមើលទំព័រ ៣០ (ការផ្ញើកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន) នៅក្នុងសំណុំឯកសារគម្រូ។

យោងលើការចុះបញ្ជីនៃការរឹបអូសជាបណ្តោះអាសន្ន ដោយអនុលោមតាមការផ្ញើកផ្តាក់ដែលបានលើកឡើងខាងលើ គឺការិយាល័យចុះបញ្ជីត្រូវផ្ញើនូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី(មាត្រា៥៦៧ កថាខណ្ឌទី ៤ មាត្រា ៤២០ កថាខណ្ឌទី ២) ហើយក្រឡាបញ្ជីនោះត្រូវរក្សាទុកនូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះនៅក្នុងសំណុំរឿង។

ឧទាហរណ៍ សូមមើលទំព័រទី ៣២ (ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន) នៅក្នុងសំណុំឯកសារគម្រូ។

## ជំពូកទី ៦ ការលុបចោលប្រាតិភោគ

មាត្រា៧៣ កថាខណ្ឌទី ២ ចែងថា "ប្រសិនបើអ្នកដែលបានដាក់ប្រាតិភោគបាន បញ្ជាក់នូវការរលត់នៃហេតុដែលត្រូវបានដាក់ប្រាតិភោគ តុលាការត្រូវចេញដីកាសម្រេច លុបចោលនូវប្រាតិភោគនោះតាមពាក្យសុំ"។

ដូច្នេះ ក្នុងករណីម្ចាស់បំណុលនៃរឿងក្តីរក្សាការពារ ឈ្នះបណ្តឹងអង្គសេចក្តី ហើយសាលក្រមបានចូលជាស្ថាពរ ម្ចាស់បំណុលនោះអាចទទួលនូវប្រាតិភោគដែល គាត់ បានដាក់តាមខ្លឹមសារ នៃសេចក្តីបង្គាប់នៃមាត្រា៥៤២ របស់តុលាការនោះត្រឡប់មកវិញ បាន។

យោងតាមមាត្រា៧៣ កថាខណ្ឌទី ២ ម្ចាស់បំណុលត្រូវដាក់ពាក្យសុំលុបប្រាតិ-ភោគដើម្បីទទួលនូវប្រាតិភោគនោះត្រឡប់មកវិញ។

ឧទាហរណ៍ សូមមើលទំព័រទី ៣៥ (ពាក្យសុំលុបប្រាតិភោគ) នៅក្នុង សំណុំឯកសារគម្រូ។

យោងលើពាក្យសុំ ម្ចាស់បំណុលត្រូវដាក់ឯកសារដូចខាងក្រោមនេះ ម្ចាស់បំណុល ត្រូវបានតម្រូវឱ្យធ្វើការបញ្ជាក់នូវការរលត់នៃហេតុដែលត្រូវដាក់ប្រាតិភោគ(មាត្រា ៧៣ កថាខណ្ឌទី ២)។

- សាលក្រម
- សេចក្តីបញ្ជាក់ថា សាលក្រមនោះបានចូលជាស្ថាពរ (មាត្រា ២៥៨ កថាខណ្ឌទី ១)។

ក្នុងករណីដែលតុលាការទទួលស្គាល់ថា មូលហេតុនៃការដាក់ប្រាតិភោគបានរលត់ តុលាកាត្រូវចេញដីកាសម្រេចលុបប្រាតិភោគនោះ។

សូមមើលឧទាហរណ៍នៅក្នុងទំព័រទី ៣៩ (ដីកាសម្រេចលុបប្រាតិភោគចោល) នៅក្នុងសំណុងកសារគម្រូ។

ម្ចាស់បំណុលអាចទទួលប្រាតិភោគត្រឡប់មកវិញបាន ដោយផ្អែកលើដីកាសម្រេច លុបប្រាតិភោគចោល។ នីតិវិធីនៃការទទួលនូវប្រាតិភោគត្រឡប់មកវិញ ដោយផ្អែកលើ ដីកាសម្រេចដែលបានលើកឡើងខាងលើនឹងមានចែងនៅក្នុងសេចក្តីណែនាំរបស់ក្រសួងស្តី ពី នីតិវិធីនៃការដាក់ប្រាតិភោគដែលក្រសួងយុត្តិធម៌កំពុងធ្វើសេចក្តីព្រាង។